កាិយាល័យមេធាវីខ្មែរ
LAW OFFICE OF
Stewart H. Lim & Associates
ពិគ្រោះយោបល់ដោយមិនគិតកំរៃ
Stewart H. Lim
Main Office
100 Oceangate Blvd., Suite 1200 • Long Beach, CA 90802
(562) 590-7181 FREE CONSULTATION
-ច្បាប់គ្រោះថ្នាក់ចរាចរ, សំណង៍ប្រាក់ចិញ្ចឹមកូន, ច្បាប់អន្តោប្រវេសន៍, បណ្តឹងលែងលះ, សេដ្ឋកិច្ចក្ស័យធន, បណ្តឹងមរតក, ការពារក្តី
- Car Accident, Child Support, Immigration, Divorce, Bankruptcy, Living Trust, Defense you in Court



# ខ្មែរប៉ុស្តិ៍ THE KHMER POST

KHMER BILINGUAL BIWEEKLY NEWSPAPER

VOLUME 1 ISSUE 2 | OCTOBER, 16th - 31st, 2007 | ADVERTISING (562) 739-5928 | WWW.THEKHMERPOST.COM



ឱសថស្ថានខ្មែរថ្ងៃនេះ
Today Pharmacy
2200 E. Anaheim St.#C Long Bach, CA 90804
Tel: (562) 438-2031 • Fax: (562) 438-2031
(2 Blocks East of Cherry Ave.)
Fast and Friendly Service • FREE DELIVERY
Today Pharmacy
គឺជាឱសថស្ថានបំរើការចែកចាយថ្នាំតាមវេជ្ជបញ្ជា ។
- ទទួលយកនៅ Medicare & Medical និង Insurance ។
- ដឹកជញ្ជូនថ្នាំផ្តល់ជូនឲ្យដល់គេហដ្ឋានដោយមិនគិតពីកំរៃផងដែរ ។
សូមស្វាគមន៍!


## ក្រុងខ្មែរសម្បត្តិថ្មី



Photo by: Vantha El

*ដោយ ៖ ពិន សំខុន*

*"សម្បត្តិថ្មីអី បើពុំមានអ្វីផ្លាស់ប្តូរផងនោះ!"*

នេះជាសម្តីក្រុមអ្នកមានទុទិដ្ឋិនិយម ចំពោះសេចក្តីសម្រេចឲ្យមាន "ក្រុងខ្មែរ"នៅឡុងប៊ិចខ្មែរនេះ ។ អ្នកខ្លះទៀត អបអរសាទរថា ជាកិត្តិយសថ្មីមួយដែល ស.រ.អា ទទួលស្គាល់សហគមន៍ខ្មែរយ៉ាងដូច្នេះ។ ទុទិដ្ឋិនិយម ឬសុទិដ្ឋិនិយមពុំទាន់ឃើញមតិអបអរសាទរ ជាសម្បត្តិថ្មី ប្រៀបបាននឹងពេជ្រចរណៃ មិនទាន់ច្នៃដែលគេទើបប្រគល់មកឲ្យនូវឡើយទេ ។ យើងសូមមិត្តអ្នកអាន សាកល្បងបង្កើរអារម្មណ៍ជាមួយនឹងយើងបន្តិច ក្រែងបានដឹងថា តើដុំពេជ្រនេះយើងនឹងច្នៃរបៀបណា ?

(តទៅទំព័រទី ៦ ក)


TOP AUTO INSURANCE AGENCY
Free Quote, Low Rates, Why pay more
• LOW COST • LOW DOWN • LOW MONTHLY
AUTO - LIFE - HEALTH - HOME - COMMERCIAL
-រថយន្ត -ជីវិត -សុខភាព -គេហដ្ឋាន - ពាណិជ្ជកម្ម
Tiffany Prak
Agent/Broker
Lic.# 0E44334
(562) 230-5100
2760 E. Spring St., Ste 140 • Long Bach, CA 90806
Tel: (562) 989-1800 • Fax: (562) 989-1899


## ឆាំង សុង ៖ ជីវិតអ្នកនយោបាយដែលទីបញ្ចប់មានតែបាតដៃទទេ និងគ្មានដីមួយបន្ទី!

*ដោយ ៖ មាជ សុវណ្ណារ៉ា*



Photo by: Ryan Lafferey

ឆាំង សុង ដែលកន្លងទៅប៉ុន្មានខែនេះ ត្រូវគេដឹងថាបានតំណែងជាន់ខ្ពស់ជាទីប្រឹក្សារាជរដ្ឋាភិបាល ឋានៈ រដ្ឋមន្ត្រីដែលមានកិច្ចការងារធ្វើជាមួយឧបនាយករដ្ឋ មន្ត្រី សុខ អាន។ តំណែងនេះត្រូវបាន ឆាំង សុង អះអាងថា វាទំនងជារាជរដ្ឋាភិបាលបានមើលឃើញ ពីសមត្ថភាពដែលគាត់ អាចបន្តជួយបំរើសង្គមជាតិ ជាបន្តទៅ ទៀតជាមួយអ្វីដែលយើងធ្លាប់បានធ្វើ និងបទពិសោធន៍ មានមកជាច្រើនជំនាន់ក្នុងឆាកនយោបាយ នៅកម្ពុជា នាអតីតកាល ។

អតីតសាស្ត្រាចារ្យអក្សរសាស្ត្របារាំង នៃសាកលវិទ្យា

(តទៅទំព័រទី ៤ ខ)

## វិចារណកថា ខ្នាតវាស់នយោបាយកម្ពុជា

ខ្មែរនៅបរទេសចូលចិត្តលេងល្បែងនយោបាយតាមដានវាសនាកម្ពុជា គឺចង់ឱ្យប្រទេសតូចមួយនេះមានដំណើរដូចប្រទេសប្រជាធិបតេយ្យ

(តទៅទំព័រទី ៣ គ)

## ខ្មែរក្រៅស្រុកជាដង្ហើមសេដ្ឋកិច្ចកម្ពុជា

*ដោយ ៖ មាជ សុវណ្ណារ៉ា*

អ្នកសេដ្ឋវិទូអះអាងថា ខ្មែររស់នៅក្រៅប្រទេស គឺជាគ្រឹះមូលដ្ឋានថវិកា មួយក្នុងការជួយជំរុញ

(តទៅទំព័រទី ៥ ឃ)


PHNOM PENH EXPRESS
ក្រុមហ៊ុនទទួលផ្ញើប្រាក់ និងលក់សំបុត្រយន្តហោះ
2140 E. Anaheim St., Long Beach, CA 90804 • Tel: (562) 434-3322/ (562) 434-3760
VISA MasterCard

FARMERS INSURANCE GROUP
FARMERS INSURANCE
Douglas Horn Agency
License#0B83665
Life Insurance, Home Insurance, Business Insurance, Auto Insurance, Health Insurance, One Stop Service, Bail Bond, គោរព-ស្មោះត្រង់-ទទួលខុសត្រូវ
1633 Long Beach Blvd. Suite A •Long Beach, CA 90813
Tel:(562) 591-3100 Fax:(562) 591-3911

STATE FARM INSURANCE
ក្រុមហ៊ុនធានារ៉ាប់រង
State Farm
Peter Kong Insurance Agency
Sovannara + Sokha
License# OD 23345
• Business Liability Insurance • ធានារ៉ាប់រងទទួលបន្ទុកនៃហាងពាណិជ្ជកម្ម
• Auto Insurance • ធានារ៉ាប់រងរថយន្ត
• Home Insurance • ធានារ៉ាប់រងគេហដ្ឋាន
• Life Insurance • ធានារ៉ាប់រងជីវិត
• Health Insurance • ធានារ៉ាប់រងសុខភាព
• Apartement Insurance • ធានារ៉ាប់រងល្វែងអាគារ
• Disability Insurance • ធានារ៉ាប់រងពិការភាព
• Family & Individual Coverage • ធានារ៉ាប់រង បុគ្គល និងគ្រួសារ
(Notary Public)
2750 E. Spring Street, Suite 201, Long Beach, CA 90806
Tel:(562) 426-9189 Fax:(562) 426-4669







TOYOTA
CABE
40 YEARS
SCION

**ទី~តាំង** (Ty Tang)
Speak Khmer, Thai,
Vietmanes, Lao,
Chinese, English
Cell: (562) 787-1306
sales@cabetoyota.com

**កណ្ណថារា~យូ**
(Kan You)
និយាយភាសាខ្មែរនិងអង់គ្លេស
Cell: (562)477-9702
sales@cabetoyota.com

**វុធ~ផូ**
(Vuth C. Pho)
និយាយភាសាខ្មែរនិងអង់គ្លេស
Cell: (562)552-6439
sales@cabetoyota.com

**TOYOTA**
***CABE***

## នៅក្បែរលោក-អ្នកជានិច្ច!
## គ្មានក្រេឌីត គ្មានបញ្ហា ទទួលកាត់ខែ!




**(562) 595-7411 • (800) 576-2223 • Fax: (562) 424-6731**

2895 Long Beach Blvd. Long Beach, CA 90813
1/2 MILE SOUTH OF 405 FRWY Se Habla Español
www.cabetoyota.com 1-877-862-2223

(តមកពីទំព័រទី ១ គ)

ឯទៀតក្នុងពិភព លោក បើលទ្ធផលមិនបាន ដូច អ្នកទាំងនោះច្រើនតែចង់បោកក្បាល ក៏ បោចសក់ខ្លួនឯងស្ទើរទំពែកក្បាលតែរៀងៗខ្លួន ពីព្រោះតែការលំបាកទាំងអម្បាលមាណ នៅ កម្ពុជា សុទ្ធសឹងតែមានគំរូបសំរាប់ដោះស្រាយ បានយ៉ាងងាយស្រួល ។ ពួកគេបានយកខ្នាត នៃ ស.រ.អា, បារាំង, អង់គ្លេស, អាល្លឺម៉ង់... ទៅអូសអភិវឌ្ឍន៍នៅកម្ពុជា គិតថា បើធ្វើ តាមតែខ្នាតនៃប្រទេសទាំងនោះទៅ លទ្ធផល នឹងបានដូចតែគ្នា ជាប្រាកដ...តែធាតុពិតវិញ មិនត្រឹមតែឱ្យផលយ៉ាងយឺតប៉ុណ្ណោះទេ វា ថែមទាំងឱ្យផល ផ្ទុយទៅវិញគួរឱ្យខ្មាញ់ ណាស់...តើហេតុអ្វី ?។

យើងមុខជានៅចងចាំជាមិនខានថា កាលពី បោះឆ្នោតឆ្នាំ១៩៩៣ ការស្រង់មតិពលរដ្ឋមួយ និយាយថា "ពលរដ្ឋចង់បានការផ្លាស់ប្តូរអ្នក កាន់អំណាចខ្មែរ"។ លទ្ធផលនៃការបោះឆ្នោត រៀបចំដោយ អ.ស.ប ឆ្លើយមកស្របនឹងមតិ មែន គឺហ៊្វុនស៊ិនប៉ិចរាជានិយម បានអាសនៈ ៥៨ លោក សឺន សាន បាន១០អាសនៈ ម៉ូលី ណាកា បាន១អាសនៈ នេះគឺសម្លេងឆ្នោត ប្រឆាំងនឹងគណបក្សប្រជាជន ដែលបាន អាសនៈតែ៥១ប៉ុណ្ណោះ ។ ពេលនោះអ្នកបាន សម្លេងឆ្នោតច្រើន ពុំបានប្តូរដៃកាន់អំណាចពី គណបក្សប្រជាជនបានទេ ពីព្រោះសម្តេចព្រះ ប្រមុខរដ្ឋបានប្រកាសឱ្យលទ្ធផលស្មើគ្នា លើក ឱ្យមាននាយករដ្ឋមន្ត្រីដល់ទៅពីររូប ឱ្យកាន់ អំណាច បើទោះជាច្បាប់ពុំមាន ចែងជាមុនមក ក្តី ។ ពេលនោះ ដំណោះស្រាយ "សម្លេង ពលរដ្ឋ" បានត្រូវដាក់ពីក្រោយដំណោះស្រាយ "សន្តិសុខ"។

មកដល់ឆ្នាំ១៩៩៨ ឱកាសសម្រាប់ប្តូរអ្នក គ្រប់គ្រងកម្ពុជាកើតឡើងជាថ្មីម្តងទៀត ពេល នោះពុំមាន អ.ស.ប មករាប់សន្លឹកឆ្នោត ឬ ធានាសន្តិសុខឱ្យកម្ពុជា ទៀតទេ គឺម៉ាស៊ីន បោះឆ្នោតរបស់គណបក្សប្រជាជន នឹងធានា ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ឱ្យពលរដ្ឋ ខ្មែរ ។ មុនពេលបោះឆ្នោត ពលរដ្ឋខ្មែរនៅតែ ចង់ បានការផ្លាស់ប្តូរដៃកាន់អំណាចដូចមុន ដដែល នេះបើតាមការស្រង់មតិពលរដ្ឋខ្មែរ ក៏ ប៉ុន្តែព្រឹត្តិការណ៍ ដែលបានកើតឡើងនៅកម្ពុជា គឺការវាយបំបែកគណបក្ស ដែល នឹងធ្វើឱ្យមាន ការគ្រោះថ្នាក់ដល់បក្សប្រជាជន មានគណ បក្សហ៊្វុនស៊ិនប៉ិច គណបក្សលោក សឺន សាន គណបក្សជាតិខ្មែរ...ធ្វើឡើងដោយ កម្លាំងរដ្ឋ អំណាចប្រជាជន និងដោយរដ្ឋប្រហារមួយនៅ ឆ្នាំ១៩៩៧ ។ នៅលើគំនរនៃការគំរាមកំហែង ដល់ពលរដ្ឋម្ចាស់ឆ្នោត លទ្ធផលដែលបាន ប្រកាស គឺគណបក្សប្រជាជនបាន៦៤អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិច បាន៤៣អាសនៈ គណបក្ស សម រង្ស៊ី បាន១៥អាសនៈ ក៏ប៉ុន្តែ លទ្ធផលនៃចំនួនសន្លឹកឆ្នោតវិញ គណបក្សពីរ ចុងក្រោយបូកគ្នា បានឈ្នះ គណបក្សប្រជា ជនដល់ទៅ១០ម៉ឺនសន្លឹក ឯណោះ ។

មកទល់ត្រឹមនេះ បំណងនៃចិត្តសប្បុរសធម៌ ចង់ផ្តល់សេចក្តីសុខសាន្តត្រាណជូន ពលរដ្ឋ កម្ពុជា ឱ្យដូចពលរដ្ឋសេរីឯទៀតៗ ខ្មែរនៅ បរទេសមើលឃើញថា កម្ពុជា កំពុងដើរថយ ក្រោយទៅវិញ គឺការបោះឆ្នោតក្នុងរូបភាព លោកសេរី បានត្រូវវាស់"ម៉ែត្រ"នៃសម្តេចព្រះ ប្រមុខរដ្ឋ និងគណបក្សប្រជាជនរួមដៃគ្នា ពុំ មែនដោយ"សម្លេង ពលរដ្ឋ"នោះទេ ។ សម្លឹង មើលទៅកាន់ការបោះឆ្នោតនៅកម្ពុជាតែត្រឹមពីរ អណត្តិប៉ុណ្ណោះ គេនឹងបានឃើញថា នៅ មាន"កត្តាមនុស្ស" មួយទៀតដែលសំខាន់ ណាស់ ដែរ ខ្វះមិនបានទេ ។ នៅកម្ពុជាភាព បរិសុទ្ធនៃការបោះឆ្នោត ស្ទើរចាប់កំហុសមិន បាន ក៏ប៉ុន្តែគេបានបញ្ជូនមនុស្សខិលខូចឱ្យ ទៅកាន់អំណាចស្ទើរចាប់មិនខុស ។ នៅ ប្រទេសកម្ពុជា ការប្រើរង្វាស់ក្នុងស្រុកចំនួន ជាង១៥ឆ្នាំកន្លងទៅសម្រាប់វាស់ខ្នាតអន្តរជាតិ ឥឡូវបានមកដល់ចំណុចឥតត្រឡប់ក្រោយ ។ កម្ពុជាលែងនៅជា "ទន្លេសាប" ដែលទឹកហូរត្រ ឡប់ក្រោយ៦ខែម្តងនោះទៀតហើយ គេកំពុង ក្លាយជា"ទន្លេមេគង្គទាំងស្រុងដែលនាំទឹកមាន ប្រភពនៅប្រទេសចិន ដីគោកហូរនាំល្បប់ មក ពីវៀតណាម មកស្រោចស្រពកម្ពុជាគ្មានឈប់ ឈរ ។ ស្ថានភាព "ទឹកហូរមិនត្រឡប់" នេះ បានផ្តល់រូបភាពអភិវឌ្ឍន៍កម្ពុជាថ្មី ដែលគ្មាន ពលរដ្ឋកម្ពុជានៅក្នុងនោះ កាន់តែច្បាស់ឡើង ដែរ ។

យន្តការបោះឆ្នោត ដ៏ប្រណីតដដែលនេះ បានត្រូវប្រើជាថ្មីម្តងទៀត នាឱកាសបោះឆ្នោត ឆ្នាំ២០០៣ ។ ដូចគ្នាពេលមុនៗពលរដ្ឋក្នុង ស្ទង់មតិថ្មីមួយទៀត នៅតែ ចង់ឃើញមានការ ផ្លាស់ប្តូរអ្នកកាន់អំណាចក្នុងរដ្ឋដដែល ។ ចំណែកឯលទ្ធផលវិញ ទទួលបានយ៉ាងដូច្នេះ គឺគណបក្សប្រជាជនបានសម្លេងឆ្នោត ៤៧% តែការបែងចែក ដ៏ប៉ិនប្រសព្វឱ្យ៧៣អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិចបាន២៦អាសនៈ និង គណបក្ស សម រង្ស៊ី បាន២៤អាសនៈ ។ គណ បក្សហ៊្វុនក្នុងចំនួនអាសនៈ ដែលអាចកំណត់ ថា គណបក្សប្រជាជនកំពុងនៅក្នុង "ការអរ គុណ" ចំពោះខ្លួន ពុំបានប្រើគុណសម្បត្តិនោះ ជាប្រយោជន៍នៃ"សម្លេងពលរដ្ឋ"ខ្លួន ដោយ ទទួលស្គាល់សម្លេងឆ្នោត"កញ្ចប់" របស់ គណ បក្សប្រជាជន ម្ល៉ោះហើយពលរដ្ឋបានវាយតំ លៃថា ខ្វះសេចក្តីក្លាហាន ខ្វះសុចរិត យុត្តិធម៌ ក្នុងគម្ពីរព្រះពុទ្ធសាសនា ដែលខ្មែរយើងបាន ស្គាល់យ៉ាងជាក់ច្បាស់ថា "បើអ្នកចង់ធ្វើបុណ្យ ឱ្យបានបុណ្យ អ្នកត្រូវប្រកាន់ឥរិយាបទនៃសីល ៥ជាមុនសិន គឺការមិនលួច ការមិនភរ ការមិន

(តទៅទំព័រទី ៧ គ)


ក្រុមហ៊ុនធានារ៉ាប់រង
TOP AUTO INSURANCE AGENCY
នាងខ្ញុំនិយាយភាសាខ្មែរ
AUTO - LIFE - HEALTH - HOME - COMMERCIAL
រថយន្ត -ជីវិត -សុខភាព -គេហដ្ឋាន -ពាណិជ្ជកម្ម
-Immediate Coverage
-Any car, any driver
FREE QUOTE
LOW RATES
Instant SR22
Why pay more
-Low Cost. Low Down. Low Monthly Payment
Tickets, accident, DUI=No Problem
- Multiple Car discount
- Good driver discount
• ធានារ៉ាប់រងជូនភ្លាមៗដល់អ្នកបើកបរគ្រប់រូប និង យានយន្តគ្រប់ប្រភេទ
• ចុះថ្លៃជូនអ្នកបើកបរមានសុវត្ថិភាព និងចុះថ្លៃជូន ចំពោះរថយន្តច្រើន
• បង់កាត់ខែតិច • ជំរាបតម្លៃជូនជាមុន





Tiffany Prak
Broker/Agent Lic.# 0E44334
(562) 230-5100
2760 E. Spring St., Suite 140 • Long Beach, CA 90806
Tel: (562) 989-1800 Fax: (562) 989-1899



Please, Ask for David
(526) 599-1234
DJ Auto Body Parts Inc.
Quality Domestic & Foreign Auto Body Partrts
1130 Santa Fe Ave., Long Beach, CA 90813
Hoods • Fenders Grills • Bumpers
Radiator • A/C Condensers
All kind of Lights and More...
DJ SPECIALIZE IN:
-Spoilers -Mirrors -Bed Liners -Side Step Bars
-Custom Lights -Custom Grilles -Custom Hoods
--Fan Assembly
ទំនិញយើងខ្ញុំលក់តម្លៃសមរម្យនិងធានារកជូនលោកអ្នកនូវ ទំនិញដែលមិនមានក្នុងហាងយើងខ្ញុំ ។






# ទីណាមានគ្រោះអាសន្ន...ទីនោះមានកាកបាទក្រហម !

## បងប្អូនខ្មែរចូលរួមស្តាប់ការអប់រំពីសុវត្ថិភាពការពារជីវិតពេលមានអាសន្ន

ដោយ ៖ មាស សុវណ្ណារិទ្ធិ

សង្គមជាតិនិមួយៗ ដែលទំនាក់ទំនងគ្នា ទោះជាក្រុមកុលសម្ព័ន្ធ ឬជាប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ និងលទ្ធិកុម្មុយនីស្តក៏ដោយ ។ ហើយបើ កាលណាមានគ្រោះអាសន្នដែលបង្កហេតុដោយបរិស្ថានធម្មជាតិ រញ្ជួយផែនដី, ទឹកជំនន់, ឆ្លើងឆេះផ្ទះ និងប្រការអ្វីផ្សេងៗទៀត គឺមិនអាចគេចផុតពីការជួយ សង្គ្រោះជាបន្ទាន់ពីកាកបាទក្រហមជាតិ និងអន្តរជាតិឡើយ ក្នុងផ្នែកមនុស្សធម៌ ។ ពោលគឺទីណាមានគ្រោះអាសន្ន...ទីនោះមានកាកបាទក្រហម ។ ដូចជានៅ ប៉ុន្មានសប្តាហ៍ជាប់ៗគ្នានៃសហគមន៍ខ្មែរ Long Beach បានបើកវគ្គហ្វឹកហ្វឺនបង្ហាត់បង្ហាញប្រជាជនខ្មែរឲ្យយល់ដឹងពីវិធីការពារអាយុជីវិតឲ្យមានសុវត្ថិភាព ពេលមានគ្រោះអាសន្នប៉ះពាល់មកលើខ្លួន ឬតំបន់រស់នៅ ។



អ្នកថតរូបៈ លោក ឯល វ៉ាន់ថា

កាកបាទក្រហមអាមេរិកាំង ARC ប្រចាំក្រុង Long Beach បានផ្តល់នូវសម្ភារៈដែលទាក់ទងទៅនឹងការជួយសង្គ្រោះជីវិត និងផ្តល់ចំណេះអប់រំឲ្យដឹង ក្នុងលក្ខណៈត្រៀមសម្ភារៈសង្គ្រោះ និងសម្ភារៈដំណេក ឬម្ហូបអាហារជាប្រចាំ ដើម្បីទប់ស្កាត់ពេលមានអាសន្នមកដល់ ។

សមាជិកអចិន្ត្រៃយ៍នៃកាកបាទក្រហមអាមេរិក លោក វង្ស ដានី បានប្រាប់ឲ្យដឹងថា ជំនួយសង្គ្រោះរបស់កាកបាទក្រហមចំនួន៤០០កាតាប ដែលក្នុង មួយកាតាបតម្លៃ២៥០ដុល្លារ មាន២៧មុខ ទាក់ទងទៅនឹងសម្ភារៈធានាសុវត្ថិភាពមនុស្សមួយអន្តរកាលនៃគ្រោះអាសន្នមកដល់ ទម្រាំការជួយសង្គ្រោះជា បន្ទាន់ចូលទៅដល់នោះ ត្រូវបានចែកជូនដល់បងប្អូនខ្មែរ ដើម្បីថែរក្សាទុកការពារខ្លួន ។

លោក វង្ស ដានី បញ្ជាក់ថា ការភ័យតក់ស្លុត បានធ្វើឲ្យយើងភ្លេចភ្លាំងស្មារតីនឹកមិនឃើញអ្វីឡើយ នៅពេលមានគ្រោះអាសន្នដូចជា គ្រោះធម្មជាតិ រញ្ជួយផែនដី, ទឹកជំនន់, ភ្លើងឆេះផ្ទះ ។ ដូច្នេះបងប្អូនខ្មែរយើងត្រូវតែមានវិធីការពារ និងទប់ស្កាត់ ហើយអ្វីដែលការពារ និងទប់ស្កាត់ ត្រូវធ្វើយ៉ាងណាចំពោះ ជីវិតគ្រួសារ, សហគមន៍ជីវិតអ្នកដទៃ, ត្រៀមអាហារសំរាប់រស់ ៤-៥ថ្ងៃ ។

អ្នកថតរូបៈ លោក ឯល វ៉ាន់ថា




អ្នកស្រី Chan Hopson ត្រូវបង្ហាត់បង្រៀនវគ្គអប់រំយល់ដឹងពីកិច្ចការជីវិតដោយសុវត្ថិភាព បានបញ្ជាក់ប្រាប់សិក្ខាកាមជាអតីតជនភៀសខ្លួនខ្មែរថា សម្ភារៈដែលយើងរក្សាទុកមាន ៖ ទឹក, ម្ហូបកំប៉ុង, របស់ក្រៀមក្រោះ ឬម្ហូបដែលមិនផ្អូមរលួយ មិនចាំបាច់ប្រើទូរទឹកកក ដែលត្រូវផ្លាស់ប្តូរ៦ខែម្តងៗ ៖ Radio (វិទ្យុ) ដែលជារបស់ស្តាប់ព័ត៌មានផង និងជួយបំភ្លឺភ្លើងឲ្យយើងមើលឃើញអ្វីៗមួយរយៈកាលខ្លី, កញ្ចែផ្លុំ, Tape (បង់) សំរាប់រុំ ឬអបខ្លួនប្រាណ ពេលមាន របួសស្នាម, សម្លៀកបំពាក់ខោ-អាវវែង ស្បែកជើងឃ្លុប, សម្ភារៈសំអាតខ្លួនផ្នែកអនាម័យ, ស្រោមដៃសំរាប់ការពារប៉ះពាល់វត្ថុមុតរឹងៗ ។

ផែនទីសំរាប់ការបង្ហាញផ្លូវដើម្បីរំដោះខ្លួនចេញពីគ្រោះអាសន្ន, សម្ភារៈដំណេក, ថ្នាំសង្កូវដើម្បីព្យាបាលខ្លួនមួយអន្តរកាលខ្លី, ថវិកាជាលុយរាយ ឬ កាក់ ងាយស្រួលទិញដូរ ឬដាក់ហៅទូរស័ព្ទ និងសំណុំឯកសារនៃការរស់នៅ មាន Green Card, I.D Card, Driver License សំបុត្រកំណើត I-94 និង អាស័យដ្ឋានត្រឹមត្រូវ ឬទូរស័ព្ទ ដើម្បីងាយស្រួល ទំនាក់ទំនងក្នុងការជួយសង្គ្រោះ និងស្វែងរកញាតិសន្តាននៅពេលព្រាត់ប្រាសគ្នា ។

វគ្គហ្វឹកហ្វឺនពីវិធីការពារសុវត្ថិភាពអាយុជីវិតមនុស្ស-សត្វ ដែលរៀបចំឡើងដោយកាកបាទក្រហមអាមេរិកាំង ប្រចាំ Long Beach បានធ្វើឡើងជាប់ៗ គ្នា ៦ វគ្គ ដែលមួយវគ្គៗមានពេល១ព្រឹក ឬ ១ល្ងាច មានបងប្អូនខ្មែរចូលរួមមិនលើសពី១០០នាក់នោះ ៕

# ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ កាន់តែស្ថិតនៅឆ្ងាយពីឆាកនយោបាយ ?



**ទ្រង់នរោត្តម រណឫទ្ធិ និង លោក ហ៊ុន សែន**

ដំណើរវិវឌ្ឍន៍នៃជីវភាពនយោបាយ របស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះរាជបុត្រសម្តេចព្រះ នរោត្តម សីហនុ ដែលបាន តាំងខ្លួនឯងថា ជាអ្នកប្រកាន់របបរាជានិយមធំជាងគេតែមួយនៅកម្ពុជា ហាក់កាន់តែឃ្លាតឆ្ងាយបន្តិចម្តងៗពីគណបក្សពីអ្នកគាំទ្រព្រះអង្គ និងពីការងារនយោបាយរបស់ប្រទេសកម្ពុជា។

ប៉ុន្តែបើទោះជាយ៉ាងណា ក្នុងស្ថានភាពកាន់តែយ៉ាប់ទៅៗក៏ដោយ មន្ត្រីហែហមព្រះអង្គនៅតែមានជំនឿថា ទ្រង់នឹងអាចយាងមកចូលរួមការបោះឆ្នោតជាតិខែកក្កដា ឆ្នាំ២០០៨ ដោយមានអន្តរជាតិជួយគាំទ្រដែរ។

បញ្ហាព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលកាន់តែឃ្លាតឆ្ងាយពីបញ្ហាកម្ពុជានេះ ត្រូវបានក្រុមអ្នកវិភាគឯករាជ្យមើលឃើញថា មិនមែនមកពីគណបក្សហ្វ៊ុនស៊ិនប៉ិច ឬ មកពីលោក ញ៉ឹក ប៊ុនឆៃ , លោក លឺ ឡាយស្រេង ឬ ក៏អ្នកនយោបាយរាជានិយមណាម្នាក់ទេ តែសំខាន់នោះ គឺដៃគូសម្ព័ន្ធភាពនយោបាយរបស់ទ្រង់ គឺលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ អនុប្រធានគណបក្សដ៏មានអំណាចទេ ដែលអាចនឹងបញ្ចប់ជីវភាពនយោបាយ និងបានផាត់ទ្រង់ឲ្យនៅក្រៅសង្វៀននយោបាយកម្ពុជា។

នៅថ្ងៃទី ៩ កញ្ញា លោក ហ៊ុន សែន បានបញ្ជាក់ជាថ្មីអំពីការបិទទ្វារថា ប៉ុន្មានថ្ងៃមុនមានអ្នកចង់ទាក់ទងលោក តាមរយៈរដ្ឋមន្ត្រីក្រសួងព័ត៌មាន ប៉ុន្តែលោកបានបដិសេធពីព្រោះអ្នកនោះនិយាយសង្ខាណាស់តាមវិទ្យុ VOA និង RFA ។ លោកថា "បើខ្លាំងមិនបាច់មក រក ហ៊ុន សែន ទេ ខ្ញុំនិយាយតាមមួយបែបដូចឆ្នាំ២០០៣។ ពិភាគពេកសណ្តោងរ៉ឺម៉ក ២-៣ បើទៀងឡេនដោះកួយមិនអស់ ហើយមកឲ្យ ហ៊ុន សែន ជួយដោះ! អត់ដោះទេ! ចង់ទៅជាអីក៏ទៅចុះ ចង់ព្រាត់ប្រាស់ទៅណាក៏ទៅចុះ។ មនុស្សរវល់រកពេលទំនេរគ្មាន....បើបានទាក់ ទងបន្តិចតាំងយកទៅឃោសនា ឥឡូវសូម្បីសំបុត្រ ឬ ហ្វាក់ ខ្ជិលមើលបញ្ជូនទៅវិញ"។ លោកបញ្ជាក់ថា លោកបានផ្តាំឲ្យ រដ្ឋមន្ត្រីក្រសួង ព័ត៌មាន លោក ខៀវ កញ្ញារីទ្ធ ឈប់ទាក់ទង។

មន្ត្រីនាំពាក្យគណបក្សប្រជាជន លោក ខៀវ កញ្ញារីទ្ធ បានប្រាប់កាសែតក្នុងស្រុកកាលពីថ្ងៃទី ៦ តុលា ថា លោក ហ៊ុន សែន បាន បិទទ្វារជាមួយសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ពី

(តទៅទំព័រទី ១០)

# ការជជែកពីករណីសម្តេចព្រះនរោត្តម សីហនុ ទាក់ទិននឹងខ្មែរក្រហមមិនទាន់បញ្ចប់


សី ហនុ ក្នុងអតីតប្រមុខរដ្ឋសម័យខ្មែរក្រហម

វាជារឿងក្តៅគគុកមួយ ក្នុងការដែលឥស្សរជនខ្មែរក្នុងសង្គមស៊ីវិល បានទាមទារឲ្យមានការដកអភ័យឯកសិទ្ធិ ដែលផ្តល់ដោយច្បាប់ថ្វាយសម្តេចព្រះ នរោត្តម សីហនុ អតីតព្រះមហាក្សត្រ ព្រះរាជាណាចក្រកម្ពុជា ដើម្បីបើកផ្លូវឲ្យតុលាការកាត់ទោសពួកមេដឹកនាំ ខ្មែរក្រហម អាចសាកសួរព្រះអង្គ អំពីការដែលទ្រង់ធ្លាប់កាន់តួនាទីជាប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យមួយរយៈខ្លីនោះ បានធ្វើឲ្យមានប្រតិកម្មទប់ស្កាត់ និងការពារព្រះអង្គពីប្រមុខរដ្ឋាភិបាលខ្មែរ លោក ហ៊ុន សែន ហើយការនេះបាននាំឲ្យមានការជជែក នៅក្នុងគ្រប់មជ្ឈដ្ឋានជនកម្ពុជា ក្នុងន័យ រកឲ្យឃើញថា តើវាជារឿងគួរ ឬមិនគួរនឹងធ្វើដូច្នេះ?

ការជជែកអំពីការដែលថា សម្តេចព្រះនរោត្តម សីហនុ ព្រះអង្គគប្បីត្រូវធ្វើជាសាក្សីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាស្តីពីការកាត់ទោសពួកខ្មែរក្រហម ឬយ៉ាងណា? ធ្វើឲ្យអ្នកនយោបាយអ្នករកស៊ី ពិសេសអ្នកចូលនិវត្តន៍ដែលនិយមធ្វើនយោបាយ តាមតុកាហ្វេ លើកជាប្រធានបទពិភាក្សាមិនទាន់ចប់នៅឡើយ ហើយក៏នៅតែមិនដាច់ស្រេចថាភាគច្រើនចាប់យកខាងណាដែរ តែយ៉ាងណាព្រះអង្គនៅតែ ទទួលបានការគោរពច្រើនពីសំណាក់ប្រជារាស្ត្រព្រះអង្គ ដែលមានវ័យចំណាស់។

វាមានមតិពីរដែលគេគិតជជែកសព្វថ្ងៃ ។ តែជាផ្លូវការគ្មានអ្នកណាម្នាក់ ហ៊ាននិយាយចេញមុខទាក់ទិនដល់ អតីតក្សត្រខ្មែរអង្គនេះទេ ដោយសារច្បាប់រដ្ឋធម្មនុញ្ញ បានហាមប្រាមណាមួយគេក៏គិតថា ព្រះអង្គមានព្រះជន្មច្រើនណាស់ហើយ គួរទុកឲ្យព្រះអង្គមានសេចក្តីសុខខាង ផ្លូវអារម្មណ៍ក្នុងព្រះជន្មចុងក្រោយនេះផងទៅ!។ តែមតិមួយទៀត គេនៅតែការពារស្លោកលេងសើចដដែលថា "ធ្វើជ្រូកកុំវាទឹកក្តៅ "បើ ព្រះអង្គពិតជាស្អាតស្អំ និងបូជាអ្វីៗដើម្បីជាតិ ក្នុងព្រះជន្មព្រះអង្គមែន តើព្រះអង្គខ្លាចអីនឹងឡើងតុលាការ ?

លោក កាន់ រិះ ប្រធានគណបក្សអំណាចប្រជាពលរដ្ឋ ដែលមិនទាន់បានសាកល្បងលើសង្វៀនដណ្តើមកៅអីសភានៅឡើយ បានបង្ហាញទស្សនៈ គណបក្សលោកជាមួយនឹងខ្មែរប៉ុស្តិ៍ថា លោកមិនគាំទ្រគំនិតជំរុញឲ្យរដ្ឋសភាដកអភ័យឯកសិទ្ធិពីសម្តេច សីហនុ ទេ តែថាបើ ទ្រង់មានភាពបរិសុទ្ធមែន ព្រះអង្គគួរគប្បីលះបង់អភ័យឯកសិទ្ធិនេះក៏ជាការល្អដែរ។ លោកថា ច្បាប់ហាមមិនឲ្យមានការបំពារបំពានដល់ អតីតព្រះមហាក្សត្រមែន ប៉ុន្តែមធ្យោបាយតែមួយ ក្នុងការជួយឲ្យមានការស្ងប់ចិត្តពីសំណាក់ជនរងគ្រោះ និងសាច់ញាតិគេដែលសេសសល់ពី ស្លាប់ក្នុងរបបនេះ គឺមានតែព្រះមហាវរក្សត្រ ព្រះអង្គលះបង់អភ័យឯកសិទ្ធិដោយព្រះអង្គឯង។

ពីមុនមកព្រះនរោត្តម សីហនុ ធ្លាប់មានបន្ទូលប្រាប់កាសែតបរទេសថា ព្រះអង្គនឹងមិនរុញរានឹងការបំភ្លឺដល់តុលាការ ស្តីអំពីតួនាទីដែល គ្មានអំណាច កាលព្រះអង្គនៅជាប្រធានកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) មួយរយៈខ្លីនោះទេ នេះប្រសិនជាតុលាការចាំបាច់ចង់ឲ្យព្រះអង្គ បំភ្លឺ បើទោះបីជាព្រះអង្គមិនបានជាប់ទាក់ទិននឹងអំពើឧក្រិដ្ឋ និងជាជនរងគ្រោះម្នាក់ក្នុងរបបព្រៃផ្សៃនេះក៏ដោយ។

មុនពេលដែលមានការ ចោទប្រកាន់ពីតុលាការខ្មែរក្រហម ទៅលើជនជាប់ចោទដែលគេបង្ហើបឲ្យដឹងថាអាចមាន ៥ រូប កាលពីមុនការ ចាប់ខ្លួន នួន ជា បងធំទី២នោះ និងនៅពេលដែលមានការទាមទារថា ព្រះអង្គជាមេដឹកនាំខ្ពស់បំផុតមួយដែរ គួរតែមកបំភ្លឺដល់តុលាការ កូនកាត់ចំរុះសាសន៍នេះ សម្តេចព្រះនរោត្តម សីហនុ បានដាក់កាលកំណត់បែបប្រយោលមួយ តាមរយៈសារព័ត៌មានឲ្យមន្ត្រីតុលាការនេះចូល គាល់ព្រះអង្គមុនថ្ងៃ ៨ កញ្ញា ២០០៧ ហើយបើហួសគំហិតនេះ តទៅមុខព្រះអង្គនឹងមិនអនុញ្ញាត និងនិយាយពីរឿងខ្មែរក្រហមនេះទៀត ឡើយ ។ ប៉ុន្តែការអញ្ជើញបែបនេះ ត្រូវមន្ត្រីតុលាការចាត់ថា មិនផ្លូវការហើយមិនបានធ្វើតាម ព្រះរាជបំណង ទ្រង់ឡើយ។

លោកបណ្ឌិត ឡៅ ម៉ុងហៃ បានផ្តើមទម្លាយឲ្យមានបញ្ហាក្តៅ ដល់ក្នុងព្រះរាជវាំងខ្មែរកាន់តែខ្លាំង ខណៈដែលវាំងកំពុងតែស្ងប់ស្ងាត់ក្នុងមួយរយៈចុងក្រោយនេះ ក្នុងអត្ថបទមួយកាលពីក្នុងខែកញ្ញា ហើយអតីតព្រះមហាក្សត្រសម្តេចព្រះនរោត្តម សីហនុ ក៏ព្រះអង្គមានការស្រពន់ព្រះទ័យខ្លាំងណាស់ដែរ នឹងការដាក់ព្រះអង្គជាមូលបទ ទាក់ទិនក្នុងតុលាការកាត់ទោសពួកខ្មែរក្រហម រហូតទ្រង់បានបញ្ឈប់ឲ្យមានការ ចូលគាល់ព្រះអង្គពីសំណាក់ភ្ញៀវជាតិ និងអន្តរជាតិ ។


ឡៅ ម៉ុងហៃ

ជាមួយនឹង អត្ថបទលោក ឡៅ ម៉ុងហៃ ជាមន្ត្រីស្រាវជ្រាវ នៃគណៈកម្មាធិការសិទ្ធិមនុស្សអាស៊ី មាន មូលដ្ឋាននៅហុងកុងដែល ទាមទារ ឲ្យរដ្ឋសភាដកអភ័យឯកសិទ្ធិពីសម្តេចព្រះនរោត្តម សីហនុ ប្រធានអង្គការពង្រឹងវិស័យច្បាប់ ដើម្បីការពារសិទ្ធិមនុស្សបណ្ឌិត ហ៊ាង រិទ្ធី បានការពារអតីតព្រះមហាក្សត្រដោយលើកឡើងថា វាមិនគួរនឹងលើកឡើងបែបនេះទេ ពីព្រោះវាគ្មានមូលដ្ឋានជាទីសំអាង និងអាចជា ទឡ្ហីករណ៍ ហើយបើតាមតាមនីតិវិធីច្បាប់ ធ្វើអ្វីមួយគេគប្បីមានឯកសារភស្តុតាងជាគតិយុត្តិច្បាស់លាស់ជាមុនសិន មិនអាចធ្វើបែបលោក បណ្ឌិត ឡៅ ម៉ុងហៃ បានទេ។

សម្តេចឪដែលគង់នៅឆ្ងាយពីបញ្ហានយោបាយជាតិជាយូរមកនេះ មួយរយៈចុងក្រោយដែលមានព្រះទ័យមិនស្ងប់ ពីព្រោះតែអត្ថបទព័ត៌មាននានានោះបានព្រមានពីលទ្ធភាព ធ្វើការប្តឹងបកទៅលោក ឡៅ ម៉ុងហៃ វិញ។ នៅក្នុងសេចក្តីថ្លែងការណ៍ពីថ្ងៃ ២៨ កញ្ញា សម្តេចព្រះ នរោត្តម សីហនុ បានសរសេរថា "...ប្រាកដហើយមានអ្នកស្អប់ នរោត្តម សីហនុ ដូចជាបណ្ឌិត ឡៅ ម៉ុងហៃ គាត់មានសេរីភាពរិះគន់ខ្ញុំ ដោយពាក្យសំដី និងការសរសេរ ។ តែពួកគេគ្មានសិទ្ធិមួលបង្កាច់ខ្ញុំទេ"។ ព្រះអង្គមានបន្ទូលក្នុងសារដែរថា "ប្រសិនបើគេមួលបង្កាច់ខ្ញុំនោះ ខ្ញុំរក្សាសិទ្ធិធ្វើបណ្តឹងជាផ្លូវការប្រឆាំងពួកគេ នៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា នៅអង្គជំនុំជម្រះជាតិ"។

ជាមួយនឹងបញ្ហាដ៏រសើបនេះ គណបក្សកាន់អំណាចទាំងពីរ គឺបក្សប្រជាជនកម្ពុជា និងហ៊្វុនស៊ិនប៉ិច ថ្កោលទោសចំពោះបំណងណាមួយ ក្នុងការយាងអតីតព្រះមហាក្សត្រទៅ

*(តទៅទំព័រទី ២០)*


**ការិយាល័យមេធាវីខ្មែរ**

**Law Office of Roman P. Mosqueda**


ROMAN P.MOSQUEDA
ATTORNEY AT LAW

**ទទួលរ៉ាប់រងធ្វើសំណុំរឿងចំពោះបងប្អូន :**

- Auto Accident - គ្រោះថ្នាក់រថយន្ត
- Immigration - កិច្ចការអន្តោប្រវេសន៍
- Worker Compensation - គ្រោះថ្នាក់នៅកន្លែងធ្វើការ
- Criminal Cases - ករណីឧក្រិដ្ឋកម្ម
- Bankruptcy - ក្ស័យធន
- Divorce - បណ្តឹងលែងលះ

នាងខ្ញុំ លីនដា ផៅ

ជំនួយការមេធាវី, និយាយភាសាខ្មែរ រង់ចាំជួយបំរើលោកអ្នកនូវរាល់ករណីទាក់ទងផ្នែកច្បាប់ដោយភាពហ្មត់ចត់ និងស្មោះត្រង់ជាមួយមេធាវីល្បីឈ្មោះរូបនេះ ។

**សូមអញ្ជើញដោយក្តីរីករាយ!**

**1045 E. Anaheim Street • Long Beach, CA 90813**
**Bus: (562) 218-8600 • Fax: (562) 218-8300**
**Cell: (562) 761-5277**

(តមកពីទំព័រទី ៨)

ឥឡូវនេះទៅហើយ ដែលការបិទទ្វារនេះ គឺមកតែពីសម្តេចក្រុមព្រះខ្លួនឯងជាអ្នក ដែលបំផ្លាញស្ពានសំរាប់ព្រះអង្គ ទាក់ទងជាមួយលោក ហ៊ុន សែន ដោយព្រះអង្គឯង។ លោក ខៀវ កញ្ញារីទ្ធ បន្តថា ពីពេលនេះទៅគ្មាន ស្ពានថ្មីសំរាប់ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ឆ្លងមករកលោក ហ៊ុន សែន ទៀតទេ។ ស្ពាននេះគឺសំដៅទៅលើការទំនាក់ទំនងរវាងដៃគូ មេដឹកនាំនយោបាយពីររូបនេះ ដែលអាចមានការជួបតាមទូរស័ព្ទ តាមអ៊ីមែល ឫ មានការពិភាក្សាពីតំណាងមន្ត្រីរៀងៗខ្លួន ។ ប៉ុន្តែលោក ខៀវ កញ្ញារីទ្ធ អះអាងថា ច្រកទ្វារនិងស្ពានទាំងនេះ គឺបានបិទទាំងអស់ហើយបិទជាស្ថាពរ។

តែទោះជាយ៉ាងណា សំដីអ្នកនយោបាយ វាមិនមែនជាកិច្ចសន្យាទេ ហើយដំណើរវិវឌ្ឍន៍យ៉ាងសំរាប់អនាគត គឺគ្មានអ្នកស្មានទុក ត្រូវឡើង គិតទាំងអ្នកធ្វើនយោបាយខ្លួនឯងផង។

មន្ត្រីស្និទ្ធនឹងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលស្ថិតក្នុងគំនាបសព្វយ៉ាង ក្នុងការជួយលើកមុខមាត់ចៅហ្វាយនាយក្នុងប្រទេស នៅតែយល់ថា បញ្ហាសម្តេចក្រុមព្រះមិនមែនជាបញ្ហាឯកជនទេ តែជាបញ្ហានយោបាយជាតិដែលអន្តរជាតិ ត្រូវតែគាំទ្រឲ្យព្រះអង្គអាចយាងមកចូលរួមការបោះឆ្នោតជាដាច់ខាត។ ហើយក្រុមមន្ត្រីគណបក្ស នរោត្តម រណឫទ្ធិ នៅតែរំពឹងទុកថា ការនេះនឹងកើតឡើងបានដូច ដែលធ្លាប់បានកើតមានម្តងមកហើយ កាលពីសម័យបោះឆ្នោត ១៩៩៨ ក្រោយពីមានមានរដ្ឋប្រហារថ្ងៃ ៥-៦ កក្កដា ១៩៩៧ ទម្លាក់ទ្រង់ ចេញពីតំណែងនាយករដ្ឋមន្ត្រី១ ដែលកាលណោះតុលាការ បានសំរេចដាក់ទោសដល់អស់ព្រះជន្មផងចំពោះទ្រង់។

អ្នកនាំពាក្យលោក មុត ចន្ថា បានតបជាមួយអ្នកសារព័ត៌មានថា មេដឹកនាំគណបក្សលោកមិនសុំជំនួយពីលោក ហ៊ុន សែន ទេ ហើយផ្លូវសំរាប់ព្រះអង្គក្នុងការយាងនិវត្តន៍ ក៏មិនតាមច្រកលោក ហ៊ុន សែន ដែរ។ លោកថា យើងត្រូវគោរពរដ្ឋធម្មនុញ្ញ និងព្រះមហាក្សត្រ ហើយព្រះមហាក្សត្រ ជាអ្នកប្រទានការលើកលែងទោស មិនមែននាយករដ្ឋមន្ត្រីជាលើកលែងទេ ។ លោក មុត ចន្ថា ថ្លែងថា លោក ហ៊ុន សែន កំពុងប្រើឥទ្ធិពលដាក់គំនាបទៅលើតុលាការអំពីករណីសម្តេចក្រុមព្រះ ខណៈដែលតុលាការមិនទាន់សំរេចនូវការប្តឹងឧទ្ធរណ៍ចុង ក្រោយនៅឡើយ អំពីបទចោទថា ទ្រង់បានរំលោភលើសេចក្តីទុកចិត្តហ្វ៊ុនស៊ិនប៉ិច។

ក្រុមមន្ត្រីសង្គមស៊ីវិល បានប្រមើលដែរថា លទ្ធភាពរបស់សម្តេចក្រុមព្រះ ក្នុងការយាងមកដឹកនាំគណបក្សរបស់ព្រះអង្គ នៅតែមាននៅឡើយទេ គ្រាន់តែច្រកនោះរួមតូច ហើយបើទោះជាព្រះអង្គយាងមក ក៏គ្មានតម្លៃខាងនយោបាយសំរាប់ព្រះអង្គម្ចាស់ទៀតដែរ។

មុននេះក្រុមមន្ត្រីស្និទ្ធនឹងព្រះអង្គ មានលោក មុត ចន្ថា, លោក យូ ហុកគ្រី បានប្រឹងរកមេធាវីដើម្បីទៅតតាំងក្តីជាមួយនឹងការ ប្តឹងពីគណបក្សហ្វ៊ុនស៊ិនប៉ិច ទាក់ទិននឹងករណីក្បត់សេចក្តីទុកចិត្ត ខណៈដែលទ្រង់បានយកដីទីតាំងគណបក្សថ្មីដាក់ឈ្មោះផ្ទាល់ព្រះអង្គ កាលនៅជាប្រធានហ្វ៊ុនស៊ិនប៉ិច នៅសាលាឧទ្ធរណ៍ ប៉ុន្តែជាលទ្ធផល គឺចៅក្រមសាលាឧទ្ធរណ៍បានតម្កល់សាលដីកាសាលាដំបូងភ្នំពេញ ឲ្យនៅដដែល គឺព្រះអង្គត្រូវជាប់គុក១៨ ខែ និងសងជំងឺចិត្តលោក ញ៉ឹក ប៊ុនឆៃ ថែមទៀត។

ចាប់តាំងពីមានរឿងរ៉ាវផ្ទាល់ព្រះអង្គ ក្នុងក្រុមគ្រួសារ និងការដែលទ្រង់បានលះបង់តួនាទីពីប្រធានរដ្ឋសភាមក ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ក៏បានយាងចេញទៅក្រៅប្រទេស ហើយតមកក្នុងខែតុលា ២០០៦ គណបក្សហ្វ៊ុនស៊ិនប៉ិច ដឹកនាំបើកសមាជ ដោយលោក ញ៉ឹក ប៊ុនឆៃ បានទម្លាក់ព្រះអង្គពីប្រធានបក្សមានអំណាច ឲ្យមកជាប្រធានកិត្តិយសបក្សជាប្រវត្តិសាស្ត្រវិញ។ រួចហើយក៏មានករណីប្តឹង ផ្តល់ពីព្រះជ័យាព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី រណឫទ្ធិ និងការប្តឹងពីហ្វ៊ុនស៊ិនប៉ិច ជុំវិញការលក់ដីស្នាក់ការជិតគល់ស្ពានជ្រោយចង្វា។ ចាប់ពីនោះមកព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានគង់នៅនិរទេសពីមាតុភូមិរហូតដល់សព្វថ្ងៃ ហើយក្រុមមន្ត្រីទ្រង់បាននឹងកំពុងព្យាយាម រកច្រកថ្វាយទ្រង់ ក្នុងការយាងវិលមកដឹកនាំគណបក្ស ដើម្បីចូលរួមការបោះឆ្នោតជាតិឆ្នាំ ២០០៨ ។

ធ្លាក់ក្នុងសភាពបែបនេះក៏ដោយ មេដឹកនាំគណបក្សហ្វ៊ុនស៊ិនប៉ិច ហាក់នៅតែមានសមានចិត្ត និងអតីតមេដឹកនាំប្រវត្តិសាស្ត្របក្ស នេះដែរ ទាំងប្រធានគណបក្សថ្មី លោក កែវ ពុទ្ធ រស្មី ទាំងអគ្គលេខាធិការបក្សលោក ញ៉ឹក ប៊ុនឆៃ គឺសុទ្ធតែបង្ហាញពីច្រកទ្វារ ថ្វាយព្រះអង្គ ម្ចាស់ រណឫទ្ធិ គឺការចូលតាមផ្លូវហ្វ៊ុនស៊ិនប៉ិច នេះតែមួយគត់។ ហើយលទ្ធភាពដែលលើកឡើងថ្វាយនោះ គឺអាចជាប្រធានបក្សដដែល អាចមកជាបេក្ខជន នាយករដ្ឋមន្ត្រីអាណត្តិថ្មី ប៉ុន្តែខាងហ្វ៊ុនស៊ិនប៉ិចបានសុំមកវិញនូវការទទួលស្គាល់សមាជថ្ងៃ ១៨ តុលា និងការប្រគល់ប្រាក់ ៦ លានដុល្លារ ពីការដោះដូរដីស្នាក់ការបក្ស ជាថ្នូរនឹងការដកពាក្យបណ្តឹងនៅតុលាការ។

តាមលោក មុត ចន្ថា មន្ត្រីនាំពាក្យគណបក្ស នរោត្តម រណឫទ្ធិ បានអះអាងថា សម្តេចក្រុមព្រះនឹងមិនប្តូរជំហរ ហើយទទួលយក គណបក្សហ្វ៊ុនស៊ិនប៉ិចវិញទេ ហើយថា ក្នុងកាលៈទេសៈណាក៏ដោយ ក៏សម្តេចក្រុមព្រះមិនប្តូរជំហរនេះដែរ។ លោកថា ការសន្យាណាមួយរបស់មន្ត្រីក្បត់ហ្វ៊ុនស៊ិនប៉ិច គឺមិនគួរឲ្យទុកចិត្តបានឡើយ។

លោក យូ ហុកគ្រី អគ្គលេខាធិការគណបក្ស នរោត្តម រណឫទ្ធិ បានបង្ហាញជំហរអំពីការបិទច្រក សំរាប់ប្រធានបក្សលោកថា ការបើកច្រកដែលបិទនោះ វាស្ថិតលើការលើកលែងទោសដល់សម្តេចក្រុមព្រះ ។ លោកថា កន្លងមកក៏ធ្លាប់ថាបិទច្រកអ៊ីចឹងដែរ តែនៅតែបើកបានដដែល ហើយបើទោះជាបាត់កូនសោរ ក៏គេអាចធ្វើកូនថ្មីបានដូចគ្នា ។

មន្ត្រីគណបក្សប្រឆាំង សម រង្ស៊ី មិនឲ្យចេញឈ្មោះយល់ថា ព្រះអង្គម្ចាស់ រណឫទ្ធិ បើសិនយាងមកតាមច្រកហ្វ៊ុនស៊ិនប៉ិចក៏ដោយ ឬតាមការចរចាណាមួយជាមួយនិងលោក ហ៊ុន សែន ក្តី គឺព្រះអង្គនឹងគ្មានឯករាជ្យភាពនយោបាយផ្ទាល់ឡើយ ហើយនិងជាអ្នក នយោបាយដែលធ្វើតែតាមខ្សែញាក់គេប៉ុណ្ណោះ។ ណាមួយការដាក់លក្ខខណ្ឌ ឲ្យព្រះអង្គម្ចាស់សងប្រាក់៦លានដុល្លារ ទៅហ្វ៊ុនស៊ិនប៉ិចនោះ គឺរិតតែមិនអាចទេ ។ មន្ត្រីរូបនេះនិយាយថា ការសំរេចព្រះទ័យដោយឯករាជ្យ វាជាជំរើសមួយដែលមានភាពថ្លៃថ្នូរក្នុងជីវិតនយោបាយ របស់ព្រះអង្គ ។

សួរថា តើការស្ថិតនៅក្រៅប្រទេស នាំឲ្យមានការបាត់បង់ប្រជាធិបតេយ្យពីក្នុងការបោះឆ្នោត ២០០៨ ឫយ៉ាងណា? មន្ត្រីបក្ស ប្រឆាំង និយាយថា វាមិនអាចទេ ពីព្រោះថា នៅមានគណបក្សច្រើនទៀតកំពុងធ្វើសកម្មភាព ថ្វីបើគណបក្សកាន់អំណាច មិនសម្រួលឲ្យបានទូលំទូលាយក៏ដោយ។ ណាមួយទៀតគណបក្សនេះ ក៏មានសកម្មភាពដែរ គឺលើកលែងតែទ្រង់មួយអង្គឯង ដែលមានរឿងនៅតុលាការដែលវាជាករណីបុគ្គល មិននាំឲ្យរាំងស្ទះដល់ដំណើរការបោះឆ្នោតឡើយ បើទោះជាពេលបច្ចុប្បន្ននេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លំអៀងទៅបក្សកាន់អំណាច ក៏ដោយ។

ទាក់ទិននឹងការដឹកនាំដែលអត់ប្រធាន នៅចាត់ការផ្ទាល់ លោកអគ្គលេខាធិការ យូ ហុកគ្រី អះអាងថា ទម្ងន់នៃការសំរេចកិច្ចការ នានាក្នុងបក្ស ថ្វីបើមានអគ្គលេខាធិការ មានអគ្គរង៧រូប មានអនុប្រធាន និងអគ្គធិការក៏ដោយ ក៏ក្រុមការងារអចិន្ត្រៃយ៍គណបក្សមិន ដែលរំលង និងត្រូវតែសុំការយល់ព្រមពីសម្តេចក្រុមព្រះជានិច្ចដែរ។/



កុំរំពឹងរកភាពបន្សល់ទុកពីអ្នកនយោបាយខ្មែរ ព្រោះតែលោភលន់និងអំណាច!

ពីសំរែកជនជាតិខ្មែរ


LENG
BEAUTY SALON

ហាងកាត់សក់-សំអាងការ
2224 E. ANAHEIM STREET • LONG BEACH, CA 90804
(562) 434-9621 • (562) 869-1912
មានជាងចំណាន១ដែលមានការពិសោធន៍ជាច្រើនឆ្នាំជាមួយជំនាញកាត់សក់, អ៊ុតសក់ សម្រាប់មនុស្សគ្រប់វ័យ បុរស-ស្ត្រី ។
ហាងយើងខ្ញុំក៏មានទទួលតែងការក្នុងពិធីរៀបអាពាហ៍ពិពាហ៍តាមម៉ូតស៊ីវិល័យទាន់សម័យនិយម ឬបែបប្រពៃណីបូរាណ ។
-ទទួលសាក់ចិញ្ចើម និងគូរភ្នែក
សូមអញ្ជើញ ដោយមេត្រីភាព!
ហាងយើងខ្ញុំត្រូវការរកជាងសាបក្រចកម្នាក់ និងរកជាងអ៊ុតសក់ម្នាក់ !



# VISUAL JUSTICE – Media and the Khmer Rouge Tribunal

Written by Khmer Post: Tiara Delgado

**Part 2 – Media coverage inside the People's Revolutionary Tribunal**

After the genocide, along with urgent necessities such as food, sanitation and medicine, Cambodians had another top priority: prosecuting those responsible for the bloodbath. The world's first genocide tribunal was the People's Revolutionary Tribunal held in Phnom Penh in August 1979. The tribunal charged Pol Pot and one of his top henchmen Ieng Sary with the crime of genocide. (At the 1948 Nuremberg Trials in Germany, Nazi leaders were not charged for the crime of genocide.) Some critics called the People's Revolutionary Tribunal a "show trial". But in the immediate aftermath of genocide it is quite amazing there was any sort of trial at all! Twenty-nine foreign journalists were invited to attend. Foreign judges from Algeria, Cuba, India, Japan, Laos and the USSR were invited to participate. The defense and prosecution each included one American lawyer. The legal system contained elements derived from the French legal system (such as in absentia trials) that had been established in Cambodia during French colonialism. Although the trial included much international participation, it was not of interest to the international press. However domestic media coverage was plentiful. Court proceedings were broadcast by loudspeakers set up around the Chatamouk Theatre, where the trial was held. The Voice of Kampuchea Radio broadcast live proceedings. The Kampuchea newspaper (published weekly) dedicated a full issue to transcripts and photos from the trial. Two Cambodian judges and ten peoples assessors participated in the tribunal. Thirty-nine witnesses gave sworn testimony. In the aftermath of genocide there was no shortage of evidence of the atrocities committed. The prosecution arranged the judges to visit mass-grave sites such at Choueng Ek where over 10,000 bodies lay decomposing. The judges were also brought to Toul Sleng, a prison used by the Khmer Rouge for torture and interrogation. Toul Sleng had been made into a museum with photos of the victims and detailed documentation kept by the Khmer Rouge. The People's Revolutionary Tribunal found Pol Pot and Ieng Sary were found guilty and the sentence imposed was death. Verdicts from the genocide tribunal were sent to the United Nations. However nobody took action to capture the convicted Khmer Rouge leaders. Why was the world's first genocide tribunal not bombarded with international attention? Why did the US lack interest in this trial? In fact, the UN and Western world completely turned its back on Cambodia. Western nations refused to recognize Cambodia's new Vietnamese-backed People's Republic of Kampuchea government. The UN called for the "unconditional and immediate withdrawal of Vietnamese forces from Cambodia……………………"



THE PLAYERS

The US led a world- wide trade embargo against Cambodia for over a decade. Adding insult to injury, the United Nations Credentials Committee allowed the Khmer Rouge to keep its seat in the General Assembly. International isolation was an attempt to punish Vietnam but actually caused great suffering for Khmer people. Unfortunately, politics seemed more important than justice. It would be a generation – almost thirty years – until an internationally recognized tribunal would be seen……………………………………

**NEXT ISSUE – Part 3 - Media preserving history**

សូស្តីប្រិយមិត្តអ្នកអាន! បើលោកអ្នកមានចម្ងល់ ឬការតិះទៀននិងមានយោបល់ផ្សេងៗ សូមទាក់ទងយើងខ្ញុំតាមរយៈ:
ទូរស័ព្ទ (562) 591-4902
Sovannara@ThekhmerPost.com




ការិយាល័យបំរើផ្នែកច្បាប់
Samuel Lim & Associates
A Professional Representation
17094 Magnolia St. Mountain Valley, CA 92708
Office: 714-596-8878• Fax: 714-847-4449• Cell: 714-747-7989











បំរើអស់លោក~ លោកស្រី ៖
- ដីធ្លី- គេហដ្ឋានៈ លក់-ទិញ ចូលរួមវិនិយោគទុននិងធ្វើអភិវឌ្ឍន៍
- អន្តោប្រវេសន៍៖ ធានាគ្រួសារ សុំចូលសញ្ជាតិ និងការពារការបណ្តេញទៅស្រុកកំណើត ។
- រដ្ឋបាលសន្តិសុខសង្គម និងការិយាល័យផ្នែកសំរេចពីពិការភាពនិងពិនិត្យឡើងវិញ៖ សុំប្រាក់សង្គមកិច្ច ប្រាក់ពិការ ធ្វើសាវនាការសុំប្រាក់ពេទ្យរដ្ឋកាលីហ្វ័រនីញ៉ា និងការសុំប្រាក់ពេទ្យសំរាប់ជនជរាពិការ ។
-គ្រោះថ្នាក់និងរងរបួសធ្ងន់ធ្ងរ ៖ មេធាវីយើងអាចតំណាងលោកអ្នក ជាមួយបទពិសោធន៍ជាង១៥ឆ្នាំ ។
- Social Security disability and SSI benefit
- Medical & Medicare Hearing
- Immigration Services
- Court Translation Agency and Referral
-ការិយាល័យយើងខ្ញុំក៏មានកន្លែងពិនិត្យភ្នែក និងកាត់កញ្ចក់វ៉ែនតាដែលមានវេជ្ជបណ្ឌិត JUE. L. LIM
• Complete Eyes exam • Contact Lenses fitting • Fashion Eyewear • Treatment & Management of Eyes diseases.

# ទិដ្ឋភាពថ្ងៃភ្ជុំបិណ្ឌនៃសហគមន៍ខ្មែរឡុងប៊ិច



ព្រះចៅអធិការវត្ត ពោធិ៍ព្រឹក្សារាម ធម្មប្បញ្ញោ នួនបុណ្ណារិទ្ធិ

ថ្ងៃសីល១៥រោច ខែភទ្របទ ព.ស២៥៥១ ត្រូវនឹងថ្ងៃទី១១ ខែតុលា មនុស្សម្នាជាពុទ្ធសាសនិកជនបាននាំចង្ហាន់ទៅប្រគេន ព្រះសង្ឃ និងឧទ្ទិសកុសលសែន ព្រេនរំលឹកវិញ្ញាណក្ខ័ន្ធចំពោះញាតិសន្តាន ដែលបានចែកឋានទៅកាន់បរលោកដើម្បីឲ្យបានក្តីសុខ ទៅកាន់សួគ៌ា វៀរចាកការទៅកើតនរកប្រេត ។ អ្នកស្រុកខ្មែរយើង នៅតំបន់នានាជុំវិញទីវត្តអារាមខ្មែរចំនួន១០ បើទោះបីរវល់រវៃក្សុង ជាមួយការងារយ៉ាងមមាញឹកក៏ដោយ ពួកគេឆ្លៀតពេលវេលាក្នុងនាមជា អ្នកកាន់ព្រះពុទ្ធសាសនា ទៅកាន់វត្តអារាម ដើម្បីគោរពប្រតិបត្តិធ្វើបុណ្យដាក់ទាន ទៅតាមទំនៀមទម្លាប់ខ្មែរ ។ ទីវត្តអារាម គឺជាទីណាត់ជួបគ្នាដ៏កម្រនៃបងប្អូនខ្មែរយ៉ាងអធឹកអធម គឺមាន តែពេលបុណ្យទានធំៗប៉ុណ្ណោះ មានបុណ្យចូលឆ្នាំ ភ្ជុំបិណ្ឌ ក្រៅពីនោះពួកគេកម្រណាស់ ព្រោះរស់ឆ្ងាយៗពីគ្នា និងរវល់ពីដំណោះស្រាយក្រពះជាប្រចាំថ្ងៃ ដែលយើងជា អតីតជនភៀសខ្លួនរស់នៅលើទឹកដីគេ ចាំបាច់ត្រូវតែប្រឹងដើម្បីរស់នៅ ។

ទិដ្ឋភាពនាថ្ងៃនោះ ចាស់ៗមិនថាប្រុសស្រី នាំគ្នាស្តាប់ធម៌ ឬការទេសនា និងថ្វាយបង្គំព្រះ ជាមួយការជជែកគ្នាបែកអូរហូរជាស្នឹង ពីការរលឹកគ្នាទៅវិញទៅមក ពីអតីតកាលដែលវ័យបច្ចុប្បន្នកំពុងតែនាំខ្លួនពួកគាត់ទៅមុខ ជានិច្ចនោះ ។ រីឯអ្នកខ្លះទៀតបន្ទាប់ពីប្រគេនចង្ហាន់ព្រះសង្ឃ ឬរាប់បាត្ររួច ពួកគេនាំគ្នាជជែកពីស្រុក ទេសកំណើតអាណិតអាសូរប្រជាជនខ្មែរក្រីក្រ និងស្ថានការនយោបាយកម្ពុជាឆ្ពោះទៅរកការបោះឆ្នោត ដោយពួកគេលើកដៃបន់ស្រន់សំពះព្រះសុំឲ្យមានសេចក្តីសុខ ដល់ជាតិខ្មែរកុំឲ្យមានអំពើហិង្សាកើតមានសម្លាប់ខ្មែរអំឡុងពេលបោះឆ្នោតម្តងៗ ។ ចំណែកក្រុមក្មេងយុវជនដែលធំដឹងក្តី ឬកើតនៅទីនោះ (ស.រ.អា) ពួកគេហាក់ មិនដឹងឬ ក៏យល់មិនបានជ្រួលជ្រាបពីប្រពៃណីខ្មែរ ពិសេសបុណ្យ បាប តាមទ្រឹស្តីព្រះពុទ្ធនោះ ។ ពួកគេទៅតាមឪពុកម្តាយដើម្បីសប្បាយជួបជុំមិត្តភ័ក្តិបងប្អូន នាំគ្នាលេង ឬជជែកទៅតាមចំណង់ខ្លួននូវអ្វីដែលជាសិទ្ធិសេរីភាព ។ ហើយក៏មានអ្នកខ្លះក៏បានប្រតិបត្តិយល់ដឹងចេះលើកដៃសំពះ ព្រះសង្ឃ ថ្វាយបង្គំព្រះដើម្បីសុំសេចក្តីសុខ ទៅតាមការប្រាប់ពីឪពុកម្តាយពួកគេផងដែរ ។ ដែលករណីនេះយ៉ាងហោចណាស់ ពួកគេក៏អាចបានដឹងនូវសីលធម៌នៃការគោរពពីវ័យក្មេង ឬចាស់ ដើម្បីរងាប់នូវអំពើ ហិង្សាផ្លូវចិត្តតាំងពីក្មេងទៅ នឹងរៀនយល់ដឹងពីតម្លៃវប្បធម៌ប្រពៃណី ជាតិខ្មែរឲ្យជ្រួលជ្រាបជាបណ្តើរៗទៀតផង។ ខាងក្រោមនេះកាសែតខ្មែរប៉ុស្តិ៍ សូមលើកយកមកនូវកិច្ចសម្ភាសន៍ជាមួយ ពួកបណ្ឌិតពុទ្ធសាសនាជុំវិញអត្ថន័យ ដែលតំណពីបុរាណកាលមកឲ្យមាននូវបុណ្យ បុណ្យភ្ជុំបិណ្ឌ ។ ថាតើបុណ្យដ៏ធំប្រពៃណីខ្មែរ មួយនេះមានសារសំខាន់ដល់កំរិតណា ក្នុងជីវិតយើងរស់នៅជាអ្នកកាន់ផ្លូវព្រះពុទ្ធសាសនា ។/










## បទសម្ភាសន៍ មៀច ប៉ុណ្ណ ប្រេតក្នុងរដូវបុណ្យភ្ជុំបិណ្ឌ

ក្រៅពីបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌជាបុណ្យមានទ្រង់ទ្រាយធំជាងគេរបស់ ជនជាតិខ្មែរ ។ បុណ្យនេះ ត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី១៥រោជ ខែភទ្របទ បន្ទាប់ពីបុណ្យកាន់បិណ្ឌចំនួន១៤ថ្ងៃនោះមក ។ បុណ្យភ្ជុំបិណ្ឌជាបុណ្យប្រពៃណីផង និងជាបុណ្យសាសនាផង ។ នៅក្នុងថ្ងៃបុណ្យភ្ជុំបិណ្ឌ គ្រប់វត្តអារាមសឹងពោរពេញទៅដោយពុទ្ធបរិស័ទ ប្រុសស្រីក្នុងភូមិទាំងអស់ នៅទីខេត្ត-ខណ្ឌ តំបន់ផ្សេងៗប្រកបដោយសម្លៀកបំពាក់ថ្មីៗ បានមូល មកជួបជុំគ្នានាំយកទាំងបាយសម្ល ពិសេសៗនំអន្សមបាយបិណ្ឌ ចេកទុំ យ៉ាងច្រើនមកប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសផល្លានិសង្ឃជូនទៅវិញ្ញាណក្ខ័ន្ធ មាតាបិតាជីដូនជីតាញាតិកា ទាំង៧សន្តាន ដែលចែកឋាន ឬកើតទៅជាប្រេតឲ្យទទួលទាន និងរួចទុក្ខទោស ។



លោកតា មៀច ប៉ុណ្ណ

បុណ្យភ្ជុំបិណ្ឌមានប្រភពពីទស្សនៈ ព្រលឹងនិយម (Animimse) ព្រោះមានធ្វើពិធីសែនព្រេនម្ហូបចំណី បោះបាយបិណ្ឌ នំនែកជូនចំពោះព្រលឹង បុព្វការីជន ដែលខ្មែរជឿថា តែងតែមកជួយមើលសុខទុក្ខកូនចៅ នៅឋានមនុស្សលោក។ ម្យ៉ាងទៀតបុព្វបុរសខ្មែរកំណត់យកថ្ងៃបុណ្យភ្ជុំបិណ្ឌជាថ្ងៃណាត់ជួបអស់ញាតិមិត្តជិតឆ្ងាយទាំងប៉ុន្មាន ដែលបែកគ្នាទៅនៅទីផ្សេងៗ ។ នៅថ្ងៃនោះគេបានមកជួបជុំ(ភ្ជុំ)គ្នាដើម្បីសម្តែងការនឹករលឹកគ្នាសាកសួរ សុខទុក្ខគ្នាផ្លាស់ប្តូរយោបល់គ្នាពីបទពិសោធន៍ រកស៊ីនិងបច្ចេកទេស ក្នុងការបង្កបង្កើតផលកសិកម្មឲ្យមានទិន្នផលខ្ពស់ ។ ចំណែកឯបុណ្យលក្ខណៈសាសនា គឺដើម្បីឲ្យពុទ្ធសាសនិកជនមានការអាណិតអាសូរព្រះសង្ឃ ដែលគង់ចាំព្រះ

(តទៅទំព័រទី ១៣)

*(តមកពីទំព័រទី ១២)*

វស្សាក្នុងរដូវវស្សា លំបាកនឿយហត់ក្នុងការនិមន្តបិណ្ឌបាតកាត់ភ្លៀង លុយ ទឹក លុយផុក ក៏ចាត់ចែងបង្កើតជាពិធីបុណ្យភ្ជុំបិណ្ឌ ហើយនាំយកចង្ហាន់ បាយទឹកនំចំណី យ៉ាងសម្បូរទៅប្រគេនព្រះសង្ឃដល់វត្តអារាម ដោយផ្សារភ្ជាប់ ទៅនឹងអត្ថន័យនៃអដ្ឋកថាមានចែងច្បាស់ ក្នុងគម្ពីរធម្មបទ ក្នុងគោលបំណងឧទ្ទិសមគ្គផល ចំពោះព្រលឹងជូនតាឲ្យបានទទួលចំណីអាហារបរិភោគឆ្អែត ស្កប់ស្កល់ ។

ជុំវិញបញ្ហាបុណ្យភ្ជុំបិណ្ឌ និងការសែនព្រេនឬឧទ្ទិសកុសលនានា និងបញ្ហាប្រេតនរកនេះ យើងបានជួបសម្ភាសន៍ ដោយឡែកមួយជាមួយលោកសាស្ត្រាចារ្យ មៀច ប៉ុណ្ណ ទីប្រឹក្សាក្រុមជំនុំប្រពៃណី និងទំនៀមទម្លាប់ខ្មែរនៃពុទ្ធសាសនបណ្ឌិត ដោយមានខ្លឹមសារដូចខាងក្រោម ៖

*មាជ សុវណ្ណារ៉ា៖* ហេតុអ្វីបានជារាល់កម្មវិធីបុណ្យភ្ជុំបិណ្ឌ គេត្រូវតែយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅឯវត្ត ?

*មៀច ប៉ុណ្ណ៖* អ្នកដែលកាន់ព្រះពុទ្ធសាសនា សុទ្ធតែជឿជាក់ថា ប្រសិនបើគេចង់ឧទ្ទិសដល់បុព្វការីរបស់ខ្លួនដែលបានស្លាប់ទៅហើយ ត្រូវតែធ្វើ តាមរយៈអ្នកមានសីល ពិសេសគឺព្រះសង្ឃដែលជាអ្នកទ្រទ្រង់សីល ធ្វើតាមនោះទើបអាចទៅដល់បាន បើធ្វើផ្ទាល់ពុំឆ្លងកាត់អ្នកមានសីល គឺនឹងពុំអាច ទៅដល់បានឡើយ ព្រោះអ្នកនោះពុំអាចមកជួបយើងបានទេ ។

*មាជ សុវណ្ណារ៉ា៖* ការយកបាយសម្លទៅវត្តដាក់ទៅបងប្អូនញាតិការ ដែលបានស្លាប់ទៅ ដែលបានកើតទៅ ជាប្រេត ជាខ្មោច តើអ្នកទាំង នោះ កើតទៅជាខ្មោចជាប្រេតពិតប្រាកដមែនទេ ?

*មៀច ប៉ុណ្ណ* ៖ សំណួរនេះវាមានអាថ៌កំបាំងច្រើនព្រោះរវាងអ្នកសួរ និងអ្នកឆ្លើយស្ថិតនៅក្នុងឋានជាមួយគ្នា គឺពុំមែនខ្ញុំជាអ្នកធ្លាប់បានទៅរស់ នៅភពនោះទេ ។ ប៉ុន្តែ អ្វីដែលយើងអាចដឹងបាន គឺតែតាមរយៈក្បួនប៉ុណ្ណោះ បើក្បួននោះថាភរពុំបាន ថាពិតក៏ពុំបាន ប៉ុន្តែសំរេចត្រង់ថា ទាំងអស់គ្នា យល់ព្រមជឿ ។ តាមក្បួនពុទ្ធសាសនាបាននិយាយថា បើបុគ្គលណាធ្វើកម្មពុំបានល្អកាយរស់ ហើយស្លាប់ទៅនឹងទៅកើតជានរកប្រេត ។

*មាជ សុវណ្ណារ៉ា៖* ហេតុអ្វីបានជាការដាក់បាយសម្លបញ្ជូនទៅកាន់អ្នកស្លាប់តាមព្រះសង្ឃ ទើបទៅដល់ សែនព្រេនធម្មតាមិនទៅដល់ ឯជនជាតិ ចិនគេសែនដល់ឯផ្ទះ ឬម៉ុងខ្មោចទៅវិញ តើការណ៍នោះយ៉ាងណាដែរ ?

*មៀច ប៉ុណ្ណ* ៖ ជាការពិតព្រះសង្ឃជាអ្នកមានសីល ការធ្វើបាយសម្ល ដើម្បីបានទៅដល់អ្នកស្លាប់បាន គឺត្រូវតែតាមរយៈអ្នកមានសីល ចំណែកជនជាតិចិនដែលគេសែនឯផ្ទះនោះ គឺអាស្រ័យទៅតាមជំនឿបែបផ្សេងរ បស់ជនជាតិចិន ។

*មាជ សុវណ្ណារ៉ា៖* នៅឋានខ្មោចដូចជាចិត្តអាក្រក់ម្ល៉េះ សំណែនអ្នកដទៃពុំអាចលូកហូបបាន ដរាបណាបងប្អូន និងញាតិការរបស់ខ្លួនពុំបានឧទ្ទិសឲ្យទេនោះ ?

*មៀច ប៉ុណ្ណ* ៖ ជាការត្រឹមត្រូវណាស់ នៅទីនោះគេមានលក្ខណៈបុគ្គលច្រើន ប្រសិនបងប្អូនកូនចៅរបស់ខ្មោចប្រេតទាំងនោះពុំឧទ្ទិសឲ្យទេនោះ តែខ្មោចប្រេតទាំងឡាយអាចបរិភោគចំណីចំណុក នោះបានពេលណាអ្នកធ្វើទាននោះ ឧទ្ទិសឲ្យ ទើបគេអាចទទួលបាន ។

*មាជ សុវណ្ណារ៉ា៖* តើការដែលកូនចៅពុំបានទៅកាន់វត្តក្នុងឱកាសពិធីកាន់បិណ្ឌ ហើយឪពុកម្តាយដែលកើតជាប្រេត បើរកមិនឃើញ៧វត្តនោះ នឹងដាក់បណ្តាសារមែនទេ ?

*មៀច ប៉ុណ្ណ* ៖ តាមគម្ពីរដីកាព្រះពុទ្ធសាសនា និងទំនៀមទម្លាប់របស់យើង គឺបាននិយាយបែបនេះមែន ។ ព្រោះសមល្មមនឹងឲ្យគាត់ជេរដាក់ បណ្តាសារឲ្យមែន ដោយសារកាលពីគាត់នៅរស់ គាត់ខំធ្វើការរកស៊ី និងសម្លាប់គេឯង(សត្វ)ដើម្បីយកមកចិញ្ចឹមកូនឲ្យបានរស់រានមានជីវិត និងបានថ្កុំ ថ្កើងជាហេតុធ្វើឲ្យពេលគាត់ស្លាប់ទៅកើតជានរកប្រេតពី ផលកម្មរបស់ខ្លួន បែរកូនពុំធ្វើបុណ្យទានឧទ្ទិសកុសលទៅពួកគាត់ទេ ។

*មាជ សុវណ្ណារ៉ា៖* ឪពុកម្តាយប្រព្រឹត្តបាប ដើម្បីឲ្យកូន តែច្បាប់ឋាននរកមានការលើកលែងខ្លះដែរទេ ព្រោះអំពើទាំងនោះ ដើម្បីព្រហ្មវិហារធម៌ ឬ កត្តញ្ញូប៉ុណ្ណោះ ?

*មៀច ប៉ុណ្ណ* ៖ នៅឋាននរកប្រាកដជាពុំសំរាលទោសរបស់គាត់ទេ ដរាបណាកូនចៅដែលនៅរស់ពុំបានឧស្សាហ៍ ធ្វើបុណ្យឧទ្ទិសកុសលឲ្យគាត់ ដូច្នេះរាល់កូនចៅគួរធ្វើបុណ្យឧទ្ទិសកុសល ឬតបស្នងគាត់ពេលគាត់នៅរស់ឲ្យបានច្រើនទាន់ពេលគាត់នៅអាចទទួលបាន ពេលគាត់ធ្លាក់ក្នុងឋាននរក នោះហើយពិបាកក្នុងការទទួលណាស់ ។

*មាជ សុវណ្ណារ៉ា៖* អ្នកខ្លះកាលពីឪពុកម្តាយនៅរស់ គាត់អត់ឃ្លាន ខ្វះជំរក និងខ្វះការថែទាំពុំសូវគិតគូរគាត់ទេ តែពេលគាត់ស្លាប់សែនជ្រូកខ្វៃ ធ្វើចេតិយម៉ុង យ៉ាងធំអស្ចារ្យ តើបុណ្យភ្នែក រស់ និងស្លាប់ខុសគ្នាយ៉ាងម៉េចដែរ ?

*មៀច ប៉ុណ្ណ* ៖ មិនមែនមានត្រឹមតែប៉ុណ្ណឹងទេ គេមានទាំងសែនដុតលុយ,ដុតមាស,ដុតឡាន,វិឡា ឲ្យគាត់ ក្រោយពេលគាត់ស្លាប់ទៅនោះ មិន មែនជាវិធីប្រសើរឡើយ ។ ចូរផ្តល់ឲ្យគាត់(ឪពុកម្តាយ)ពេលដែលគាត់នៅមានអាយុជីវិតទើបប្រពៃ ធ្វើបុណ្យពេលខែភ្លឺប្រសើរជាងខែងងឹត (ធ្វើ បុណ្យឪពុកម្តាយនៅរស់ប្រសើរជាងធ្វើបុណ្យក្រោយគាត់ស្លាប់) ។

*មាជ សុវណ្ណារ៉ា៖* តើមានវិធីអ្វីជួយសាច់ញាតិមានបាបឲ្យរួច ទុក្ខទោសបាន ?

*មៀច ប៉ុណ្ណ* ៖ គឺមានតែធ្វើបុណ្យឧទ្ទិសកុសលឲ្យគាត់ ទើបអាចបន្ធូរបន្ថយទោសរបស់គាត់បាន ហើយបានតែជាមួយអ្នកមានសីលប៉ុណ្ណោះ ទើបអាចទៅដល់បាន ហើយអ្នកដែលអាចទទួលបានលុះត្រាតែគាត់ស្ថិតនៅក្នុងប្រភេទប្រេតលេខ ៤ទៅទៀតទើបទទួលបាន ព្រោះប្រេតប្រភេទទី៤មាន កំរិតស្រាលទៅហើយ គេហៅថា បរទត្តូបជីវីប្រេត ចិញ្ចឹមជីវិតដោយផលទានដែលគេឧទ្ទិសឲ្យ ។

*មាជ សុវណ្ណារ៉ា៖* អ្នកលួចរបស់គេ ឬបានទ្រព្យដោយវិធីពុករលួយ ហើយយកទៅធ្វើបុណ្យបានបុណ្យឬទេ ?

*មៀច ប៉ុណ្ណ* ៖ ជាការពិតណាស់ ការធ្វើបុណ្យដោយពីវិធី លួចទ្រព្យគេ ឬបានដោយវិធីពុករលួយនឹងពុំបានបុណ្យ ដល់តិចតួច ឡើយ ។

*មាជ សុវណ្ណារ៉ា៖* តើអ្នកស្លាប់ប្រភេទណាទៅជាប្រភេទខ្មោចប្រភេទណាទៅជាប្រេត ?

*មៀច ប៉ុណ្ណ* ៖ គ្មានការកំនត់ថា ជាប្រភេទណានៃអ្នកស្លាប់ទៅជាខ្មោច ឬប្រេតឡើយ ប៉ុន្តែគឺវាយោងទៅលើប្រភេទនិស្ស័យកម្មដែលបុគ្គល ម្នាក់ៗបានប្រព្រឹត្តឡើងកាលនៅរស់ តាមតិច ឬច្រើន សូមកុំភ្លេចថា រាល់ទង្វើរបស់យើងទាំងអស់សុទ្ធតែមានអ្នកតាមឃ្លាំមើលកត់ត្រាទាំងអស់គឺអ្វីៗ យុត្តិធម៌ខ្លាំងណាស់ ។

*មាជ សុវណ្ណារ៉ា៖* តើការស្លាប់ទៅជាខ្មោច ប្រេត ហើយខ្មោច ប្រេតនោះរស់នៅបែបណាដែរ ?

*មៀច ប៉ុណ្ណ* ៖ ការចាប់ជាតិ ឬជាប្រេត គឺជាដំណាក់កាលមួយស្រាលជាងនរកបានន័យថា បានធូរស្រាលមួយកំរិតយ៉ាង ធំបន្ទាប់ពីបុគ្គលណា ម្នាក់ទទួលទុក្ខទោសជាច្រើនជាតិរួចមក ។ ហើយប្រេតមាន៤ចំណាត់ថ្នាក់ទៅទៀត គឺប្រភេទ ឧត្តជីវី រស់នៅ និងចិញ្ចឹមជីវិតដោយស៊ីខ្ទុះស៊ីឈាម ជាអាហារ, ប្រភេទទី២ ខុប្បបាសិកា ជាប្រភេទប្រេតដែលឃ្លានជានិច្ចរងទុក្ខទោស គ្រប់ពេលវេលា, ប្រភេទទី៣ និជ្ឈាមតណ្ហិក ភ្លើងឆេះជានិច្ច និង ប្រភេទទី៤ បរទត្តូបជីវី គឺចិញ្ចឹមជីវិត ដោយផលទានដែលគេឧទ្ទិសឲ្យ ។ ប្រភេទចុងក្រោយនេះដែលធូរស្រាលជាងគេ ។

*មាជ សុវណ្ណារ៉ា៖* មនុស្សស្លាប់ទៅឮថា មានការចាប់ជាតិមែនទេ? ខ្លះថា កើតជាមនុស្សវិញ ខ្លះទៀតកើតជាសត្វតិរច្ឆានផ្សេងៗ ខ្លះទៀតពុំទាន់ ចាប់ជាតិ សូមពន្យល់រឿងនេះបានទេ ?

*មៀច ប៉ុណ្ណ* ៖ តាមទ្រឹស្តីព្រះពុទ្ធសាសនាបានចែងថាយើង ដូចនោះមែនមនុស្សមិនស្លាប់ទៅសូន្យនោះទេ គឺវិលកើតវិលស្លាប់ គេហៅថា វាលវដ្តសង្សារ ដូចកង់រទេះអញ្ជើង បើចង់គេចចេញពី វដ្តសង្សារនោះ គឺមានតែ និព្វានប៉ុណ្ណោះ ប៉ុន្តែមានតិចណាស់ដែលទៅដល់ ។

*មាជ សុវណ្ណារ៉ា៖* នៅតាមជញ្ជាំងព្រះវិហារ និងចំលាក់ខ្លះ គេឃើញមានពិពណ៌នាអំពីការទទួលទោសទណ្ឌ និងទារុណកម្មផ្សេងៗ ដូចជាការឲ្យជនមានបាបទូលដី ខ្លះឲ្យឡើងរកាដែក ខ្លះបោះចូលក្នុងឆ្នាំងខ្ទះទឹកកំពុងតែពុះ,អារ ក...តើក្នុងគម្ពីរដីកាណាដែលនិយាយអំពីបញ្ហានេះ? តើនេះគឺជាការស្រមើលស្រមៃរបស់ជាងគំនូរ ឬជារឿងពិត ?

*មៀច ប៉ុណ្ណ* ៖ នេះពុំមែនជាការស្រមើលស្រមៃរបស់អ្នកណាទាំងអស់ ។ គឺគេបានដកស្រង់ចេញពីគម្ពីរដីកាណាមួយនៃព្រះពុទ្ធនោះទេ ប៉ុន្តែ ដោយព្រះសង្ឃដែលមានការយល់ដឹងជ្រៅជ្រះ ក្នុងព្រះពុទ្ធសាសនា លោកបានធ្វើការបកស្រាយឲ្យដល់សាធារណជន បានងាយយល់ងាយស្តាប់ និងប្រតិបត្តិ ត្បិតនៅក្នុងពុទ្ធឱវាទទាំង ៨៤០០ព្រះធម្មខ័ណ្ឌរបស់ព្រះមានន័យជ្រៅ និងពិបាកយល់ ។ ដូច្នេះមានតែអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាទេ ដែលអាចពន្យល់បាន ហើយក៏ពុំខុសទាស់អ្វីដែរសំរាប់អប់រំសាធារណជនកុំឲ្យធ្វើអំពើអាក្រក់ ដូចជាសម្លាប់គេ ការជួញដូរ ផ្លូវភេទ,ចាប់ជំរិតគេ,ឆក់ប្លន់,សហាយស្មន់ប្តី-ប្រពន្ធគេ...។ល។

*មាជ សុវណ្ណារ៉ា៖* បើគេពិនិត្យតាមគម្ពីរខ្លះ គឺការដាក់ទោសទ័ណ្ឌទៅលើអ្នកស្លាប់ ដូចជាធ្ងន់ធ្ងរពេក ដូចជាឮថា អ្នកប៉ិនជេរ កើតទៅជា ប្រេតមាត់ ម្ជុល, លួចសហាយស្មន់ប្តីប្រពន្ធគេឡើង រកាដែក,ឡើងខ្ទះខ្លាញ់,បឹងភ្លើង...ឬក៏លួចហូបបាយមុនលោក កើតជាអាប ឬបាបផ្សេងៗ ?

*មៀច ប៉ុណ្ណ* ៖ ដូចចម្លើយពីមុនរបស់ខ្ញុំអញ្ជើង គឺមានយ៉ាង ដូច្នេះអញ្ជើងមែន ប៉ុន្តែរឿងខ្លះពុំមានចែងក្នុងគម្ពីរទេ ដូចយ៉ាងករណីរំលូតកូន, ការ ជួញដូរភេទ...ប៉ុន្តែនៅតាមព្រះវិហារនៃវត្ត ខ្លះមានគំនូរបាបបរិយាយពីប្រការនោះ ។ គឺអាស្រ័យទៅលើអ្នកដឹកនាំសាសនា ទាំងនោះយល់ថា ជាគតិល្អ ក្នុងការអប់រំមនុស្សឲ្យគេចវេសពីទង្វើអាក្រក់ៗ ទាំងនោះចេញ បើពុំនោះទេ នឹងធ្លាក់ចូលទៅក្នុងស្ថានភាពដែលពិពណ៌នាខាងលើនោះដែរ ។ ឯបញ្ហា អាបពុំមែនស្ថិតនៅក្នុងសាសនាព្រះពុទ្ធទេ តែជាជំនឿមួយបែបរបស់ខ្មែរយើង ដែលមានតាំងពីមុនសាសនាព្រះពុទ្ធ ហូរចូលមកប្រទេសកម្ពុជាយើងម្ល៉េះ ។ បុគ្គលអាប គឺថា អតីតជាអ្នករៀន វិជ្ជាស្នេហ៍មុខយ៉ាងជោគជាំរួចមក ។

*មាជ សុវណ្ណារ៉ា* ៖ ជាចុងក្រោយលោកមានការពន្យល់យ៉ាង ណាដែរដល់សាធារណជនខ្មែរ ?

*មៀច ប៉ុណ្ណ* ៖ ទោះភ្ជុំបិណ្ឌជាប្រពៃណី ឬជាបុណ្យសាសនាក្តី ក៏បានឆ្លុះបញ្ចាំងនូវ ៖

ការលើកតម្កើងគុណូបការៈ និងការតបគុណចំពោះបុព្វការីជន ។

ទាំងព្រះសង្ឃគ្រប់វត្តអារាម ទាំងអាជ្ញាធរដែនដីគួរឆ្លៀតឱកាសក្នុងថ្ងៃបុណ្យភ្ជុំ ដែលមានម្ហូបអាហារនំនែក ផ្លែឈើដ៏សម្បូរពោរពាសនេះ ចែករំលែកទៅដល់ជនក្រីក្រ លំបាកតោកយ៉ាកជនពិការ ជនចាស់ជរាឥតទីពឹង និងអង្គភាពយោធាការពារព្រំដែននៅទីឆ្ងាយដាច់ស្រយាលក្រោម រូប ភាពជាអំណោយទានជួយសង្គ្រោះគ្នាក្នុងន័យកាត់បន្ថយទុក្ខវេទនា និងការស្រេកឃ្លានបានមួយខណៈផងដែរ ។ គួរចៀសវាងការបាចបោះបាយបិណ្ឌ ចោលទៅលើដីទទេៗ ធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន និង អនាម័យក្នុងវត្តអារាម ក៏ដូចជា ខ្ជះខ្ជាយចំណីអាហារដ៏មានតម្លៃសម្រាប់អ្នកស្រេកឃ្លាន ។/

*ខ្មែរប៉ុស្តិ៍*

## ធម្មកថារបស់ព្រះតេជគុណ បណ្ឌិត ហុក សាវណ្ណ អំពីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ

Website: hoksavann.org

ថ្ងៃ១៥ កញ្ញា ២០០៥

បុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះត្រូវពុទ្ធសាសនិកខ្មែរតែងធ្វើមុនព្រះសង្ឃ ចេញព្រះវស្សាចំនួនមួយខែ រៀងរាល់ឆ្នាំ គឺចាប់កាន់បិណ្ឌតាមវេន ពីថ្ងៃ១រោចដល់ថ្ងៃ១៤រោចខែភទ្របទ ។ នៅថ្ងៃ១៥រោច ជាថ្ងៃភ្ជុំបិណ្ឌ គឺជាថ្ងៃសំខាន់ ដោយគេធ្វើពិធីបុណ្យនេះរួមគ្នាគ្រប់វេន ទាំងអស់ ។ **ពាក្យថាបិណ្ឌ** ៖ ចេញមកពីភាសាបាលីថា បិណ្ឌំ ប្រែថាដុំបាយ ដូចជាពាក្យថា បិណ្ឌបាត្រ គឺយកដុំបាយទម្លាក់ក្នុងបាត្រ ។ ប៉ុន្តែបាយបិណ្ឌ ដែលគេធ្វើក្នុងពេលកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះ គឺជាដុំបាយដំណើបដែលគេចំអិនលាយខ្ទិះដូងនិងល្ង ឬលាយជាមួយគ្រឿងផ្សំផ្សេងទៀត តាមទម្លាប់អ្នកស្រុក ។ គេរៀបចំបាយបិណ្ឌនៅជុំវិញបាយបត្តបូរ ។ បាយបត្តបូរក៏ធ្វើដូចជាបាយបិណ្ឌ ដែរ គ្រាន់តែគេពូតជាពំនូតធំ មានកំពូលស្រួចហើយគ្របដោយសាជីស្លឹកចេក និងមាន

*(តទៅទំព័រទី ១ ៤)*

*(តមកពីទំព័រទី ១៣)*

ដោតទៀនធូបផ្កាភ្ញីផង ។ កន្លែងខ្លះឲ្យន័យថា **ពាក្យថាបិណ្ឌ** ៖ គឺចង្ហាន់ដែល ពុទ្ធបរិស័ទប្រគេនព្រះសង្ឃឆាន់ ក្នុងពិធីឧទ្ទិសផលបញ្ជូនទៅញាតិសន្ដានមានមាតាបិតាជាដើម ដែលចែកឋានទៅកាន់បរលោកហើយ ហៅថា បិណ្ឌថា ធ្វើបុណ្យដាក់បិណ្ឌថា បុណ្យភ្ជុំបិណ្ឌ ។

មុនថ្ងៃភ្ជុំមួយថ្ងៃ គ្រួសារខ្មែរនៅគ្រប់ទីកន្លែងនាំគ្នាធ្វើនំអន្សម នំគម ជាដើម បំរុងយកទៅវត្តប្រគេនព្រះសង្ឃ ឧទ្ទិសកុសល និងសំរាប់ចែកញាតិមិត្ត ។ ឯនៅ ទីវត្ត ពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗបោសសំអាតទីធ្លាវត្ត សំអាតចេតិយ និងតាក់តែងសាលាបុណ្យឲ្យបានសមរម្យ ។ នៅល្ងាចថ្ងៃ១៤រោច មុនភ្ជុំមួយថ្ងៃ មានពិធី ពិសេស គឺព្រះសង្ឃចំរើនព្រះបរិត្តនិងទេសនា កន្លែងខ្លះមានធ្វើពិធីអភិសេកព្រះពុទ្ធរូបផង ។ រាល់យប់ក្នុងអំឡុងពេលកាន់បិណ្ឌ និងភ្ជុំបិណ្ឌនោះ ពុទ្ធបរិស័ទបាននាំគ្នា ទៅវត្តស្ដាប់ព្រះសង្ឃចំរើនព្រះបរិត្ត និងទេសនា ។ រាល់ព្រឹក ពុទ្ធបរិស័ទ បានយកចង្ហាន់ទៅរាប់បាត្រ និងវេរប្រគេនព្រះសង្ឃ រួចស្ដាប់ព្រះសង្ឃសូត្រងារបង្សុកូលឧទ្ទិស កុសល ។ ពេលព្រលឹមស្រាងៗ គ្រប់វត្តអារាម គេឮសូរព្រះសង្ឃសូត្របរាភវ សូត្រលាយឡំដោយភ្លេងពិណពាទ្យ និងធម៌បទផ្សេងៗកំដរបុណ្យផង ។ មានកន្លែងខ្លះ ពុទ្ធបរិស័ទក្រោកពីព្រលឹមបាចបាយបិណ្ឌ នៅតាមខឿនព្រះវិហារដោយគេយល់ថា ពួកប្រេតតែងតែមកពេលល្ងិតរកចំណីបរិភោគ ។ ស្របគ្នាក្នុងន័យនេះដែរ បានជាគេធ្វើបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះខែរនោចព្រោះគេយល់ថា ពួកប្រេតចេញដើររកស៊ីចំណីពេលងងឹត ។ ប៉ុន្តែតាមគម្ពីរព្រះពុទ្ធសាសនាផ្នែកព្រះសូត្រ បញ្ជាក់ថា អ្នក ស្លាប់ដែលអាចទទួលផលបានដោយសារក្រុមគ្រួសារញាតិមិត្ត ដែលបានធ្វើបុណ្យឧទ្ទិសទៅឲ្យ ដូចជាការធ្វើទានរក្សាសីលជាដើម ជាពិសេសអ្នកដែលអាចទទួលផលបាន គឺពួកមនុស្សសត្វដែលបានទៅកើតជាប្រេត ។

នៅក្នុងពេលកាន់បិណ្ឌ និងភ្ជុំបិណ្ឌនោះ ព្រះសង្ឃ និងពុទ្ធបរិស័ទតែងតែសូត្រនូវសូត្រមួយហៅថា បរាភវសូត្រ ។ បានជាយកសូត្រនេះមកសូត្រធ្វើជាបទផង ព្រោះសូត្រនេះមានប្រយោជន៍ក្នុងការងារប្រចាំថ្ងៃរបស់មនុស្ស ។ គឺជាសូត្រមួយដែលពួកទេវតាទូលសួរព្រះពុទ្ធ អំពីធម៌ដែលនាំឲ្យមានសេចក្ដីវិនាស ដែលផ្ទុយគ្នាពី មង្គលសូត្រដែលពោលអំពីធម៌ដែលនាំឲ្យមានសេចក្ដីចំរើន ។ បរាភវសូត្រធម៌ ដែលនាំឲ្យសេចក្ដីវិនាស មានជាអាទិ៍ថា អ្នកស្រលាញ់ធម៌នាំឲ្យចំរើន អ្នកស្អប់ធម៌នាំឲ្យ វិនាស, អ្នកសេពគប់អ្នកអសប្បុរស អ្នកដេកច្រើន និយាយច្រើន អ្នកមានទ្រព្យច្រើនមិនចិញ្ចឹមមាតាបិតា ដែលចាស់ជរា, អ្នកប្រព្រឹត្តល្បែង៣ប្រការ ល្បែងស្រី, ល្បែងស្រា ល្បែងភ្នាល់ទាំងឡាយជាដើម ទាំងអស់នេះជាប្រធាននៃសេចក្ដីវិនាស ។

បុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះ មានខ្លឹមសារជាពិសេសគឺការឧទ្ទិសកុសល ជួយរំដោះទុក្ខដល់ជាតិមិត្តក្រុមគ្រួសារមានមាតាបិតា ជាដើម ដែលចែកស្ថានទៅ ក្រែងទៅកើតទីណាមួយមានទុក្ខវេទនាដោយមានអត្ថបទបុរាណខ្មែរពោលថា ស្ដេចយមរាជបានដោះលែងសត្វនរក ឬប្រេតក្នុងឱកាសបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ នោះឲ្យទៅរកបងប្អូនកូនចៅក្រែងធ្វើបុណ្យកុសលឧទ្ទិសឲ្យខ្លួន ។ រហូតមានអត្ថបទខ្លះនិយាយថា បើរកមិនឃើញញាតិមិត្តណាធ្វើបុណ្យឧទ្ទិសឲ្យទេ ក៏យំសោកបោក ខ្លួនដោយសេចក្ដីស្រេកឃ្លាន ហើយក៏ប្រទេចផ្ដាសាដល់ញាតិមិត្តបងប្អូនកូនចៅរបស់ខ្លួនដែលមានចិត្តអាក្រក់ ពុំនឹកនាដល់សេចក្ដីទុក្ខវេទនារបស់ខ្លួន ។ ដូច្នេះបុណ្យនេះ ចាត់ទុកជាបុណ្យឧទ្ទិសកុសលជួយរំលែកទុក្ខ ក្រែងជាតិកំណើតណាមួយបានធ្វើអំពើបាប ហើយធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិ ។ បុណ្យនេះមានអត្ថន័យសំខាន់ មួយទៀត គឺការពិចារណានូវសង្សារវដ្ដ ដែលតែងតែកើតមកហើយតែងតែស្លាប់ទៅវិញ អាចឲ្យជម្រុញទឹកចិត្តលះបង់នូវអំពើបាប ហើយសាងតែអំពើល្អ ព្រោះខ្លាច ធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិទាំង៤ មាននរកជាដើម ។

តាមការស្រាវជ្រាវបុណ្យនេះ ពុំទាន់ដឹងប្រាកដថាកើតឡើងក្នុងសម័យណាទេ នៅសម័យពុទ្ធកាលគេទំនុកបំរុងព្រះសង្ឃដោយបច្ច័យ៤ ក្នុងរយៈពេល៣ខែ ពេលដែលព្រះសង្ឃចូលព្រះវស្សានោះតែម្ដងៗខ្លះថា បុណ្យនេះយកតាមលំនាំរឿងប្រេត ជាញាតិរបស់ព្រះបាទពិម្ពិសារ នៅក្នុងគម្ពីរធម្មបទដោយមានសេចក្ដីដំណាល ជាសង្ខេបថា នៅពេលដែលព្រះបាទពិម្ពិសារ បាននិមន្តព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានមកទទួលចង្ហាន់ ពុំបានតាំងព្រះទ័យឧទ្ទិសកុសលដល់ព្រះញាតិ របស់ព្រះអង្គ ពួកព្រះញាតិដែលទៅកើតជាប្រេតបានបន្លឺ សម្លេងយំស្រែកជុំវិញព្រះរាជវាំង ជាសញ្ញាទាមទារផលបុណ្យ ព្រោះខ្លួនមានទុក្ខវេទនាអត់ឃ្លានជាយូរមកហើយ ។ ដោយទូលសួរព្រះពុទ្ធជាម្ចាស់ ថាតើសម្លេងនោះជាសម្លេងអ្វី ? ព្រះពុទ្ធត្រាស់ថា សម្លេងនោះជាសម្លេងពួកប្រេតជាញាតិរបស់ព្រះអង្គ ពួកគេយំស្រែកព្រោះយមរាជពុំបាន ផ្សាយកុសលដល់ពួកគេ ។ ព្រះបាទពិម្ពិសារបានជ្រាបហេតុការណ៍នេះហើយ ទើបព្រះអង្គប្រញាប់ប្រញាល់ធ្វើបុណ្យដូចគ្នានេះជាលើកទី២ ហើយតាំងចិត្តឧទ្ទិសកុសល ដល់ពួកប្រេតជាញាតិ។ ចាប់ពីពេលនោះមក សម្លេងស្រែកក៏ស្ងាត់បាត់ទៅ ជាភស្តុតាងបញ្ជាក់ថា ពួកប្រេតជាញាតិបានទទួលផលបុណ្យនោះហើយ ។ បុណ្យនេះពុំមែន ឧទ្ទិសចំពោះតែសត្វ ដែលកើតជាប្រេតនោះឡើយ ព្រោះពាក្យថា បេតៈ ជាភាសាបាលីសំស្ក្រឹតថា ប្រេតៈ ខ្មែរថាប្រេត ប្រែជាសេចក្ដីថា អ្នកទៅកាន់បរលោក ឬអ្នកដែលធ្វើមរណកាលទៅកាន់បរលោក ។ ប្រើជានាមសំដៅយកសត្វប្រេតក្នុងអបាយភូមិ ។ ប្រើជាគុណនាមសំដៅយកមនុស្សដែលស្លាប់ទៅហើយ ។

នៅល្ងាចថ្ងៃ១៥រោច ខែភទ្របទនៃថ្ងៃភ្ជុំនោះ ប្រជាពលរដ្ឋខ្មែររៀបសែនដូនតា ដោយពិធីផ្សេងៗក្រៅព្រះពុទ្ធសាសនាខ្លះ គឺនៅវេលាល្ងាចនោះ មានរៀប កន្ទេលខ្មើយ ក្រាលសំពត់សពីលើកន្ទេលដាក់ចំអាប១ថាស បង្អែម១ថាស មានក្រាស់ម្សៅជាដើម ហើយឲ្យកូនចៅច្រូចទឹកលើសំណែននោះប្រតិស្ឋអធិដ្ឋានជូនទៅ ដូនតា ។ លុះព្រឹកឡើងថ្ងៃ១កើត ខែអស្សុជ មានធ្វើទូកស្រទបចេកដាក់នំចំណីអុជទៀនធូបបណ្ដែតលើខ្នងទឹកទន្លេ ស្ទឹង ព្រែក ឬអូរ តាមស្ថានភាពនៃស្រុកនីមួយៗ បញ្ជូនដូនតាទៅស្រុកវិញ ។ ពិធីទាំងអស់នេះមកដល់បច្ចុប្បន្ន ហាក់ដូចជាបាត់បង់ទៅហើយ ពុំសូវឃើញមានធ្វើដូចពីដើមទេ អាចមានធ្វើខ្លះនៅតាមជនបទ ។ ទោះបី ពិធីនេះក្រៅព្រះពុទ្ធសាសនា ប៉ុន្តែមានន័យរំលឹកគុណ ចូលក្នុងន័យព្រះពុទ្ធសាសនា ។ បុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះ មានអត្ថន័យសំខាន់ណាស់ ក្នុងអារ្យធម៌ខ្មែរក្នុងចំណងសាមគ្គីភាព ភាតរភាព មេត្រីភាព ទោះបីញាតិមិត្តចែកស្ថានទៅហើយ ក៏នៅតែនឹករលឹកតបគុណជួយរំដោះទុក្ខដែរ ។/

---

*(តមកពីទំព័រទី ៧)*

នេះមានកម្លាំងណាស់ ដោយសារតែប្រទេសចិនកុម្មុយនីស្ត បានផ្ដល់បង្អែកយ៉ាងមាំដល់ព្រះអង្គ ដែលពេលនោះ ជាសន្លឹកបៀរចុងក្រោយរបស់ចិនសម្រាប់កម្ពុជា ។ បន្ថែមពីលើទម្ងន់នេះទៅលើវៀតណាម ចិនបានយកជម្លោះរឿងកោះ ស្ព្រាតលី មកវាយវៀតណាមនៅ ឆ្នាំ១៩៧៩ នោះយ៉ាងទ្រមខ្លួន ។ ការវាយប្រហាររបស់ទ័ពចិននេះ គេពុំសូវដែលប្រទះទេ តែបានផ្ដល់ផលចំណេញថា "យួនត្រូវតែដកចេញពីកម្ពុជា" ។ រូបភាពអមិត្តភាពរបស់វៀតណាមមកលើកម្ពុជា គឺការមកជួយវាយកម្ចាត់ក្រុម ប៉ុល ពត រួចហើយវៀតណាម



ហ៊ុន សែន



ខៀវ សំផន

ពុំចង់ចេញពីកម្ពុជាទៅវិញទេ ១០ឆ្នាំបន្ទាប់ពីសន្យាថា ដកទ័ពទៅប្រទេសខ្លួនវិញ នៅតែដកមិនអស់ ហើយថែមទាំងរៀបចំបណ្ដេញសន្តិសុខរបស់ខ្លួនរឹតតែមាំនៅកម្ពុជា ។ នេះជាហេតុធ្វើឲ្យពិភពលោក មើលឃើញ វៀតណាមថា ពុំមែនមកជួយកម្ពុជាទេ គឺមកកាន់កាប់កម្ពុជាទៅវិញ ម្ល៉ោះហើយក៏មានចលនាជួយដល់ក្រុមអ្នករំដោះជាតិ បើទោះជាមានក្រុមខ្មែរ ក្រហមនៅក្នុងចលនានោះក៏ដោយក្ដី ។ នៅក្រោមសម្ពាតដ៏ខ្លាំងក្លា របស់សហគមន៍អន្តរជាតិ វៀតណាមបានដកខ្លួនចេញបណ្ដើរទៅមែន តែបានពង្រឹងចលនា ខ្មែរក្រហមមួយក្រុមទៀត ដឹកនាំដោយលោក ជា ស៊ីម, ប៉ែន សុវណ្ណ, ហ៊ុន សែន ឲ្យឡើងជាភាគី ជម្លោះជំនួសភាគីវៀតណាមនៅកម្ពុជាបាន ។ គឺចាប់ពីពេលនោះហើយ ដែលផែនការណ៍របស់ គ្វារ៉េត អេវិន បានត្រូវ អ.ស.ប លើកយកមកពិចារណា ដើម្បីបញ្ចប់ជម្លោះរវាងខ្មែរ ក្រុមសីហនុនិយម ដែលមានខ្មែរក្រហម ក្រុមលោក សឺន សាន និងក្រុមទ្រង់ រណឫទ្ធិ ប្រឆាំងនឹងក្រុម ហ៊ុន សែន, ជា ស៊ីម ទៅវិញ ។ រីឯបរទេសជាបង្អែកទាំងអស់ត្រូវនៅជាអព្យាក្រិត្យ មិនអាចចូលទៅជួយ ដល់ភាគីខ្មែរ ណាបានទេ ។

ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានត្រូវសន្មត់ថា "ភាគីកម្ពុជាទាំងអស់ រួមទាំងភាគីបរទេសទាំងឡាយណាដែលជាប់ទាក់ទងជិតស្និទ្ធ ឬមិនជិតស្និទ្ធ និងដំណោះស្រាយសន្តិភាពនៅកម្ពុជា ត្រូវចុះហត្ថលេខា រួមយល់ព្រមឲ្យមាន អ.ស.ប ទៅបំពេញបេសកកម្មសន្តិភាពនៅកម្ពុជា" ។

១៦ឆ្នាំក្រោយមក តើបេសកកម្ម អ.ស.ប នោះ បានទទួលជោគជ័យប៉ុណ្ណា?

***យើងនឹងធ្វើសេចក្ដីរាយការណ៍លំអិតមួយនៅលេខក្រោយ ។/***

*ខ្មែរប៉ុស្តិ៍*

## សន្និសិទនៅ ស.រ.អា សិក្សាពីលទ្ធផលនៃសន្និសិទក្រុងប៉ារីស ២៣ តុលា ១៩៩៩១ -១៦ឆ្នាំក្រោយមក

សេចក្ដីអញ្ជើញរបស់ : CAHRAD – CANC – CAF—CBC (USA) – CFC – KAF – KMS – UCIC

សន្និសិទធ្វើនៅ:

HOLLIDAY INN CRYSTAL CITY

2650 JEFFERSON DAVIS HWY ARLINGTON, VA 22202

ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ **20 & 21 October, 2007**

ទាក់ទងទៅ : -វ៉ានី (103) 123 4273
-ចាន់ធូ (242) 464 4910
-ចិន្ដា (847) 813 3870
E-mail:conference@camrad.org

# KHMER STAR GIFT SHOP 1

1911 E. 10th Street • Long Beach, CA 90813
Bus: (562) 591-0262 • Cell: (562) 841-1616 /(562) 256-4328

# ហាងខ្មែរស្តាការ៉ាអូខេនិងលក់វត្ថុអំណោយ




-គឺជាហាងលក់នូវសំភារៈសិក្សា សម្លៀកបំពាក់ ប្រដាប់ប្រដាប្រើប្រាស់ផ្ទះបាយបន្ទប់គេង ក្នុងលំនៅដ្ឋានជាលក្ខណៈដុំឬរាយ មានតម្លៃសមរម្យ ។

-អ្វីដែលសំខាន់ទៀតនោះ ហាងខ្មែរស្តា ក៏មានដាក់លក់នូវចម្រៀងការ៉ាអូខេខ្មែរ, បរទេស, ភាពយន្តបូរាណឬសម័យ និងបទចម្រៀងពិរោះរណ្តំចិត្តបែបសម័យទំនើបចម្រុះ មិនថាក្នុងសម័យអធិរាជសម្លេងមាសគ្មានប្រៀប ស៊ិន-ស៊ីសាមុត, អ្នកនាងរស់-សេរីសុទ្ធា ឬក្រុមតារា-អ្នកចម្រៀងថ្មីៗជំនាន់ក្រោយឡើយ ។




-ហាងខ្មែរស្តាដែលម្ចាស់ជាចាងហ្វាងផលិតកម្មការ៉ាអូខេ **SM** ម៉ៃ-សាម៉េត ផងនោះ សូមស្វាគមន៍ចំពោះបងប្អូនខ្មែរដោយក្តីរាក់ទាក់ពីក្រុមហ៊ុនយើងដែលបានសិតសំរាំងនូវបទចម្រៀងពិរោះៗ និងនិពន្ធបទថ្មីៗដែលឆ្លុះបញ្ចាំងពីសង្គមវប្បធម៌ខ្មែរបំណងបំពេរចក្ខុអារម្មណ៍ឬសោតអារម្មណ៍ឲ្យបងប្អូនមានក្តីសប្បាយរីករាយពីភាពនឿយហត់ក្នុងការងារ និងបំបាត់ការអផ្សុក ។




# KHMER STAR GIFT SHOP 2

1432 Atlantic Ave • Long Beach, CA 90813
Bus: (562) 591-0262 • Cell: (562) 841-1616



ចាប់បើកថ្មីបន្ថែមមួយទៀតហើយស្ថិតនៅក្បែរភោជនីយដ្ឋាន
ព្រះចន្ទពេញវង់ (LA LUNE) ពីថ្ងៃទី១៣ ខែតុលាតទៅ ក្នុងឱកាសនោះយើងខ្ញុំ
នឹងមានលក់ជូននូវ DVD & CD របស់ក្រុមហ៊ុន ម៉ៃ-សាម៉េត (SM) ក្នុងតម្លៃពិសេស
ទិញ4 ថែម1 ។ ហើយជាមួយនេះផងដែរ បើលោក-អ្នកចំណាយប្រាក់ទិញ
សំភារៈក្នុងហាងយើងខ្ញុំត្រឹមតែ$20 លោកអ្នកនឹងទទួលបាននូវCDមួយ ។

## សូមអញ្ជើញដោយរួសរាន់ !

# បច្ចុប្បន្នភាពនៃរឿងមិនគួរកើតនៅកម្ពុជា

វាជារឿងដែលគួរឲ្យចង់សើច និងជារឿងដែលមិនគួរកើត តែនៅក្នុងកម្ពុជានាពេលបច្ចុប្បន្ននេះ វាបែរជាកើតមានច្រើនសឹងតែមិនគួរជឿ ករណីដែលលើកមកនេះ គឺកើតមានក្នុងអំឡុងពេលខែចុងក្រោយនេះតែប៉ុណ្ណោះ ។

• **រកឃើញប្ដីនៅក្នុងបន្ទប់ ខាងរ៉ាអូខេវៃខ្ទេចឡានមួយ**

នៅភ្នំពេញស្ត្រីម្នាក់ទំនងជាប្រច័ណ្ឌប្ដី បន្ទាប់ពីបាត់ប្ដី ហើយស្រាប់តែមករកឃើញកំពុងច្រៀងក្នុងបន្ទប់ខាងរ៉ាអូខេមួយនៅម្ដុំផ្សារធំថ្មី ក្រុង ភំពេញ ក៏វៃកំទេចរថយន្តនោះហើយឡើងជិះម៉ូតូឌុបទៅផ្ទះវិញធ្វើវាហី។ ករណីនេះសាក្សីនិយាយថា នៅម៉ោងប្រមាណ៩ព្រឹក ថ្ងៃទី២ តុលា ស្ត្រី អាយុប្រមាណ៤០ឆ្នាំបានមកវាយរថយន្តមួយគ្រឿងម៉ាកកាមរី ស៊េរី-៨៧ ពាក់ផ្លាកលេខ ឃ.5643 . ភព2 ឡើងខ្ទេចនៅមុខហាងខារាអូខេ "ចំប៉ា" ក្នុងសង្កាត់ផ្សារថ្មី៣ ក្រុងភ្នំពេញ ។ លុះក្រោយដែលស្ត្រីជាប្រពន្ធទៅបាត់បុរសជាប្ដីនោះ ក៏លបៗមកបើឡាននោះទៅបាត់ទៅ ។ គ្មានអ្នក ណាស្គាល់ប្ដីប្រពន្ធមួយនេះទេ តែតាមសាក្សីឲ្យដឹងពីដើមហេតុថា ដោយសារតែស្ត្រីជាប្រពន្ធខឹង និងការបាត់ប្ដីដែលមកច្រៀងខារ៉ាអូខេមួយយប់ ហើយស្រវឹងដេកក្នុងហាងរហូតមួយព្រឹកថែមទៀត។/

• **ខឹងទិញបារីជឿមិនឲ្យចាក់សាំងដុតទាំងរស់**

ជារឿងសឹងតែមិនគួរជឿ តែថា វាបានកើតមានរួចហើយកាលពីថ្ងៃទី១ខែតុលាឆ្នាំ២០០៧ នៅឯស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ដែល ដើមហេតុមកពីបុរសម្នាក់ស្រវឹងស្រា បានមកទិញបារីពីស្ត្រីអ្នកលក់ចាប់ហួយ វ័យ២៥ឆ្នាំ តែដោយខឹងសុំជំពាក់ប្រាក់មិនព្រម បុរសរូបនោះ ក៏កញ្ឆក់ដបសាំងដែលតាំងលក់ជិតដៃមកចាក់ស្រោចពីលើ ក្នុងចេតនាដុតស្ត្រីអ្នកលក់នោះទាំងរស់ ។ ប៉ុន្តែដោយសារតែការប្រតាយប្រតប់គ្នាសាំងបាន ស្រោចលើនិងត្រូវភ្លើងឆេះតែមួយកំណាត់ខ្លួន ហើយរងការរលាកត្រឹមដៃជើងប៉ុណ្ណោះ នេះបើកុំតែបានការអន្តរាគមន៍ពីអ្នកជិតខាងផង កុំអីអាច ដល់ស្លាប់ឬ ពិការមួយជីវិតក៏ថាបាន ។

បុរសឃោរឃៅដែលយកការស្រវឹង មកដោះសារនៅចំពោះមុខប៉ូលិស នូវចេតនាអាក្រក់នេះឈ្មោះ គាក់ សាន អាយុ៣៣ឆ្នាំ រស់នៅភូមិ អូរ ស្គូត ឃុំបន្ទាយនាង ស្រុកមង្គលបុរី ឯស្ត្រីរងគ្រោះឈ្មោះ ជួន សមុទ្រ ជាអ្នកភូមិផងរបងជាមួយគ្នា ។ បច្ចុប្បន្នបុរសម្នាក់នេះត្រូវសមត្ថកិច្ច ប៉េអឹមខេត្តបន្ទាយមានជ័យ បញ្ជូនទៅតុលាការហើយ។/

• **កូនតំណាងរាស្ត្រក៏មិនលើកលែងដែរ !**

ស្រុកខ្មែរឲ្យតែអ្នកមានតួនាទីធំក្នុងរាជការ គឺកម្រមានអ្នកណាហ៊ានប៉ះពាល់ណាស់ គិតតាំងពីតុលាការឡើងទៅ គឺមិនហ៊ានឲ្យមន្ត្រីរដ្ឋចាញ់ក្ដី ឡើយ តែកាលពីថ្ងៃទី ២៩ កញ្ញា បែរជាមានបុរសបីនាក់ ក្នុងនោះមានម្នាក់ជាប្រធានក្រុមហ៊ុនមួយបានជិះឡានកាមរី ស៊េរី-៩១ ប្រដេញចាប់កូនស្រីអ្នកតំណាងរាស្ត្រ សំ ហ៊ាង នៃមណ្ឌលខេត្តសៀមរាប ឡើងផ្អើលក្រុងទេសចរនេះ ទាំងកណ្ដាលអាធ្រាត្រ ។

ក្រោយការឃាត់ខ្លួនរបស់សមត្ថកិច្ចខេត្ត ជនទាំងបីដោះសារថាខ្លួនដេញតាមចាប់ដោយសារតែនារីសំណារី (កូនលោក សំ ហ៊ាង) បើក ឡានកៀរឡានគេហើយរត់តែខាងប៉ូលិស ពិនិត្យទៅមិនឃើញមានស្លាកស្នាមដូចចោទសោះ។ តាមសាក្សីឲ្យដឹងថា ករណីនេះជនបង្កហេតុបាន តាមដេញប្រកិត និងតាមរករឿងឡើងផ្អើលមនុស្សក្នុងសណ្ឋាគារ "បុប្ផាអង្គរ" ខេត្តសៀមរាប ខណៈដែលនាង សំ ណារី បានរត់មកសុំការជួយ អន្តរាគមន៍ និងដើម្បីលាក់ខ្លួនគេចពីការប៉ុនប៉ងព្យាបាទនៅក្នុងសណ្ឋាគារនោះ ។ ករណីនេះម្ចាស់សណ្ឋាគារបុប្ផាអង្គរបានប្ដឹងទៅតុលាការហើយ ហើយជនបង្កហេតុត្រូវបានប៉ូលិសឃាត់ខ្លួន ដើម្បីធ្វើការស៊ើបអង្កេត។/

• **ផឹកប៉ះចំស្រាកាចគប់ក្បាលគ្នាបែកហូរឈាមព្រោះតែសាច់ក្លែម**

ស្រុកខ្មែរឥឡូវ គ្រាន់តែការផឹកស៊ីសប្បាយសោះ ក៏មានរឿងចម្លែក មានកាប់ចាក់គ្នាផ្អើលភូមិដែរ ជាក់ស្ដែងកាលពីថ្ងៃទី១៩កញ្ញា២០០៧ នៅភូមិ ខ្លុយលិច ឃុំសូយោង ស្រុកបារាយណ៍ ខេត្តកំពង់ធំ បុរសឈ្មោះ សាំង ឧត្តម អាយុ ២៣ ឆ្នាំ ត្រូវរងរបួសបែកក្បាល ដោយសារតែមិត្តភក្តិឈ្មោះ ខៃ ម៉ៅ អាយុ ២៣ ឆ្នាំ មានទីលំនៅមិនច្បាស់លាស់ផឹកស៊ីជាមួយគ្នាគប់នឹងចាន ។ មុនមានរឿងឈ្មោះ ខៃ ម៉ៅ បានប្រើឈ្មោះ សាំង ឧត្តម ឲ្យទៅយកសាច់ក្លែម បន្ថែម តែដោយគេមិនព្រមទៅ ឈ្មោះ ខៃ ម៉ៅ ខឹងក៏គប់មួយចានចំក្បាលបែកចេញឈាមត្រូវគ្រូពេទ្យដេរចំនួនប្រាំថ្នេរ ។ បន្ទាប់ពីបង្ករបួសរួចឈ្មោះ ខៃ ម៉ៅ បានរត់គេចខ្លួនបាត់ ។ អ្នកឃើញហេតុការណ៍ និយាយកំប្លែងលេងថា ពួកគេផឹកប៉ះចំស្រាគប់ចាន ទើបមានអ្នករបួសបែបនេះ ។ ខ្លះនិយាយលេងដែរ ស្រាស្រុកខ្មែរមានជាច្រើនប្រភេទណាស់ មានស្រាវាយប្រពន្ធកូន ស្រាផឹកហើយកាប់ចាក់គ្នា ស្រាវាយតប់ដណ្ដើមស្រីគ្នា ស្រាផឹកហើយចង់តែបាញ់បោះ និង ស្រាចាប់រំលោភស្រី ក៏មាន....ជាដើម ។/

• **ជ្រូកនាំចូលពីយួនអត់ច្បាប់៩ក្បាលត្រូវសមត្ថកិច្ចចាប់ដុតទាំងរស់**

ជារឿងសាហាវមួយ ដែលប្រទេសកម្ពុជាប្រកាន់យកពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ហើយស្រាប់តែអាជ្ញាធរ ចាត់វិធាការសាហាវហួសហេតុដល់ ទៅដុតសត្វទាំងរស់ឲ្យរត់ពេញដី ។ រឿងដុតជ្រូកទាំងរស់នេះ គឺមិនមែនធ្វើសាច់ខ្វៃ ឬក៏ដើម្បីធ្វើជាគ្រឿងក្លែមក៏ទេដែរ តែនេះជាករណីបង្ក្រាបអំពើនាំ មេជ្រូកពូជ៩ក្បាលល្មើសច្បាប់ ដែលសមត្ថកិច្ចបសុសត្វខេត្តកំពង់ចាម បានអនុវត្តជាការព្រមានដល់អ្នកល្មើសបំរាម។ វិធានការទប់ស្កាត់បញ្ឈប់ការនាំចូល សាច់និងជ្រូកពីបរទេសនោះការិយាល័យបសុព្យាបាលខេត្ត បានអនុវត្ត ដោយសហការ ជាមួយកម្លាំងការពារព្រំដែនយោងតាមការផ្សព្វផ្សាយ នៅឯកិច្ច ប្រជុំថ្នាក់ខេត្ត ហើយកាលពីថ្ងៃទី ២៥ កញ្ញា សមត្ថកិច្ចក៏ស្ទាក់ចាប់បានជ្រូករស់ ៩ ក្បាលពីឈ្មួញវៀតណាមដែលឌុបដោយម៉ូតូចូលមកភូមិរូង ឃុំរូង ស្រុក មេមត់នៃខេត្តធំជាងគេ នៃកម្ពុជានេះ ហើយកងកម្លាំង ក៏យកមកដុតទាំងរស់តែម្ដង ដើម្បីជៀសវាងការប៉ះពាល់សុខភាព ប្រជាពលរដ្ឋពីការឆ្លងរោគ ។ សមត្ថកិច្ចអះអាងថា នៅវៀតណាមជ្រូកកំពុងកើតជំងឺ ត្រចៀកខៀវ ដែលជាប្រភេទជំងឺមួយសាហាវ បានសម្លាប់ប្រជាពលរដ្ឋវៀតណាមជាបន្តបន្ទាប់ ។ ប៉ុន្តែទោះជាយ៉ាងណាវិធានការបែបនេះ ក៏ត្រូវបានរិះគន់ថា វាសាហាវហួសហេតុនិងថានៅមានវិធានការក្រៅពីនេះច្រើនដែលគួរធ្វើ ។ អ្នកខ្លះទៀតក៏គិតដែរថារដ្ឋហាមតាំងពីការសម្លាប់សត្វនៅថ្ងៃសីលតែដល់មន្ត្រីធ្វើបែបនេះ វាហាក់ដូចជាផ្ទើននឹងវិធានការរដ្ឋាភិបាលទៅវិញ ។/

• **គិតចូលរំលោភចៅ តែយាយអង្វរពេកក៏ព្រមតាម**

"....លោកចោរហ្អើយអាណិតកូនស្រីខ្ញុំ វានៅក្មេងណាស់កុំធ្វើបាបវា បើចង់រំលោភៗខ្ញុំវិញទៅ......." វាជារឿងកំប្លែងសើចលេងដែលលោកព្រហ្ម ម៉ាញបានតំណាលពីមុនមក ប៉ុន្តែឥឡូវរឿងនេះវាបានកើតឡើងពិតក្នុងប៉ុន្មានអាទិត្យកន្លងទៅនេះ ដោយសារតែបុរសប្រមឹកម្នាក់ ស្រវឹងជោគខ្លួនលប ឡើងលើផ្ទះយាយក្រីក្រ ដែលរស់នៅជាមួយចៅតូចៗ២នាក់ ក្នុងគោលបំណងចាប់ចៅរបស់យាយរំលោភសេពសន្ថវៈ ប៉ុន្តែ ពេលនោះដោយយាយសំពះ អង្វរកពេក ថាចៅៗយាយនៅតូចៗគ្នាមិនដឹងខ្យល់អី បើចង់រំលោភមករំលោភលោកយាយចុះ លោកចោរបានដៃក៏យិតយាយរហូតបានសំរេចបំណង ដ៏លាមករបស់ខ្លួន ។ លោកយាយរងគ្រោះមានអាយុ៧៣ឆ្នាំដំបូងអាចោរជំរិតទារប្រាក់១០ម៉ឺនរៀលទេ តែមកពីយាយដ៏កំសត់គាត់គ្មានលុយ ទើបបុរស ចោរប្រមឹកល្មោភកាមតណ្ហាក្រាស់ប្រព្រឹត្តអំពើអនាចារនោះ។ ករណីបានកើតឡើងនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧ វេលាម៉ោង៨យប់ លុះដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ក្រោយពេលលោកយាយដាច់ចិត្តប្ដឹងប៉ូលិសប៉ុស្តិ៍រដ្ឋបាលឃុំគគីរធំ ក៏សុំយោបល់ទៅតុលាការខេត្តកណ្ដាលធ្វើការឃាត់ខ្លួនជនសង្ស័យ តែម្ដង ។

លោកយាយអាយុ៧៣ឆ្នាំ ពិការជើងម្ខាងរស់នៅក្នុងខ្ទមកំសត់ជាមួយចៅកំព្រា២នាក់ យ៉ាងវេទនាក្នុងភូមិគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្ត កណ្ដាល ។ ឯជនសង្ស័យពីតណ្ហាក្រាស់ឈ្មោះ សឿន ណាត ភេទប្រុស អាយុ២៣ឆ្នាំ មានស្រុកកំណើតនៅ ស្រុកព្រះស្ដេច ខេត្តព្រៃវែងមកមានប្រពន្ធ នៅភូមិគគីរធំ។ ជននេះបានបដិសេធដែរ តែគ្មានភស្តុតាងបញ្ជាក់សោះ ។/

• **ដាក់ច្រវាក់កូនក្នុងសណ្ឋាគារព្រោះខ្លាចឆ្លងអេដស៍**

ស្ត្រីឡប់សតិម្នាក់ បាននាំកូនពីរនាក់យកទៅចាក់សោរទុកក្នុងបន្ទប់សណ្ឋាគារ រហូតធ្វើឲ្យអ្នកបំរើការមានការសង្ស័យ ក៏ប្ដឹងសមត្ថកិច្ចឲ្យជួយអន្ត រាគមន៍ ។ សមត្ថកិច្ចប៉ូលិសព្រហ្មទ័ណ្ឌខេត្តកោះកុង និងព្រះរាជអាជ្ញាអមតុលាការ បានទៅរំដោះកូនទាំងពីរនិងនាំស្ត្រីនោះ ចេញពីបន្ទប់សណ្ឋាគារ "ភូមិន្ទ កោះកុង" កាលពីថ្ងៃ១០ កញ្ញា ហើយបានចោទប្រកាន់ពីបទប្រើហិង្សាមកលើកូនខ្លួនផ្ទាល់ផ្ទុយពីច្បាប់ ។ ប៉ូលិសខេត្តកោះកុងឲ្យដឹងថា ស្ត្រីសតិមិនល្អនេះ ឈ្មោះ សេង មួយ អាយុ៣៩ឆ្នាំ នៅក្នុងភូមិព្រះពន្លា សង្កាត់ព្រៃកប្រា ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ចំណែកកូនស្រីច្បងឈ្មោះ ហ៊ាង អាយុ ១៣ឆ្នាំ និងកូន ប្រុសឈ្មោះ យាង អាយុ៧ឆ្នាំ ។

នៅចំពោះមុខប៉ូលិសស្ត្រីរូបនេះឆ្លើយថា ខ្លួនពិតជាបានដាក់ច្រវាក់ចាក់សោ កូនទាំងពីររបស់គាត់ពិតប្រាកដមែន ព្រោះខ្លាចកូនបើកទ្វារបន្ទប់ឲ្យ ឪពុករបស់វាចូល ព្រោះអីប្ដីគាត់ឈ្មោះ គ្រាន់តូច ធ្វើជាគ្រូពេទ្យនៅអតីតជំរំខាវអ៊ីដាង ធ្លាប់បានបូមឈាមអ្នកផ្ទុកមេរោគអេដស៍យកមកគំរាម

(តទៅទំព័រទី ១៨)



## **ឆាន ឈួ ៖** ចម្រៀងមួយបទរុញជីវិតពីកម្មករបេះផ្លែឈើ ទៅជាថៅកែ!



លោក កែវ សារ៉ាត់ និង លោក ឆាន ឈួ

*តមកពីលេខមុន....*

កែវ សារ៉ាត់ ច្រៀង គឺបទស្រណោះដីខ្មែរស្រុកស្រែចំការ ដែលបទ នេះបានរុញច្រានក្ដីអស់សង្ឃឹមរបស់មនុស្សម្នាក់ ឱ្យទទួលជោគជ័យក្នុងឆាកជីវិត ជាជនភៀសខ្លួនចំណាកស្រុក ព្រោះសំពាធនយោបាយប្រទេស កម្ពុជានាអតីតកាលមួយដែលធ្លាក់ចូលទៅក្នុង ភ្លើងសង្គ្រាម ។ ស្របពេលនយោបាយការទូត អាមេរិកបានកាត់ផ្ដាច់ចំណងគ្នាទៀត ឆាន ឈួ បានគិតថា ស្រុកខ្មែរនឹងរលាយនៅដំណាក់ចុងក្រោយពីការឈ្លានពានពីបរទេស ហើយឪពុកនិងកូនត្រូវព្រាត់ប្រាសនិរាស្ដ រហូតដល់ស្លាប់គ្មាន ថ្ងៃជួបគ្នា ។ ដោយការគិតស្មាននេះ បានចាប់បង្ខំ ទឹកចិត្ត និងបេះដូងស្រលាញ់ខ្មែរ នឹកស្រុកទេស ជាមួយចំណេះដឹងចេញពីអ្នកបួសរៀន ឪប្លូម សាលាបាលី៦ព្រះវស្សា ។ នៅតំបន់ស្រុក គាស់ ក្រឡ ឆាន ឈួ បាននិពន្ធនូវបទចម្រៀង២បទ គឺ បទស្រណោះដីខ្មែរ និងបទពិសាខដើមឆ្នាំ នាឆ្នាំ ១៩៨៤ បំណងបង្ហាញពីការអស់សង្ឃឹមថា គ្មាន ថ្ងៃវិលត្រឡប់វិញទេ ក្នុងផ្លូវដ៏លំបាកក្នុងជីវភាព គ្រួសារ និងការឃ្លាតឆ្ងាយស្រុក ព្រាត់ញាតិផៅ សន្ដានដើម្បីឱ្យធូរទ្រូងពីការគិត ។ ប៉ុន្តែធាតុ ពិតផ្ទុយពីការគិត និងស្មាននោះ ឆាន ឈួ ដែល បាននិពន្ធបទចម្រៀងជិត៥០បទឱ្យ កែវ សារ៉ាត់ ច្រៀង ក៏ស្រាប់តែប្រែជីវិតឱ្យមានជីវភាពធូរធារមួយពព្រិចភ្នែកផ្លាស់ប្ដូរពីជីវិតដែលធ្លាប់ដើរ ឬជិះកង់ទៅរៀន ព្រោះខ្សត់ខ្សោយលុយចាក់សាំង ឡានកញ្ចាស់មួយ ដែលបានត្រឹមតែបញ្ឈរចោល នៅមុខផ្ទះនាក្រុង ត្បៀចកឿន និងជាកម្មករស៊ី ឈ្នួលបេះផ្លែឈើ ព្រោះតែបញ្ហាក្រពះ និងទឹក ដោះគោ ឱ្យកូនបៅ ។

ជីវិតពីអ្នកស្រែក្លាយជា អ្នកជំនួញជួកិច្ច ព្រោះតែភាពជោគជ័យនៃបទចម្រៀង ។ គ្រួសារ មួយនេះបានរុញច្រានឱ្យកូនប្រុស ស្រី ៤នាក់ រស់ នៅមានអនាគតល្អក្រោមដំបូន្មានឪពុកម្ដាយ ដែលកូនស្រី២នាក់មានកិត្តិយសជាប់បរិញ្ញា ឯក សមាគមខ្មែរ ឡៀនង ពចោហ និងបរិញ្ញា ឯកបីប្រទេស មានខ្មែរ-ថៃ-លាវ។ រីឯកូនប្រុសជួយធ្វើការឱ្យក្រុមហ៊ុនឪពុកតាមគន្លងធម៌នៃ កូនខ្មែរក្នុងវប្បធម៌អាស៊ី ។ ឆាន ឈួ ដែលជាថៅកែផង និងតួសម្ដែងឯកឱ្យតារាភាពយន្តថៃ ផ្នែកខេមរៈភាសា បានអះអាងថា ជាង២០ឆ្នាំ បន្ទាប់ពីសេចក្ដីអត់ឃ្លានក្នុង នាមជាអតីតជនភៀសខ្លួន នាទសវត្សរ៍ឆ្នាំ ៨០ ដោយឥឡូវលោកបានជោគជ័យជាមួយសុភមង្គល គ្រួសារយ៉ាងប្រសើរហើយ ។ ប៉ុន្តែទទឹមនឹងការ ជោគជ័យ ក៏យើងត្រូវមានការទប់ស្កាត់ពីការ បរាជ័យផងដែរ ព្រោះអនាគតជីវិតមនុស្សគ្មាន នរណាទស្សន៍ទាយបានទេ ក្នុងន័យ"ចន្លោះ ប្រហោង ឬភ្លាត់ស្នៀត១វិនាទីនាំឱ្យបរាជ័យមួយ ជីវិត"។

ក្ដីមោទនភាពនៃជីវិតជោគជ័យ លោក ឆាន ឈួ អះអាងថា ក្រុមហ៊ុនរបស់លោកនៅតែមានសន្ទុះគាំទ្រពីមហាជន បើទោះបីមានព្រឹត្តិការណ៍កំហឹងវាយដុតស្ថានទូតថៃ នៅកម្ពុជាកាល ពីឆ្នាំ២០០២ ក៏ដោយ ។ ប៉ុន្តែដំណើរអាជីព ជំនួញពីឆ្នាំ១៩៨៧មក បងប្អូនខ្មែរនៅតាម សហគមន៍ បានផ្ដិតអារម្មណ៍ និងដាក់មនោ-សញ្ចេតនាជាមួយ ខ្សែភាពយន្តថៃបញ្ចូលសម្លេង ខ្មែរ ក្រុមហ៊ុនរបស់លោកក្នុងបំណងកែអផ្សុក និងចង់ឱ្យកូនចៅចេះនិយាយខ្មែររួមនឹងចង់ឃើញ របៀបរបបនៃតម្លៃវប្បធម៌ជាតិ បើ

(តទៅទំព័រទី ១៩)

## មាតុភូមិ ៖ ២០ឆ្នាំរស់ទាំងគ្រាំគ្រា...ក្រព្រោះទ្រទ្រង់អក្សរសាស្ត្រមិនឱ្យលិចលង់...!

*ដោយ ៖ មាស សុវណ្ណារិទ្ធិ*

ក្នុងទឹកមុខដែលមើលទៅទំនងជាមានការគិតគូរច្រើនពីចំណោទបញ្ហា មិនថា ក្នុងផលរបររកស៊ី




ឬការរិះរកកៀងគរខ្មែរឱ្យយល់ពីតម្លៃ វប្បធម៌ អក្សរសាស្ត្រជាតិ គុជ សុជាតិ ដែលជាម្ចាស់ហាងមាតុភូមិ បានអះអាងថា កន្លែងរបស់ខ្លួនគឺជា ទីមជ្ឈមណ្ឌលអក្សរសាស្ត្រ ចម្រុះទៅ ដោយសៀវភៅរាប់រយមុខ ដែលជាតឹកតាងគ្រឹះនៃតម្លៃជាតិខ្មែរ ។

ហាងមាតុភូមិ ត្រូវបានខ្មែរនៅម្ដុំក្រុងខ្មែរឡុងប៊ិចស្គាល់ថា ជាកន្លែងមួយបើករបររកស៊ីលក់ដូរសៀវភៅគ្រប់មុខ ដែលទាក់ទងទៅនឹង អក្សរសាស្ត្រ វប្បធម៌, អរិយធម៌, ប្រវត្តិសាស្ត្រ,សង្គម,សេដ្ឋកិច្ច,នយោបាយ,វិជ្ជាពេទ្យប្រព័ន្ធសុខាភិបាល និងសិល្បៈប្រលោមលោក កុន ល្ខោន ចម្រៀងសម័យបុរាណ ខារ៉ាអូខេ ជាដើម។ល។ ដែលកើតមានមកជិត២០ឆ្នាំ ។ ប៉ុន្តែផលរបររកស៊ីលក់ដូរសៀវភៅនេះ ហាក់មិនសូវកាក់កប ប៉ុន្មានទេ ព្រោះមនុស្សតិចតួចណាស់ដែលចាប់អារម្មណ៍ និងចូលចិត្តអានសៀវភៅ ដោយសារបងប្អូនខ្មែរយើងការចេះដឹងនូវមានកំរិត ផ្សំនឹង ជីវភាពមិនសូវធូរធារក្នុងគ្រួសារទៀតនោះ ឬអ្នកមួយចំនួនមិនចេះអក្សរដែលវាខុសពីប្រទេសមហាអំណាចអាមេរិកាំងមួយនេះ ដែលប្រជាជន របស់គេវាពោរពេញទៅដោយអ្នកចេះដឹងមានការរៀនសូត្របានខ្ពស់ ។ ដូច្នោះដើម្បីចង់ដឹងបន្ថែម ឬការពិត ពួកគេចាំបាច់ត្រូវតែទៅកាន់ Bookstore ឬបណ្ណាល័យដើម្បីទិញសៀវភៅ ឬខ្ចីសំរាប់ការអាន និងស្រាវជ្រាវនូវចំណេះដឹងចម្រុះពីគ្រប់ទិសទី និងជុំវិញជាតិសាសន៍របស់ពួកគេ ។

គុជ សុជាតិ និយាយថា មាតុភូមិកើតឡើងពីមានលុយរហូតដល់ក្រខ្លួន ក៏លោកមិនតូចចិត្តឡើយ រហូតដល់បាត់បង់ស្នេហា ដោយ បេះដូងមិនផ្សាភ្ជាប់ជាមួយគូស្នេហ៍ ក៏មិនខ្វល់ខ្វាយដែរ ព្រោះយើងបានជួយទ្រទ្រង់ ដោយធ្វើឱ្យមាតុភូមិក្លាយទៅជាមជ្ឈមណ្ឌលអក្សរសាស្ត្រ ជាតិនេះឡើង ។ ហើយអ្វីដែលយើងចង់បាន គឺការបង្ហាញនូវគោលការណ៍របស់ មាតុភូមិ ដែលជាអត្ថប្រយោជន៍ចំពោះសង្គមជាតិ ដោយសុំនូវ ការអំពាវនាវដោយស្មោះអស់ពីដួងចិត្ត និងជាសំណូមពរសំរាប់ជីវិតចុងក្រោយ ក្នុងការទទួលនូវការជួយឧបត្ថម្ភដ៏កក់ក្ដៅនោះ គឺជាកាយវិការនៃ ការយល់យ៉ាងច្បាស់លាស់ពីតម្លៃនៃ ការកសាងជាតិរបស់យើង ។ ហើយបើការបណ្តែតបណ្តោយមិនបានគិតទេនោះ មានន័យថា"ភាសារលត់ ជាតិរលាយ,ភាសាពណ្ណរាយ ជាតិថ្កុំថ្កើង"។ អ៊ំប្រុស សម្បត្តិ អ្នករស់នៅក្រុង San Diego និយាយថា ការធ្វើល្អដោយការតស៊ូ ហើយអំណត់ ដើម្បីសេចក្ដីល្អសំរាប់សង្គម សំរាប់ខ្មែរ ដែលជាក់ស្ដែង ដូចម្ចាស់ហាងមាតុភូមិមានអ្វីៗ គ្រប់សព្វនូវសៀវភៅឯកសារ ក្នុងការថែរក្សាព្រលឹង ជាតិខ្មែរនោះ មិនយូរមិនឆាប់សេចក្ដីល្អការប្រឹងប្រែងពិតជានឹងនាំផលលាភ និងការជោគជ័យមកឱ្យជាមិនខាន ។ តើអ្នកណាជាអ្នកនាំសំណាង មកឱ្យនោះ គឺប្រជាជនខ្មែរយើងនោះឯង ព្រោះពួកគេត្រូវការ នូវអ្នកណាពិត...អ្នកណាត្រង់ដើម្បីជួយបង្ហាត់បង្ហាញផ្លូវ ឱ្យដល់កូនចៅពួកគេបានយល់ជ្រួលជ្រាបពីតម្លៃជាតិយើង។

ចំណែកលោក ឆាន ឈួ បានសំដែងក្ដីបារម្ភថា បើសហគមន៍យើង ពិសេសពួកអ្នកដឹកនាំសមាគម ឬក្រុងខ្មែរ មិននាំគ្នាបាញ់ឆ្ពោះឱ្យស៊ី ជម្រៅទៅនឹងបញ្ហាអក្សរសាស្ត្រ វប្បធម៌ជាតិទេ។ ដោយយើងគ្មានមជ្ឈមណ្ឌលវប្បធម៌ ឬអក្សរសាស្ត្រណាមួយច្បាស់លាស់ ឱ្យលេចចេញជារូប រាងទេនោះ នូវទីបញ្ចប់ក្មេងៗសារក្រោយពួកគេលែងដឹងឮនិងយល់អ្វីទាំងអស់ថា ស្អីទៅជាខ្មែរ? អក្សរខ្មែរ វប្បធម៌ប្រពៃណីជាខ្មែរនោះ?។

អ្នកស្រី សិទ្ធា សាន ប្រធានក្រុងខ្មែរ Long Beach បានប្រាប់ខ្មែរប៉ុស្ដិ៍ឱ្យដឹងថា យើងចាំបាច់ណាស់ការបង្កើតក្រុងខ្មែរ គឺដើម្បីចង់រក្សា វប្បធម៌អក្សរសាស្ត្រខ្មែរនោះឯង។ ដូច្នេះភាពសហការគ្នាត្រូវតែមាន ប៉ុន្តែយើងត្រូវការប្រើប្រាស់ពេលវេលាដើម្បីចាត់ចែងការងារព្រោះក្រុងខ្មែរយើង ទើបសម្រេចឱ្យជាង២ខែប៉ុណ្ណោះ មិនអាចធ្វើអ្វីឱ្យទាន់ចិត្តចង់បានភ្លាមៗនោះទេ។ អ្នកស្រី សទ្ធា សាន បន្តថា ថ្មីៗនេះ យើងបានរៃ អង្គាសប្រាក់បាន១៥ម៉ឺនដុល្លារ ដើម្បីគាំទ្របណ្ណាល័យ Mark Twain ព្រោះមានកូនខ្មែរយើងក៏បានទៅប្រើប្រាស់ នៅទីនោះដែរ ។ រហូតដល់ យើងមានកន្លែង១បន្ទប់ សំរាប់ដាក់តាំងនូវវត្ថុអ្វី ដែលជាអត្តសញ្ញាណជាតិខ្មែរផង ។

ទាក់ទិនទៅនឹងការសួរនាំពីបញ្ហាមជ្ឈមណ្ឌលអក្សរសាស្ត្រមាតុភូមិ ចៅហ្វាយក្រុងខ្មែរជាស្ត្រីរូបនេះបានអះអាងថាយើងនឹងមានការជជែកគ្នាដើម្បីថា តើយើងត្រូវធ្វើអ្វីជាមួយគ្នាដើម្បីសហគមន៍ខ្មែរយើង។

នាយកដ្ឋានមាតុភូមិ គឺជាកន្លែងការពារកិត្តិយសនិងតម្លៃរបស់ជាតិយើង ជាកន្លែងរបស់យើងដែលជាពលរដ្ឋខ្មែរទាំងអស់គ្នា ។ នាយក ដ្ឋាននេះមានគណៈកម្មាធិការនិពន្ធ ការិយាល័យជួយសំរួលកិច្ចការទូទៅ សាលារៀនដែលមានការបើកបង្រៀនតាំងពីដើមខែតុលានេះតទៅ ផលិតកម្មមាតុភូមិ (ដំណើរទេសចរណ៍ជុំវិញប្រទេសកម្ពុជា) វត្ថុភ្ជុំ CD(ចម្រៀងដើម ស៊ីន ស៊ីសាមុត, រស់ សេរីសុទ្ធា, ប៉ែន រ៉ន, ហួយ មាស) ទស្សនាវដ្ដីមាតុភូមិ, បណ្ណាល័យ និងបណ្ណាគារមាតុភូមិ, រោងពុម្ព និងមជ្ឈមណ្ឌលតម្កល់ឯកសាររបស់ជាតិ ព្រមទាំងល្ខោននិយាយ, ចាប៉ីរឿង, អាយ៉ៃ, ល្ខោនបាសាក់, យីកេ, ភ្លេងខ្មែរ, (ភ្លេងការ, ពិណពាទ្យ, មហោរី, ខ្លុយ, សាដៀវ)។ល។

លោក គុជ សុជាតិ បានអំពាវនាវតាមរយៈខ្មែរប៉ុស្ដិ៍ឱ្យដឹងថា នាយកដ្ឋានមាតុភូមិ អាចរស់រានមានជីវិត គឺអាស្រ័យលើការយកចិត្តទុក ដាក់ និងការជួយឧបត្ថម្ភគាំទ្រយ៉ាងមោះមុតបំផុតពីសំណាក់ប្រជាជនខ្មែរ ។ ព្រោះថាមពលដ៏ខ្លាំងក្លានេះ អាចជួយជំរុញមាតុភូមិបំពេញ បេសកកម្មដ៏ថ្លៃថ្លារបស់ខ្លួនក្នុងការបោះផ្សាយនូវសៀវភៅវចនានុក្រមវេជ្ជសាស្ត្រ, ច្បាប់, នយោបាយ, សេដ្ឋកិច្ច, ទស្សនវិជ្ជា, កសិកម្ម, និង ពាក្យវប្បធម៌ជាតិ ព្រមទាំងសៀវភៅសិក្សាផ្សេងទៀត ឱ្យបានសម្រេចជាស្ថាពរក្នុងការបំរើផលប្រយោជន៍ដ៏សំខាន់បំផុតសម្រាប់ប្រទេសជាតិរបស់ខ្លួន ។/



នាទីប្រវត្តិសាស្ត្រ៖

# ពីរចនាសម្ព័ន្ធ"កុលសម្ព័ន្ធ"ទៅរដ្ឋបាលជាតិ"

*រៀបរៀងដោយ ៖ ពិន សំខុន*

គឺជាការបរិច្ឆេទប្រវត្តិសាស្ត្រ ដែលប្រជាពលរដ្ឋខ្មែរគួរចងចាំពីនយោបាយរបស់ជាតិខ្លួន។ សព្វថ្ងៃនេះឯកសារមានតិចតួច ហើយពិបាកយល់ ឬក៏សរសេរជា ភាសាបរទេស ដែលបើខ្មែរភាគច្រើនបានជួបប្រទះ ហើយក៏មិនដឹងជាយកមកធ្វើអ្វីតទៅទៀត ។ កូនខ្មែរភាគច្រើននៅបរទេសពុំបានទទួលការសិក្សាពីវិជ្ជាដ៏មាន សារសំខាន់នេះទេ ការមិនដឹងនេះធ្វើឱ្យខ្មែរយើងមួយចំនួនមិនចង់ឱ្យគេស្គាល់ថាខ្លួនជាខ្មែរថែមទៀតផង ។

មិនចង់និយាយអំពីទង្វើត្រូវ ឬខុស ល្អ ឬអាក្រក់ យើងនឹងលើកមកបង្ហាញ តែព្រឹត្តិការណ៍នៅពេលវេលាមួយ ជាមួយនឹងតួអង្គដែលមានពិតប្រាកដ ហើយ លោកអ្នកអាននឹងនៅតែជាម្ចាស់នៃការពិចារណាលើព្រឹត្តិការណ៍ទាំងឡាយនោះដោយខ្លួនឯងដដែល ។ នេះជាឱកាសល្អណាស់ ដែលនៅពេលអានអត្ថបទនេះ លោក អ្នកនឹងឃើញព្រឹត្តិការណ៍ដែលបានកើតឡើង ដោយគ្មានឥទ្ធិពលនៃការស្រលាញ់ ឬស្អប់ ល្អឹង ឬជូរចត់ ត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះឡើយ លុះដល់អានចប់ទើបអាច ឃើញចំណុចក្រោយ ឬចំណុចខ្លាំងនៃកម្ពុជា នៃពូជពង្សខ្មែរតាមរយៈប្រវត្តិនយោបាយ បច្ចុប្បន្នបង្រួញខ្លីជូនជាសណ្តាប់នាពេលនេះ ។

ប្រវត្តិនយោបាយបច្ចុប្បន្នខ្មែរនេះ បានត្រូវកសាងឡើងនាជំនាន់ព្រះបាទអង្គឌួង នាឆ្នាំ១៨៥០ ដែលតាំងពីនោះមក មានការផ្លាស់ប្តូររចនាសម្ព័ន្ធជាតិ ពីលក្ខណៈ "កុលសម្ព័ន្ធ" មកលក្ខណៈ"ទំនើបវិញ ម្តងបន្តិចៗទៅតាមដែលប្រជាជាតិអាចទទួលបាន ។ រហូតបានមកដល់រចនាសម្ព័ន្ធនយោបាយសព្វថ្ងៃនេះ ខ្មែរប្រើពេលអស់រយៈ ពេល១៥០ឆ្នាំ ថ្ងៃខែឆ្នាំ ដកស្រង់ពីសៀវភៅគន្លឹះនៃកម្ពុជា របស់ វ៉ាអ៊ុល ដេណាឆ្នាំ១៨៣៥ព្រះបាទអង្គច័ន្ទចូលទីវង្គពេលនោះព្រះរាជវង្សអង្គអេង និងអង្គម៉ី ដណ្តើមរាជសម្បត្តិ ហើយទៅពឹងយួន និងសៀមឱ្យជួយដណ្តើមដែនដីខ្មែរនេះ ពេលនោះបានក្លាយទៅជាភ្នក់ភ្លើងសង្គ្រាម រវាងប្រទេសជិតខាងយ៉ាងខ្ទេចខ្ទាំ។ ប្រជាពលរដ្ឋខ្មែរក៏ពុំបានដេកចាំសុំតែសុខនោះទេ គេបាននាំគ្នាបះបោរស្ទើរគ្រប់កន្លែង ហើយបណ្តេញឱ្យយួន(អណ្ណាម)ដកទ័ពចេញពីកម្ពុជា ដែលខ្លួនបានកាន់កាប់ចំនួន ១០ ឆ្នាំបាន ។

***ឆ្នាំ១៨៤៦*** ៖ សៀម និងយួន បានបង្ខំឱ្យស្តេចអង្គឌួង ដែលគេអភិសេកនៅស្រុកសៀមឱ្យចុះហត្ថលេខា ចំណុះឱ្យប្រទេសទាំងពីរនោះ ហើយនាំសួយសារអាករ ឱ្យប្រទេសជាម្ចាស់នោះរៀងរាល់ឆ្នាំ ពេលនោះព្រះអង្គនៅជាចំណាប់ខ្មាំងរបស់សៀម ។

***ឆ្នាំ១៨៤៨*** ៖ ដោយសារចង់បន្ទាបការបះបោរបស់រាស្ត្រខ្មែរ ស្តេចសៀមក៏បញ្ជូនព្រះបាទអង្គឌួង ឱ្យមកសោយរាជ្យស្រុកខ្មែរវិញ ហើយអភិសេកជាថ្មីម្តងទៀតនៅកម្ពុជា ក៏ប៉ុន្តែទុកកូនពីរនាក់ជាចំណាប់ខ្មាំងដដែល គឺព្រះអង្គម្ចាស់នរោត្តមនិងព្រះអង្គម្ចាស់ស៊ីវុត្ថា ស្តេចសៀមយល់ថា ស្តេចសៀមយល់ថា ព្រះអង្គឌួង ជាស្តេចអត់ចេះក្បួនយោធាទេ ។

***ឆ្នាំ១៨៥៣*** ៖ (ថ្ងៃ១៤ មិថុនា) ព្រះបាទអង្គឌួង បានលបផ្ញើរចុតហ្មាយទៅឱ្យព្រះចៅអធិរាជ ណាប៉ូឡេអុង ទី៣ នៃប្រទេសបារាំង ឱ្យមកជួយស្រុក ដោយបាន ដឹងថា បារាំងមានបំណងមកយកកូសាំងស៊ីន។

***ឆ្នាំ១៨៥៦*** ៖ (ថ្ងៃ២១ តុលា)ឯកអគ្គរាជទូតបារាំងឈ្មោះ ម៉ុងទីញី មានភារកិច្ចមកចុះហត្ថលេខាមិត្តភាពជាមួយខ្មែរ បេសកកម្មនោះត្រូវបរាជ័យ ដោយស្តេច សៀមដឹងថា មានអំពើក្បត់នៅប្រទេសខ្មែរ ។

***ឆ្នាំ១៨៥៩*** ៖ (ថ្ងៃ១៧កុម្ភៈ) បារាំងចូលមកកាន់កាប់ជ្រោយនៅព្រៃនគរ។

***ឆ្នាំ១៨៦០*** ៖ (ថ្ងៃ១៩ តុលា)ព្រះបាទអង្គឌួងចូលទីវង្គត់ បន្តរាជ្យដោយហ្លួងនរោត្តម ជាព្រះរាជបុត្រ

***ឆ្នាំ១៨៦១*** ៖ (ថ្ងៃ៧ កុម្ភៈ) នាវាចម្បាំងបារាំងចំនួន៥៥ចូលសំចតនៅព្រៃនគរ

***ឆ្នាំ១៨៦២*** ៖ (ថ្ងៃ៥ មិថុនា) ចុះសន្ធិសញ្ញានៅព្រៃនគរជាអាណានិគមបារាំង

ខេត្ត...................នៃកូសាំងស៊ីន គឺ យួន និងលាវ ក៏ប៉ុន្តែចុះហត្ថលេខាជាមួយ ខ្មែរ(ថ្ងៃ១១ សីហា) ដាក់ជាប្រទេសអាណាព្យាបាល (Protected) ។ រីឯជាមួយនឹងស្តេចសៀមវិញ ខ្មែរទទួលស្គាល់ថា សៀមជាម្ចាស់នៃកម្ពុជាត្រួតត្រានៅ បាត់ដំបង ស៊ីសុផុន សៀមរាប ម្លូព្រៃ ទន្លេរពៅ កំពង់ស្វាយ និងពោធិសាត់ ។

***ឆ្នាំ១៨៦៤*** ៖ (ថ្ងៃ៣ មិថុនា)ព្រះរាជាភិសេករបស់ព្រះបាទនរោត្តមទី១ ក្រោមការគ្រប់គ្រងពីអធិរាជបារាំងផង និងព្រះចៅសៀមផង ។

***ឆ្នាំ១៨៦៥*** ៖ ចលនាបះបោរប្រឆាំងនឹងបារាំង ដោយ ពោរកំបោរ ហើយនៅខែធ្នូ ហ្លួងនរោត្តម បានប្តូរព្រះមរបរាជវាំងពីក្រុងឧដុង្គមកភ្នំពេញ ទន្លេបួនមុខ វិញ ។

***ឆ្នាំ១៨៦៦*** ៖ ចាប់សង់ព្រះបរមរាជវាំងសព្វថ្ងៃនេះ ។

***ឆ្នាំ១៨៦៧*** ៖ (សន្ធិសញ្ញា បារាំង-សៀម (ថ្ងៃ ១៥ កក្កដា) ថា សៀមឈប់ជាម្ចាស់នៃកម្ពុជាទៀតហើយ តែនៅរក្សាតំបន់ និងខេត្តដែលខ្លួនកាន់កាប់ហើយ ។

***ឆ្នាំ១៨៧៦*** ៖ (ពីថ្ងៃ១៨ មេសា ដល់ថ្ងៃ៩ វិច្ឆិកា) មានការបះបោរពេញប្រទេសប្រឆាំងនឹងវត្តមានបារាំង ដឹកនាំដោយប្អូនប្រុសហ្លួងនរោត្តម គឺព្រះអង្គម្ចាស់ ស៊ីវុត្ថា ។

***ឆ្នាំ១៨៧៧*** ៖ សេចក្តីសម្រេចរបស់ព្រះមហាក្សត្រខ្មែរជាមួយនិងបារាំងថា លុបបំបាត់ទាសភាព និងរៀបដំណើរការពីមហាមន្ត្រីឱ្យទៅជាគណរដ្ឋមន្ត្រីវិញ នេះជាសេចក្តីសម្រេចដំបូងគេក្នុងការកែទម្រង់រដ្ឋបាលខ្មែរទំនើប ។

***ឆ្នាំ១៨៨៤*** ៖ (ពីថ្ងៃ១៧ ដល់២៤ មិថុនា) មហាសន្និបាត បង្គាប់ដោយបារាំង ដាក់ឱ្យហ្លួងនរោត្តម កែទម្រង់រដ្ឋបាលជាតិ តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម រដ្ឋបាលជាតិត្រូវនៅក្រោមការកាន់កាប់របស់បារាំង តំណាងបារាំងប្រចាំកម្ពុជា បានប្តូរឈ្មោះទៅជា ធស៊ីដង់ សេណេរ៉ាល់ វិញ ឆ្នាំនោះ ព្រះអង្គម្ចាស់ស៊ីវុត្ថា ដឹកនាំការ បះបោរម្តងទៀត (រហូតដល់ឆ្នាំ១៨៨៧) ប្រឆាំងនិងបារាំង មន្ត្រីខ្មែរតាមខេត្តចង់រក្សាបុព្វសិទ្ធិ ប្រមូលពន្ធអាករ និងមានទាសករ ក៏ចូលរួមប្រឆាំងយ៉ាងសកម្ម។

*សូមអញ្ជើញតាមដានភាគបន្តនៅលេខក្រោយ*

*(តមកពីទំព័រទី ១៦)*

ចាក់ឲ្យ កូន និងរូបគាត់ម្តងហើយ ហើយមកពីមូលហេតុនេះ ទើបរូបគាត់ដាច់ចិត្តនាំកូនរត់ចេញពីផ្ទះ និងបានមកស្នាក់នៅសណ្ឋាគារបួនរួចមកហើយ ចាប់តាំងពី ចេញពីផ្ទះរយៈ១០ថ្ងៃ ដើម្បីគេចចេញពីប្តីមក។

តាមប៉ូលិសថា ស្ត្រីរូបនេះបានធ្វើដំណើរមកដល់ខេត្តកោះកុង ចម្ងាយជាង៣០០គីឡូម៉ែត្រ ដោយជិះម៉ូតូឆាលី ពណ៌សមួយគ្រឿង ដឹកកូន២នាក់ និងមានកាបូបដាក់កាំបិតចុងស្រួច ចំនួន៦ កាំបិតប៉ុងតោដងស្ពាន់ចំនួន២ ចំពុះទុង១ ជញ្ជីងយួរចំនួន២ ប្រវាក់២ខ្សែកូនសោរសំរាប់ចាក់ជើងកូនរបស់ខ្លួន ចំនួន៣ ប្រដាប់ប៉ះកង់មួយកំប្លេ ស៊ីរ៉ាំងចាក់ថ្នាំចំនួនមួយនិងរូបថតសំលៀកបំពាក់មួយចំនួនធំទៀត ។ ប៉ូលិសខេត្តកោះកុងបានទំនាក់ទំនងមករដ្ឋអំណាច មូលដ្ឋានសង្កាត់ព្រែកប្រា ក៏បានដឹងថា ស្រីរូបនេះមានសតិមិនល្អទេ ។ តមកនៅពេលតុលាការស៊ើបដឹងពីករណីនេះក៏បានដោះលែងស្ត្រីនោះវិញ ដោយដក ហូតយកចេញនូវអាវុធ និងគ្រឿងសោរច្រវាក់ ប្រគល់ឲ្យតែម៉ូតូសំរាប់ជិះដឹកមកកូនមកស្រុកវិញប៉ុណ្ណោះ។ ចំណែកប្តីស្ត្រីនេះ មិនបានលេចមុខមកបំភ្លឺពីករណីចោទប្រកាន់ថា យ៉ាងណាៗនោះឡើយ។/

- **កាប់ប្រពន្ធរបួសធ្ងន់ ហើយកាប់កូនសម្លាប់២នាក់រួចចងកធ្វើអត្តឃាត**

បុរសម្នាក់ដែលគេសង្ស័យថា មានសតិមិនប្រក្រតី បានប្រើពូថៅកាប់ផ្តាច់ផ្តិលជីវិតក្រុមគ្រួសាររបស់ខ្លួនទាំងអស់ ចុងក្រោយក៏ធ្វើអត្តឃាតដោយ ចងកនៅលើផ្ទះ ។ តាមសេចក្តីរាយការណ៍ថា ហេតុការណ៍ដែលគួរឲ្យរន្ធត់នេះបានកើតឡើងនៅថ្ងៃទី១០ ខែកញ្ញា នៅក្នុង ភូមិរហាល ឃុំស្វាយដូនកែវ ស្រុកពួក ខេត្តសៀមរាប បានបណ្តាលឲ្យស្លាប់មនុស្ស៣នាក់ និងរងរបួសធ្ងន់ម្នាក់ ។

នាយប៉ូលិសស្រុកពួកបានឲ្យដឹងថា បុរសមានសតិមិនប្រក្រតី កាប់កូនកាប់ប្រពន្ធនេះឈ្មោះ គង់ ភ្លី អាយុ ៣២ ឆ្នាំ បានកាប់ប្រពន្ធ ឈ្មោះ ហ៊ាន ហុង អាយុ២៨ឆ្នាំ នឹងពូថៅបណ្តាលឲ្យរងរបួសធ្ងន់នៅផ្នែកក្បាល និងវាយដោយអង្រែបុកគ្រឿងបាក់ដៃស្តាំ។ ចំណែកកូន ម្នាក់ឈ្មោះ ភ្លី រ៉ុត ភេទស្រី អាយុ៧ឆ្នាំ និងកូនប្អូនឈ្មោះ ភ្លី គី ភេទប្រុស អាយុ៣ឆ្នាំ បានស្លាប់បាត់បង់ជីវិត ដោយការកាប់នឹងពូថៅត្រូវក្បាលផ្នែកខាងក្រោយទាំង២នាក់ ។

តាមសាក្សីដែលរស់នៅក្បែរលំនៅឋានកើតហេតុបានឲ្យដឹងថា មុនពេលកើតហេតុគេបានឮសូរសំឡេងស្ត្រីរងគ្រោះជាប្រពន្ធស្រែក ហៅឲ្យអ្នកជិត ខាងជួយ តែពុំមាននរណាម្នាក់ហ៊ានទៅជួយទេ រួចក៏ស្ងាត់មាត់ឈឹងតែម្តង ។ លុះក្រោយមកអ្នកជិតខាងបាននាំគ្នាទៅមើល ក៏ស្រាប់តែឃើញ

*(តទៅទំព័រទី ២០)*

គង់ថតរូបរហ័សទាន់ចិត្ត
KONG'S ONE HOUR PHOTO
DIGITAL LAB SYSTEM
PASSPORT & I.D PHOTOS
PRINTS FROM YOUR DIGITAL CAMERA
FAMILY PORTRAIT & WEDDING
DIGITAL HD VIDEO PRODUCTION
837 E.ANAHEIM ST.
LONG BEACH,CA 90813
BUS(562)218-8434
CEL(562)896-0742
www.weddingvfx.com







# កំណាព្យមន្តស្នេហ៍

ពីជំរុំជាយដែនខ្មែរមកដល់សហរដ្ឋអាមេរិក លោក ម៉ម ឃិន បានរក្សាកំណាព្យដ៏មានតម្លៃមួយបានចំនួន ២៨ ឆ្នាំ។ កំណាព្យដ៏មាន មន្តស្នេហ៍នេះ បានកែច្នៃជីវិតកំព្រាតែម្នាក់ឯងឱ្យបានជួបនារីម្នាក់ឈ្មោះ កញ្ញា វ៉ាន់ កេង ដែលបានក្លាយជាភរិយាពូនជាគ្រួសារមួយសំបុកតាំងពីពេល នោះមក ។

អ្នកស្រី កញ្ញា ម៉ម ទើបនឹងបានឮកំណាព្យនេះអានសាជាថ្មីម្តងទៀតកាលពីខែកក្កដាមុននេះ នៅក្នុងវិទ្យុផ្សាយសម្លេងខ្មែរ-អាមេរិកាំង ហើយ ឧទានដោយសម្លេងរំភើបថា "មិនដឹងថាកំណាព្យនេះនៅថែរក្សាបានយូរដូច្នេះទេ ខ្ញុំរំភើបនឹកឃើញដូចជារឿងនេះកើតនៅថ្មីៗសោះ" ។

សូមអញ្ជើញអានកំណាព្យខ្មែររបស់លោក ម៉ម ឃិន ដែលនឹងនាំអារម្មណ៍លោកអ្នកឱ្យអណ្តែតតាមមន្តប៉ាកាដ៏ចំណានរបស់លោក ។ *ជំរុំជនភៀសខ្លួនជាយដែន,ថ្ងៃទី៣០ មករា ១៩៨០*

លោក ម៉ម ឃិន បានឲ្យដឹងថាកំណាព្យនេះ សរសេរឡើងក្នុងឋានៈដែលលោកអស់សង្ឃឹមថាការខិតខំចង់ប្រាប់ពីបំណង ស្នេហារបស់លោកដល់នាងកញ្ញាតែពុំបានសម្រេច សោះ ទើបដាច់ចិត្តសរសេរកំណាព្យនេះឡើង ដើម្បីបញ្ចប់ទំនាក់ទំនងដ៏គ្មានសង្ឃឹមនេះ. . .ក៏ប៉ុន្តែលទ្ធផលទទួលបែរជាបានផ្ទុយទៅវិញគឺកញ្ញាបានឆ្លើយតបតាមលិខិត ដ៏មានឥទ្ធិពលនោះដោយក្តីអាណិតស្រលាញ់...គ្រួសារមួយក៏ចាប្តកំណើតឡើងនាពេលបន្តបន្ទាប់មក៕

*ខ្មែរប៉ុស្តិ៍*

## អក្ខរាសូមទោស និងសូមលា

អក្ខរាចារចែងថ្លែងសេចក្តី ចូលមកនាងថ្លៃស្រស់បវរ
ល្អល្អះខ្លាំងណាស់ដូចកិន្នរ ចាកចុះមកឈរបង្ហាញប្រាណ ។
ស្រស់អើយសែនស្រស់គួរស្រលាញ់ សក់វែងអង្កាញ់ល្អរកគ្មាន
ភក្ត្រមូលក្រឡង់ដូចដួងច័ន្ទ ញញឹមដោយមានភ្នែកភ្លឺថ្លា ។
ពេលនិយាយខ្លាំងចេញសម្លេង ពិរោះដូចភ្លេងគួរចេតនា
សារសងជាមួយសែនរម្យនា ជាប់ចិត្តគ្រប់គ្រាមិនចង់បែក ។
ដើមទ្រូងមូលក្លំសមល្អណាស់ បង្ហាញយ៉ាងច្បាស់ឃើញផ្ទាល់ភ្នែក
ឃើញហើយមិនចង់ចាកចេញបែក នាងល្អចម្លែកលើសស្រីផង ។
គន់មើលចង្កេះរាងរាវសម មិនតូចមិនធំល្មមតែម្តង
ផ្សំនិងជើងដៃគ្មានទាស់ឆ្គង ល្អក្រៃកន្លងគួរភិសម័យ ។
ឱរាត្រីស្ងាត់សែនជ្រងំ ក្នុងទីជំរុំខ្មែរប្រុសស្រី
នាំគ្នាភៀសខ្លួនមករត់ក្តី សុខសាន្តប្រពៃក្នុងជីវិត ។
រូបខ្ញុំនិទ្រាពុំលក់សោះ នឹកតែស្រីស្រស់ជាប់ក្នុងចិត្ត
គិតចាំមិនបាននៅជិតដិត ពីព្រោះការពិតនាងមិនឆ្លើយ ។
ខ្ញុំបានសារសងសាកសួរនាង ហើយខំប្រឹតព្រាងទៅនាងអើយ
តែនាងហាក់ដូចធ្វើព្រងើយ ពុំបានប្រាប់ឡើយថាស្រលាញ់ ។
ខ្ញុំដេកម្នាក់ឯងធំងកំសត់ រងាររន្ធត់សែនពោរពេញ
ដោយទុក្ខក្រៀមក្រំសែនទោម្នេញ ទោមនស្សខ្ទួលខ្ទាញ់នឹកតែថ្លៃ ។
ទើបសម្រេចចិត្តក្នុងយប់នេះ ចាប់ប៊ិចពិសេសចែងសេចក្តី
សូមទោសដល់នាងសូមប្រណី លើកទោសក្រាស់ក្រៃខ្ញុំបានខុស ។
ទៅស្រលាញ់នាងមិនប្រមាណ តើខ្លួនឯងមានដឹងកំហុស
គិតឱ្យត្រឹមត្រូវមុនដាក់ចុះ ស្រលាញ់នាងនោះមិនបានទេ ។
ដោយដឹងកំហុសខ្លួនទាំងនេះ ខ្ញុំសូមត្រិះរិះដកក្តីស្នេហ៍
សូមនាងអភ័យចាប់តាំងតែ ពេលខ្ញុំសរសេរអក្ខរានេះ ។
រួចហើយរូបខ្ញុំសូមក្រាបលា នាងស្រស់ពុំងារថ្លៃពិសេស
ទៅរកទីរស់តាមតំរិះ ដែលបានចាំចេះជូនជាតិខ្មែរ ។
កំពុងរងទុក្ខសែនស្រណោះ គ្មានបានសុខសោះឥតមានល្ហែ
រត់ភៀសខ្លួនមករស់ពឹងតែ អំណោយហូរហែអន្តរជាតិ ។
បានមកសង្គ្រោះជាតិកំសត់ ត្រូវគេសង្កត់ឱ្យចាកឃ្លាត
ព្រាត់ប្រាស់ពុកម្តាយសណ្តានញាតិ មកនៅព្រោងព្រាតពេញជាយដែន ។
មុននឹងខ្ញុំលាចាកចេញទៅ សូមនាងស្រីពៅរស់សុខសែន
តាមពរខ្ញុំជូនពិតជាផែន បរិសុទ្ធមែនទែនពីដួងចិត្ត ។
សូមឱ្យអ្នកនាងមានសុខភាព ប្រពៃដរាបពេញកំរិត
សុខកាយសប្បាយរីករាយពិត នៅក្នុងជីវិតចាកទុក្ខភ័យ ។
សូមមានអាយុវែងយឺនយូរ ហើយបានផ្សារគូមាននិស្ស័យ
បានជាគូគាប់ជាប់ប្រពៃ ជាអចិន្ត្រៃយ៍តរៀងទៅ ។
ជាទីបញ្ចប់ខ្ញុំសូមលា លើកផ្តុំហត្ថាសូមពាលពៅ
សូមរស់បានសុខស្ថិតស្ថេរនៅ ដរាបតទៅរៀងរហូតអើយ ។

*ពីជនកំសត់អភ័ព្វ*

*(តមកពីទំព័រទី ១៧)*

ទោះបី សាសនាខុសគ្នា ប៉ុន្តែទំនៀមទម្លាប់ការកាន់ព្រះ ពុទ្ធសាសនា ស្ទើរវេញជាផ្លូងតែមួយ ។ លោកថា ការគាំទ្រនាពេលនោះ ដោយសារចរាចរកុនខ្មែរ ចម្រៀងខ្មែរមិនអាចនាំចូលបាន ព្រោះប្រទេស កម្ពុជាយើងស្ថិតក្រោមរបបកុម្មុយនីស្តត្រួតត្រាដោយស្របនយោបាយការទូតខ្មែរ និងអា-មេរិកាំង មិនទាន់បើកផ្លូវចំណងមិត្តភាព ឡើងវិញនៅឡើយ ។

នៅទីបញ្ចប់ នៃការនិទានដំណើររឿងជីវិត លោក ឆាន ឈួ បាននិយាយថា ទោះបីជីវិតថ្មី លើទ្រនុំស្រុកទេសគេដែលមានជីវភាពប្រសើរយ៉ាង ណាក៏ដោយ ក៏លោកមិនភ្លេចជីវិតរស់នៅជាមួយ ក្តាម ខ្យង ត្រកូលកូនអ្នកស្រែដែរ ។ ហើយមិន យូរប្អូនដប់ឆ្នាំទៀត លោកនឹងត្រឡប់ទៅរស់នៅ ប្រទេសកម្ពុជាវិញ ជាមួយដីធ្លីធ្វើស្រែចំការ និង ផលរបរជំនួញនានា ដែលរហូតមកដល់បច្ចុប្បន្ន លោកបានចំណាយថវិកាអស់រាប់ម៉ឺនដុល្លារ ហើយ ។ ប៉ុន្តែមុខរបរបញ្ចូលកុន លោកអត់ បញ្ចប់ទេ បើនៅតែមានការគាំទ្រពីបងប្អូនខ្មែរ ព្រោះកន្លងមកយើងមានវាសនាល្អមានបានក៏ដោយសារវិស័យសិល្បៈនេះឯង ហើយយើងក៏បានជួយដល់សហគមន៍ខ្មែរ-កូនខ្មែរ អាចយល់ពី វប្បធម៌ និងចេះនិយាយភាសាខ្មែរ ព្រោះតែការ ចេះមើលកុននៅផ្ទះជាមួយឪពុកម្តាយ ។

ទន្ទឹមនឹងការសប្បាយចិត្តពីផល របររកស៊ីបាន ក៏ពិតមែនក៏ដោយ តែលោក ឆាន ឈួ បានបង្ហើប ថា ប៉ុន្មានឆ្នាំចុងក្រោយ បញ្ហាលួចចម្លងធ្វើអាជីវកម្ម ដែលក្រុមហ៊ុនត្រូវជួបការលំបាកនិងត្រូវរកវិធានការទប់ស្កាត់ ដោយលោកដាក់ការព្រមាន ថា ពួកគេកំពុងធ្វើឱ្យអ្នកលក់កាស្សែត CD ខាតអូខេ ផលិតកម្មមួយចំនួនឈានទៅរកដួល រលំហើយ ។ ចំណែកពួកគេជាចោរក៏អស់របរ លួចចម្លង និងគ្មានកាស្សែត DVD លក់ដូរទៀត ដែរ ។ ជាមួយនេះ លោក ឆាន ឈួ ក៏សូមឱ្យ មនុស្សដែលមានសុភាវគតិខុសពីសត្វចេះយល់ពី ច្បាប់រក្សាសិទ្ធិ និងមានបញ្ញាញាណផង ។/


# មន្ទីរពេទ្យចាប់សរសៃ HILLSIDE




Dr. Rene Uong, D.C.

## CHIROPRACTIC & REHAB CENTER

ជួបជាមួយវេជ្ជបណ្ឌិត រ៉េន អ៊ុង ពិតជាមិនខុសបំណងឡើយ ។
ទទួលព្យាបាលជម្ងឺ៖
- ឈឺក្បាល, វិលមុខ, ឈឺក, ឈឺចង្កេះ, ឈឺស្មា, ឈឺដៃ-ជើង, ចុករោយសាច់ដុំ, ស្ពឹកដៃ-ជើង, អស់កម្លាំងល្ហិតល្ហៃ, ចាប់សរសៃ-គក់ច្របាច់ និងគ្រោះថ្នាក់ចរាចរ ។

**សូមអញ្ជើញ ដោយមេត្រីភាព!**

- AUTO COLLISION
- WORK INJURY
- SPORT INJURY

2760 E. SPRING STREET, SUITE 150, LONG BEACH, CA 90806
PHONE: 562-424-1200 • FAX: 562-424-1214



# កីឡាបាល់ទះផ្តើមការប្រកួតនៅហ្វីឡាដែលហ្វីយ៉ា...

យុវជននៅហ្វីឡាដែលហ្វីយ៉ា រដ្ឋផែនស៊ីវលនីយ៉ាកំពុងធ្វើឲ្យសហគមន៍ខ្មែរនៅទីនោះផ្លាស់ប្តូរមុខមាត់បន្ទាប់ពីប្រកួតបាល់ទះ(Volleyball) រួចមក ។

នៅទីនោះ គេពុំដែលឮអ្វីល្អក្រៅតែពីការ ស៊ីផឹកជក់ ល្បែង ដែលជាការកំសាន្ត បន្ទាប់ពី ការងារប្រចាំថ្ងៃនោះទេ ។ តែឥឡូវនេះការ ប្រកួតកីឡាមួយបានផ្តើមធ្វើឱ្យមានការចាប់ អារម្មណ៍ថា "ជាការចាប់ផ្តើមត្រឡប់មករកភាព ប្រសើរវិញហើយដោយសារក្រុមយុវជនបាន ងាកមកចាប់អារម្មណ៍ពីសុខភាពខ្លួនវិញ"។

លោក គឿង សាមិត បានផ្តួចផ្តើមយក ទ្រព្យធនដែលបានមកពីការដឹកមនុស្សឱ្យទៅ ធ្វើការនៅតាមរោងចក្រ ទៅទិញបង្គោល, សំណាញ់បាល់ និងគ្រឿងសម្ភារៈកីឡាបាល់ទះ ផ្គត់ផ្គង់ឱ្យក្រុមកីឡាបាល់ទះ៨ក្រុម ដែលរស់ នៅតំបន់ ហ្វីឡាដែលហ្វីយ៉ា ខាងត្បូង ជាតំបន់ ដែលសម្បូរខ្មែររស់នៅ ។ លោកបានលើកទឹក ចិត្តឱ្យយុវកីឡាករនាំគ្នាមកកំសាន្តកាយ ដោយ ប្រកួតកីឡាប្រជែងគ្នាវិញ ។ ក្រុមកីឡាករចម្រុះ ខ្មែរ-លាវ មានទាំងស្រីផង បានចុះឈ្មោះចូល ប្រកួតគ្នារវាងកីឡាករទាំង ៨ក្រុម ដែលសុទ្ធសឹង តែមានសមត្ថភាពជំនាញ ។

កាលពីពេលមុនៗ អ្នកទាំងនោះធ្លាប់ប្រកួត គ្នាខ្លះដែរ ដែលជាការប្រកួតភ្នាល់ដាក់លុយ...។ តែលើកនេះ គេនាំគ្នាប្រកួតដណ្តើមពានរង្វាន់ និងប្រាក់រង្វាន់លើកទឹកចិត្តដល់អ្នកឈ្នះបន្តិច បន្តួច ។ ទីលានហ្វឹកហាត់របស់ក្រុមយុវជនត្រូវ រង់ចាំដល់ម៉ោង៨យប់ ទើបគេអនុញ្ញាតឱ្យចូល ហាត់ ព្រោះកន្លែងមានតិចសំរាប់កីឡាករ ម្យ៉ាង ក្រុមនិមួយៗគេខិតខំសំរាំងកីឡាកររៀងៗខ្លួន អស់រយៈពេលបីខែមុននឹងចាប់ផ្តើមប្រកួត ។

នារាត្រីថ្ងៃ ព្រហស្បតិ៍ ទី៣០ សីហា នេះ គឺជាថ្ងៃប្រកួតផ្តាច់ព្រ័ត្ររវាងក្រុម៤ ដែលចេញ មកពីការប្រកួតឈ្នះអស់រយៈ២សប្តាហ៍មក ហើយនោះហើយជម្រុះចោល៤ក្រុមដែលប្រកួត ចាញ់គេ ក្រុមអាវស និងអាវប្រផេះ ត្រូវប្រកួត យកចំណាត់ថ្នាក់លេខ១ និងលេខ២ រីឯក្រុម អាវក្រហម និងលឿងត្រូវប្រកួតយកចំណាត់ ថ្នាក់លេខ៣ និងលេខ៤ ។ ចុងបញ្ចប់ក្រុមពាក់អាវ ស បានសម្រេច ជ័យជំនះយ៉ាងស្អិតស្អាញ លើក្រុមអាវប្រផេះ ដោយឈ្នះ៥សិត ទល់នឹង៤ ហើយទទួលពាន រង្វាន់ប្រចាំឆ្នាំ និងប្រាក់១០០០ដុល្លារ រីឯក្រុម លេខ២ បានទទួលប្រាក់៥០០ដុល្លារ ។

នេះគឺជាលើកដំបូងបង្អស់ដែល ហ្វីឡាដែល ហ្វីយ៉ា មានការប្រកួតក្នុងសហគមន៍ ដោយក្រុមអាស៊ីរបៀបនេះ ក្រុមគ្រួសារនៃអ្នកប្រកួតបាន ចេញមកអបអរសាទរ ក្នុងបរិកាសរីករាយ ក្រៃលែង ។/ *ខ្មែរប៉ុស្តិ៍*

*(តមកពីទំព័រទី ១៨)*

នៅក្រោមផ្ទះ សុទ្ធតែឈាម ។ ទោះជាបែបណាពុំមានអ្នកណាម្នាក់ហ៊ានចូលទៅជួយឡើយ ព្រោះខ្លាចជនជាប្តី គង់ ភ្លី កាប់ ក៏នាំគ្នារត់ទៅប្តឹងនគរបាលប៉ុស្តិ៍រដ្ឋបាលស្វាយ ជូនកែវឲ្យមកជួយធ្វើអន្តរាគមន៍ ។ ពេលសមត្ថកិច្ចមកដល់បុរសជាប្តីបានចងកសម្លាប់ខ្លួន ស្លាប់បាត់ទៅហើយ ចំណែកកូនស្រីប្រុសតូចៗ ក៏អស់ មធ្យោបាយជួយសង្គ្រោះបានដែរ។ តែសមត្ថកិច្ចនៅតែនាំខ្លួនស្ត្រីជាប្រពន្ធនិងកូនតូចៗ ២នាក់ ទៅកាន់មន្ទីរពេទ្យបង្អែកខេត្តសៀមរាបដើម្បីសង្គ្រោះដែរ។ តែកូនទាំង២នាក់បានស្លាប់ និងត្រូវនាំមកដាក់តំរៀបគ្នាសំរាប់សមត្ថកិច្ចធ្វើកោសល្យវិច័យ ។ ចំណែកស្ត្រីជាប្រពន្ធនិងជាម្តាយកំពុងនៅក្នុងការសង្គ្រោះ របួសដ៏ធ្ងន់ធ្ងរនោះ តែយ៉ាងណានាងនៅរស់មានជីវិត ។ មូលហេតុនៃហេតុការណ៍ដ៏រន្ធត់នេះអ្នកភូមិនិយាយថា អាចមកពីការប្រចណ្ឌ ហើយថា បុរស ជាប្តីមានឥរិយាបថមិនប្រក្រតីបែបនេះតាំងពីចុងខែឧសភាមកម៉្លេះ រហូតដល់ក្រុមគ្រួសារនាំទៅរកគ្រូខ្មែរឲ្យព្យាបាលផង ។ មួយទៀត មុនពេលកើតហេតុ គេបានឃើញឈ្មោះ គង់ ភ្លី កាន់ពូថៅជាប់ ហើយតែងហៅប្រពន្ធ និងកូនៗឲ្យនៅជុំគ្នាជានិច្ចឲ្យតែមានរឿងក្នុងផ្ទះ ។/

*(តមកពីទំព័រទី ៩)*

តុលាការខ្មែរក្រហម ដែលមានភាពយឺតយ៉ាវ និងមានឧបសគ្គ មិនចេះអស់មិនចេះហើយនេះ។ សូម្បីតែ គណបក្ស សម រង្ស៊ី ក៏មិនគាំទ្រគំនិតដកអភ័យឯកសិទ្ធិសម្តេច សីហនុ ដែរ។ ចំណែកមន្ត្រីអង្គការសង្គមស៊ីវិលនានា ក៏មិនហ៊ានធ្វើ អត្ថាធិប្បាយដែរ ដោយសារថា ច្បាប់បានហាមមិនឲ្យមានការ ធ្វើអ្វីដែលប៉ះពាល់ដល់អតីតព្រះមហាក្សត្រ សីហនុ នេះតាំងតែពីទ្រង់បានយាង ចូលនិវត្តន៍ម្ល៉េះ។

ព្រះមហាក្សត្របានព្យាយាម ពន្យល់ដល់សាធារណមតិជាតិ និងអន្តរជាតិក្នុងសារជាភាសាខ្មែរបីទំព័រ កាលពីថ្ងៃទី១ តុលា ថា ទ្រង់មិន ដែលបានចុះចូលជាមួយខ្មែរម្តងណាទេ រហូតតាំងតែពីមុនមក ហើយផ្ទុយទៅវិញ មានតែពួកខ្មែរក្រហមទៅវិញទេ ដែលចុះចូលនឹងព្រះអង្គ ដូចមានលិខិតអតីតមេខ្មែរក្រហម លោក ខៀវ សំផន, លោក ហូ នឹម, លោក ហ៊ូ យន់ នៅជាភស្តុតាង និងបានផ្សាយតាមវិទ្យុប៉េកាំង តាំងតែពីថ្ងៃ ២៣ មីនា ១៩៧០ ។ ឯការជម្លៀសប្រជារាស្ត្រចេញពីភ្នំពេញវិញ ព្រះអង្គបដិសេធថា មិនបានដឹងទាល់តែសោះ រហូតពេលបាន មកគង់នៅភ្នំពេញប៉ុន្មានអាទិត្យ ទើបបានទ្រង់បានដឹងអំពីរឿងនេះតាមរយៈ ការស្តាប់វិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) និងប៊ីប៊ីស៊ី (BBC) ការអានសារទូរលេខរបស់ AFP, AP, Reuter ។ សម្តេច

*(តទៅទំព័រទី ២២)*




# នាយកដ្ឋានមាតុភូមិ

## មជ្ឈមណ្ឌលអក្សរសាស្ត្រខ្មែរ

## Khmer Education Center

នាយកដ្ឋានមាតុភូមិគឺជាមជ្ឈមណ្ឌលអក្សរសាស្ត្រខ្មែរ បានចាប់បដិសន្ធិឡើងនៅឆ្នាំ១៩៨៩ រហូតដល់សព្វថ្ងៃ ។ គោលបំណងដ៏ធំធេងរបស់នាយកដ្ឋានមាតុភូមិ គឺជាការពារកេតម្លៃដ៏វិសេសរបស់ជាតិ គឺវប្បធម៌ និងសង្គមធម៌ ដែលមានអរិយធម៌របស់ជាតិសាសន៍យើង និងមានអក្សរសាស្ត្រជាមូលដ្ឋាន ។

វត្តមាននៃនាយកដ្ឋានមាតុភូមិ គឺជាសុច្ចន្ទៈដ៏ខ្លាំងក្លាក្នុងការរក្សា និងការពារលក្ខណៈពិសេសរបស់ជាតិ គឺអក្សរសាស្ត្រឲ្យបានគង់វង្សជានិរន្តរ៍ ។ យោងទៅតាមគំនិតជាសារវន្តនេះ, នាយកដ្ឋានមាតុភូមិបានខិតខំយ៉ាងអស់ពីសមត្ថភាពក្នុងការស្រាវជ្រាវរកមូលភាពដ៏មានប្រសិទ្ធភាព ។

រក្សានិងការពារគ្មានមូលភាពជាក់លាក់ មិនមែនជារចនាសម្ព័ន្ធដែលមានអនុភាពក្នុងការលើកស្ទួយអក្សរសាស្ត្រឲ្យមានស្ថេរភាពនោះទេ គឺការផ្តល់វឌ្ឍនភាពនៃចំណេះទៅលើវិស័យនេះដើម្បីដណ្តើមយកនូវបសិដ្ឋកម្ម(Improvement) យ៉ាងពិតប្រាកដ ។ បើមិនដូច្នេះទេ, អក្សរសាស្ត្រជាតិយើងមានត្រឹមតែជាព្យញ្ជនៈ និងស្រៈនិស្ស័យតែប៉ុណ្ណោះ ។ ចំពោះការផ្តល់វឌ្ឍនភាពនៃចំណេះដល់អក្សរសាស្ត្រយើងនោះ, គឺគ្មានអ្វីក្រៅពីអនុវត្តភាសាបរិវត្តន៍ (Translation, ការប្រែសម្រួលគ្រប់អត្ថបទជាភាសាបរទេសមកជាភាសាយើង)ដើម្បីផ្តល់នូវចំណេះដឹងដ៏មានតម្លៃជូនដល់ពលរដ្ឋយើង ព្រោះជាការជួយកសាងសង្គមមួយឲ្យបានប្រកបដោយសុខដុមរមនា គឺពឹងផ្អែកទាំងស្រុងទៅលើកិរិតចេះ-ដឹងនៃពលរដ្ឋរបស់ខ្លួនផងដែរ ។

មាតុភូមិបដិសន្ធិឡើងពីកម្លាំងញើសឈាម ពីការខិតខំប្រឹងប្រែងយ៉ាងអស់ពីសមត្ថភាពរហូតសម្រេចក្លាយជាមជ្ឈមណ្ឌលអក្សរសាស្ត្រជាតិនេះឡើង ទោះជាត្រូវចំណាយថវិកាដ៏ច្រើនសន្ធឹកសន្ធាប់ឬក៏ទោះបីមានឧបសគ្គយ៉ាងណាក៏ដោយ ។ ការបង្ហាញនូវគោលការណ៍របស់មាតុភូមិដែលជាអត្ថប្រយោជន៍ចំពោះសង្គមជាតិយើងនេះ គឺជាការអំពាវនាវដោយស្មោះអស់ពីដួងចិត្ត និងជាសំណូមពរសម្រាប់ជីវិតចុងក្រោយក្នុងការទទួលនូវការជួយឧបត្ថម្ភ-គាំទ្រពីសំណាក់ប្រជាពលរដ្ឋរបស់ខ្លួន ។

នាយកដ្ឋានមាតុភូមិ គឺជាកន្លែងការពារកិត្តិយសនិងតម្លៃរបស់ជាតិយើង ជាកន្លែងរបស់យើងដែលជាពលរដ្ឋខ្មែរទាំងអស់គ្នា ។ នាយកដ្ឋានមាតុភូមិយើងមានៈ គណៈកម្មការនិពន្ធ, ការិយាល័យជួយសម្រួលកិច្ចការទូទៅ, សាលារៀន, ផលិតកម្មមាតុភូមិ(ដំណើរទេសចរណ៍ជុំវិញប្រទេសកម្ពុជា), វត្តភ្នំស៊ីឌី (ចម្រៀងដើមរបស់លោកស៊ីន-ស៊ីសាមុត, អ្នកស្រីរស់-សេរីសុទ្ធា, ប៉ែន-រ៉ន, ហួយ-មាស..), ទស្សនាវដ្តីមាតុភូមិ, បណ្ណាល័យ និងបណ្ណាគារមាតុភូមិ, រោងពុម្ព និងជាមជ្ឈមណ្ឌលតម្កល់ឯកសាររបស់ជាតិ ព្រមទាំងល្ខោននិយាយ, ចាប៉ីរឿង, អាយ៉ៃ, ល្ខោនបាសាក់, យីកេ, ភ្លេងខ្មែរ(ភ្លេងការ, ពិណពាទ្យ, មហោរី, ខ្លុយ, សាដៀវ ។ល។

នាយកដ្ឋានមាតុភូមិ សូមលំអោនកាយគោរពចំពោះអតិថិជននិងបងប្អូនរួមជាតិយើងជាទីស្នេហាដែលបានអញ្ជើញមកជួយឧបត្ថម្ភ-គាំទ្រយ៉ាងពេញទំហឹងតាំងតែពីដើមមក ។ ការជួយឧបត្ថម្ភដ៏កក់ក្តៅនេះ គឺជាកាយវិការនៃការយល់យ៉ាងច្បាស់លាស់ពីតម្លៃនៃការកសាងជាតិរបស់យើងតាមបាវចនាដែលថែងថាៈ ភាសារលត់ជាតិរលាយ ភាសាពណ្ណរាយជាតិថ្កុំថ្កើង ។

នាយកដ្ឋានមាតុភូមិ អាចរស់រានមានជីវិតគឺអាស្រ័យលើការយកចិត្តទុកដាក់និងការជួយឧបត្ថម្ភ-គាំទ្រយ៉ាងមោះមុតបំផុតពីសំណាក់ប្រជាជនរបស់ខ្លួន ព្រោះថាមពលដ៏ខ្លាំងក្លានេះអាចជួយជំរុញមាតុភូមិបំពេញបេសកកម្មដ៏ថ្លៃថ្លារបស់ខ្លួនក្នុងការបោះផ្សាយនូវសៀវភៅវចនានុក្រមវេជ្ជសាស្ត្រ, ច្បាប់, នយោបាយ, សេដ្ឋកិច្ច, ទស្សនវិជ្ជា, កសិកម្ម, និងពាក្យវប្បធម៌ជាតិ ព្រមទាំងសៀវភៅសិក្សាផ្សេងៗទៀត បានសម្រេចជាស្ពានក្នុងការបំរើផលប្រយោជន៍ដ៏សំខាន់បំផុតសម្រាប់ប្រទេសជាតិរបស់ខ្លួន ។

ដោយការរីករាយក្តីភាពនិងស្មោះអស់ពីដួងចិត្ត! សូមអរគុណ!

# ហោរាសាស្ត្រប្រចាំខែតុលាថ្ងៃទី ១៦-៣១

**ឆ្នាំ ជូត: (ពពួកទេវតាប្រុស ធាតុទឹក)**



រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងឧបសគ្គច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកប កិច្ចការងារអ្វីក៏ដោយ ចូរកុំមានការធ្វេសប្រហែសឲ្យសោះ ជាពិសេសបើមានមនុស្សចម្លែកយករបស់របរមានតម្លៃមកបញ្ចាំ ឬលក់ឲ្យដោយធូរ ដៃក៏មិនត្រូវទទួល ឬទិញយកដែរ ប្រយ័ត្នបានជាន់ដានចោរ អាចោររួចខ្លួនម្ចាស់ផ្ទះជាប់គុក ។

**ឆ្នាំ ឆ្លូវ: (ពពួកមនុស្សប្រុស ធាតុដី)**



រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារ អ្វីក៏ដោយ ចូរកុំធ្វេសប្រហែសឲ្យសោះ ជាពិសេសចំពោះអាជីវករអ្នករកស៊ីលក់ដូរមុននឹងប្រគល់ ឬទទួលនូវមុខទំនិញសព្វសារពើ ចូរចេះពិនិត្យ មើលគុណភាព និងរាប់ចំនួនឲ្យបានត្រឹមត្រូវទើបមិនចាញ់បោកគេ ។ ចំពោះគូស្វាមីភរិយាចូរប្រយ័ត្នប្រយែងក្រែងមានអ្នកក្រៅមកញុះញង់នាំ ឲ្យមានរឿងក្តៅក្រហាយ ។

**ឆ្នាំ ខាល: (ពពួកយក្សស្ត្រី ធាតុឈើ)**



រាសីលោកអ្នកល្អជាធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះមុជមិនជ្រៅទៅមិនឆ្ងាយ តែបើ លោកអ្នករកស៊ីនាយអាយនៅក្បែរៗ គឺអាចរកផលចំណូលហូរចូលច្រើនគ្រាន់បើ ព្រោះការជួញដូរផ្លូវឆ្ងាយ បើមិនបានជួបគ្រោះអាក្រក់ៗទេ ក៏ នឹងបានបាតដៃទទេ ឬនាំរឿងក្តៅក្រហាយត្រឡប់ចូលផ្ទះវិញដែរ ។

**ឆ្នាំថោះ (ពពួកមនុស្សស្រី ធាតុឈើ)**



រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះបើមានរឿងឈ្លោះប្រកែកកើត ឡើងចូរចេះអត់ធ្មត់ និងរំងាប់ចិត្តឲ្យបានត្រជាក់ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំ បាន ។ ចំពោះគូស្វាមីភរិយាត្រូវចេះយល់ចិត្តគ្នា ទើបមានសេចក្តីសុខនៅក្នុងគ្រួសារ ។

**ឆ្នាំ រោង (ពពួកទេវតាប្រុស ធាតុមាស)**



រាសីលោកអ្នកល្អមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះថ្វីត្បិតតែការងាររកស៊ីអាចរើបៗ បន្តិចឡើងវិញក្តី តែអ្វីដែលលោកអ្នកគួរប្រយ័ត្នប្រយែងនោះ គឺនឹងមានមនុស្សសម្តីផ្អែមត្រជាក់មកលួងលោមប៉ងបោកប្រាស់តាមគ្រប់រូបភាព ដូច្នេះទាំងបុរស-ស្ត្រី គឺមិនត្រូវឆាប់ត្រចៀកទន់ជឿទុកចិត្តគេពេកទេ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះមានភាពស្និទ្ធស្នាលនឹងគ្នាដូចធម្មតា ។

**ឆ្នាំ ម្សាញ់ (ពពួកមនុស្សប្រុស ធាតុភ្លើង)**



រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាស្មុគស្មាញច្រើន ។ ក្នុងរយៈពេលនេះ អ្វីដែលលោកអ្នកត្រូវយក ចិត្តទុកដាក់ជាពិសេសនោះ គឺបងប្អូនញាតិមិត្តខាងប្រពន្ធ ឬខាងប្តីព្រោះរឿងរ៉ាវអាចកើតមានឡើងដោយសារតែបញ្ហារឿងបំណុលប្រាក់កាស ឬក៏ផ្តើមចេញពីពាក្យសម្តីនិយាយទ្រគោះបោះបោកដាក់គ្នា ។

**ឆ្នាំ មមី (ពពួកទេវតាស្រី ធាតុភ្លើង)**



រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះរាល់ ឧបសគ្គ និងរាល់បញ្ហាស្មុគស្មាញ ត្រូវបានសាបរលាបបាត់ស្រមោលអស់រលីង ។ ដូច្នេះលោកអ្នកត្រូវរវៀសរវៃញាប់ជើងញាប់ដៃបន្តិច ព្រោះ ការងារជាមាសប្រាក់ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះប្រកបតែភាពផ្អែមល្ហែមដូចទឹកឃ្មុំ ។

**ឆ្នាំ មមែ (ពពួកទេវតាស្រី ធាតុមាស)**



រាសីល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះថ្វីត្បិតតែ លោកអ្នករកផលចំណូលបានច្រើនគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ហើយក៏មិនខុសពីទូកធំក្តោងធំ នោះដែរ ។ ចំពោះគូស្នេហ៍មានភាពស្និទ្ធស្នាលដូចប្រក្រតី ។

**ឆ្នាំ វក (ពពួកយក្សប្រុស ធាតុដែក)**



រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាលំបាកៗច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបាន ប្រកបកិច្ចការងារអ្វីក៏ដោយ តែងបានជួបនឹងគូប្រជែងជើងខ្លាំងចេញមុខមកតតាំងធ្វើជាឧបករណ៍រាំងស្កាត់មិនឲ្យបោះជំហានទៅមុខបានស្រួល ឡើយ ដូច្នេះចូររៀបជើងព្រួលទុកសម្រាប់ទប់ទល់ជាមុនទើបមិនលិចលង់ទាន់ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះមានរឿងរកាំរកូសច្រើន ។

**ឆ្នាំ រកា (ពពួកយក្សប្រុស ធាតុដែក)**



រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះឱកាសល្អ បានមកដល់ហើយ ដូច្នេះលោកអ្នកត្រូវរវៀសរវៃញាប់ជើងញាប់ដៃបន្តិច តែចូរកុំមានចិត្តលោភលន់ ព្រោះការលោភលន់នាំមកនូវក្តីវិនាស អន្តរាយ ។ ចំពោះគូស្នេហ៍ មានភាពស្និទ្ធស្នាលដូចប្រក្រតី ។

**ឆ្នាំ ច (ពពួកយក្សស្រី ធាតុដី)**



រាសីលោកអ្នកល្អធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែលោកអ្នកអាចរកផល ចំណូលបានច្រើនក្រាស់ក្រែលក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ហើយក៏មិនខុសពីទូកធំក្តោងធំដែលបាន ត្រឹមតែចំណាយកម្លាំង និងពេលវេលាឥតអំពើតែប៉ុណ្ណោះ ។ ចំពោះគូស្វាមីភរិយាក្នុងរយៈពេលនេះ ត្រូវចេះអត់ធ្មត់ទើបបានសុខកាយសប្បាយ ចិត្ត ។

**ឆ្នាំកុរ (ពពួកមនុស្សស្រី ធាតុទឹក)**



រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ក្នុងរយៈពេលនេះទោះជាលោកអ្នកបានប្រកបការងារ អ្វីក៏ដោយ ក៏អាចដំណើរការបានស្រួលដែរ ជាពិសេសបើមានទាក់ទងផ្នែកជំនួញ គឺនឹងទទួលបាននូវផលសម្រេចដូចបំណងប្រាថ្នា ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ បើស្រលាញ់កុំទៅញឹក បើរព្ធកកុំទៅញយ ទើបចំណងស្នេហ៍អាចគង់វង្សបានយូរអង្វែង ។/

# MODERN FABRIC & SHOES

-ហាងយើងខ្ញុំមានលក់ ក្រណាត់ប៉ាក់ ស្បែកជើង សំលៀកបំពាក់
-ទទួលកាត់សំលៀកបំពាក់គ្រប់ម៉ូតសំរាប់បុរសនិងស្ត្រី
-សំអាងការតាមបែបបូរាណនិងសម័យថ្មីនិយម

**សូមស្វាគមន៍ដោយក្តីញញឹម!**









**1636 E. ANAHEIM STREET LONG BEACH, CA 90813**
**Tel: (562) 599-3333 • (562) 599-3237**



# PHNOM PENH EXPRESS
## ក្រុមហ៊ុនទទួលផ្ញើប្រាក់, និងលក់សំបុត្រយន្តហោះ

**ក្នុងឱកាសបុណ្យអុំទូកប្រពៃណីជាតិខ្មែរខាងមុខនេះ ក្រុមហ៊ុន PHNOM PENH EXPRESS មានរៀបចំចាប់ឆ្នោតផ្សងសំណាងជូនដល់បងប្អូនខ្មែរដែលផ្ញើប្រាក់និងទិញសំបុត្រយន្តហោះនៅក្រុមហ៊ុនយើងខ្ញុំ !!!**

★ ជូនឆ្នោតផ្សងសំណាង១សន្លឹក ចំពោះអ្នកផ្ញើប្រាក់ចំនួន $២០០ ។ បើលោកអ្នកផ្ញើកាន់តែច្រើននឹងទទួលបានសន្លឹកឆ្នោតរឹតតែច្រើន ។
★ ជូនឆ្នោតផ្សងសំណាង២សន្លឹក ចំពោះអ្នកទិញសំបុត្រយន្តហោះ១សន្លឹក ។

- ការចាប់ឆ្នោតនឹងប្រព្រឹត្តនៅថ្ងៃអាទិត្យ ទី២៥ ខែ១១ ឆ្នាំ២០០៧ វេលាម៉ោង១២ថ្ងៃត្រង់ ។
- ទទួលទូវអាហារថ្ងៃត្រង់ និងអ្នកដែលគ្មានសំណាងត្រូវឆ្នោតនឹងបានទទួលនូវ Phone Card មួយសន្លឹកតម្លៃ$5.00 ។

**រង្វាន់មានដូចខាងក្រោមនេះ :**

- រង្វាន់ទី១ : សំបុត្រយន្តហោះទៅ-មកស្រុកខ្មែរចំនួន១សន្លឹក ។ លោកអ្នកអាចជ្រើសរើសក្រុមហ៊ុន យន្តហោះដែលចូលចិត្តបាន ។
- រង្វាន់ទី២: ទូរស័ព្ទដៃទំនើបបំផុតម៉ាក NOKIA -N95 ចំនួន១គ្រឿង ។
- រង្វាន់ទី៣: MOTOROLA - V3 ចំនួន១គ្រឿង ។
- រង្វាន់ទី៥: កាតទូរស័ព្ទ $៥ ចំនួន៥០សន្លឹក ។

MasterCard VISA

យុត្តិធម៌នឹងមានចំពោះលោកអ្នក
**បំណងល្អពី**
**PHNOM PENH EXPRESS**

**2140 E. Anaheim St., Long Beach, CA 90804**
**Tel: (562) 434-3322 / (562) 434-3760**



# ភោជនីយដ្ឋានសូភី
## Sophy's THAI & CAMBODIAN CUISINE

Sophy's

ភោជនីយដ្ឋានជាទីពេញចិត្តរបស់លោក-អ្នក ជាមួយម្ហូប ខ្មែរ-ថៃចំរុះគ្រប់មុខដែលមានរសជាតិឈ្ងុយឆ្ងាញ់ពិសារ ។



សូមស្វាគមន៍!

**Mon-Sun 9:00 am - 10:00 pm**
**3720 E. Anaheim St., Ste 102 • Long Beach, CA 90804**
**Tel: (562) 494-1763** Delivery is FREE with purchase of $15.00 or More

